សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការគ្រប់គ្រងទំនិញ
# នាំចូលមកដល់កម្ពុជាតាមផ្លូវគោក

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ឈៀង គន្និដ្ឋា**
**សុទ្ធ ដារ័ត្ន**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ឡុង ម៉ាមីឌី**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី១៦

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការគ្រប់គ្រងទំនិញ
# នាំចូលមកដល់កម្ពុជាតាមផ្លូវគោក

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៧


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ឈៀង គន្ធិដ្ឋា**
**សុទ្ធ ដាវ័ន្ត**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ឡុង ម៉ាមីឌី**



ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី១៦

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ឈៀង កន្និដ្ឋា និង សុទ្ធ ដាវន្តែ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងធុរកិច្ច ជំនាន់ទី១៦ ឆ្នាំសិក្សា ២០១៦-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងគោរពដ៏ខ្ពង់ខ្ពស់ព្រមទាំងការដឹងគុណចំពោះ៖

- **លោកឪពុកអ្នកម្តាយទាំងទ្វេ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងអប់រំទូន្មានប្រៀនប្រដៅយើងខ្ញុំ ព្រមទាំងជួយទំនុកបម្រុងយើងខ្ញុំទាំងកម្លាំងកាយចិត្ត សម្ភារៈគ្រប់បែបយ៉ាងជាពិសេសបានចំណាយនូវថវិកាយ៉ាងច្រើន ដើម្បីឲ្យយើងខ្ញុំបានបន្តការសិក្សារហូតមកដល់ថ្នាក់ឧត្តមសិក្សានេះ។
- **ឯកឧត្តមសាកលវិទ្យាធិការ** លោកសាកលវិទ្យាធិការរង លោក-លោកស្រី ព្រឹទ្ធបុរស -ព្រឹទ្ធបុរសរង លោក-លោកស្រី សាស្ត្រាចារ្យ និងលោក-លោកស្រី មន្ត្រីរាជការ-បុគ្គលិកដែលបម្រើការងារ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានបង្កលក្ខណៈងាយស្រួល និងបង្ហាត់បង្រៀនយើងខ្ញុំ។
- **លោកស្រី សាស្ត្រាចារ្យ ឡុង ម៉ាមីឌី** ដែលបានចំណាយពេលវេលាដ៏មានតំលៃក្នុងការជួយបង្ហាត់បង្ហាញដឹកនាំរូបយើងខ្ញុំ ចងក្រងសារណាបញ្ចប់ការសិក្សានេះ អស់ទាំងកម្លាំងចិត្ត កម្លាំងកាយ ដោយបានផ្តល់ជាមតិយោបល់ល្អៗ និងជួយកែតម្រូវឯកសារនេះរហូតដល់ចប់សព្វគ្រប់ទាំងស្រុងជាស្ថាពរ។

ជាចុងបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យមហាបវរ នូវគុណាណុបការៈដ៏ថ្លៃថ្លាជូនចំពោះលោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង សាស្ត្រាចារ្យរួមទាំងបុគ្គលិកទាំងអស់ និងមិត្តភក្តិរួមជំនាន់ទាំងអស់ ឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺអាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សកលភាវូបនីយកម្ម បានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍កែប្រែមុខមាត់ប្រទេសកម្ពុជា ពីប្រទេសក្រីក្រ មកប្រទេសកំពុងអភិវឌ្ឍដែលមានកំណើនសេដ្ឋកិច្ចប្រមាណ៧% ក្នុងមួយឆ្នាំ។ ក្នុងនោះដែរឃើញថា ការធ្វើពាណិជ្ជកម្មដោះដូរទំនិញមានសក្តានុពលជាងគេ ពីការធ្វើពាណិជ្ជកម្មក្នុងប្រទេស មករវាងប្រទេសជាដៃគូក្នុងតំបន់ និងឈានទៅរកការធ្វើពាណិជ្ជកម្មធំទូលាយជាសកល ក្នុងគោលបំណងដើម្បីទប់ទល់នឹងកំណើនប្រជាជនដែលកើនឡើងឥតឈប់ឈរ ជាមួយនឹងតម្រូវការឥតព្រំដែនរបស់មនុស្ស[1]។ លើសពីនេះទៀត មនុស្សគ្រប់រូបក៏អាចទាញយកផលប្រយោជន៍ពីការធ្វើពាណិជ្ជកម្មនេះចាប់ផ្តើមពីការផ្គត់ផ្គង់តម្រូវការផ្ទាល់ខ្លួន ឈានទៅដល់ការប្រកបអាជីវកម្មដើម្បីរកប្រាក់ចំណូល រហូតដល់មានការប្រកួតប្រជែងដែលសកម្មភាពទាំងនេះសុទ្ធតែបានចូលរួមចំណែកធ្វើឲ្យប្រទេសជាតិមានការរីកចម្រើន។

ជាក់ស្តែងដូចប្រទេសកម្ពុជា ដែលជាប្រទេសមួយស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ មានទំហំពាណិជ្ជកម្មការនាំចេញ នាំចូលក្នុងកំណើន និងគម្លាតប្រមាណ២ប៊ីលានដុល្លារសហរដ្ឋអាមេរិចដូចគ្នា ក្នុងមួយឆ្នាំ គិតចាប់ពីឆ្នាំ២០១៤មក។[2] នេះសបញ្ជាក់ឲ្យឃើញថា កម្ពុជាចាប់ផ្តើមឈានជើងចូលក្នុងទីផ្សារអន្តរជាតិកាន់តែច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។ ជាមួយនឹងតួលេខទំហំពាណិជ្ជកម្មដ៏ច្រើនសម្បើមនេះវាអាចផ្តល់ផលវិជ្ជមានច្រើន តែទន្ទឹមនឹងនោះវាក៏អាចជាកង្វល់ដល់ប្រទេសជាតិផងដែរ នៅពេលដែលទំហំនៃការនាំចូលច្រើនជាងការនាំចេញទៅវិញ ទាំងស្ថានភាពស្ថេរភាពសេដ្ឋកិច្ចក្នុងប្រទេស ទាំងរបៀបនៃគ្រប់គ្រងទំនិញដែលហូរចូលមកឥតឈប់ឈរនេះ។

ជាការពិត កំណើននៃលំហូរទំនិញចូលមកក្នុងប្រទេស បង្កើតឲ្យមានភាពសម្បូរបែបនៃទំនិញដែលផ្តល់ផលវិជ្ជមានដល់អ្នកប្រើប្រាស់ ក៏ដូចជារដ្ឋាភិបាលក្នុងការប្រមូលពន្ធនាំចូល ដែលជាប្រភពចំណូលរបស់រដ្ឋ ប៉ុន្តែផលប៉ះពាល់ក៏អាចកើតមានច្រើនដែរ។ ហេតុដូច្នេះហើយទើប អត្ថបទស្រាវជ្រាវនេះបានផ្តោតសំខាន់ទៅលើនីតិវិធីក្នុងការគ្រប់គ្រងការនាំចូលទំនិញទាំងឡាយតាមផ្លូវគោក ចាប់តាំងពីទំនិញមកដល់ព្រំដែនប្រទេស របៀបនៃការប្រកាសរបស់ម្ចាស់ ការត្រួតពិនិត្យរបស់មន្ត្រីមានសមត្ថកិច្ច ព្រមទាំងយន្តការរបស់រដ្ឋាភិបាលក្នុងការលើកទឹកចិត្ត ឬការដាក់ពិន័យទាំងឡាយទៅលើអ្នកពាក់ព័ន្ធ។

---

[1] វេបសាយ http://www.econlib.org/library/Topics, (ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧)

[2] របាយការណ៍ស្ថិតិប្រចាំឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម

# មាតិកា

បញ្ជីអក្សរកាត់ ..... iv
បញ្ជីរូបភាព ..... v

## សេចក្តីផ្តើម

១. លំនាំបញ្ហា ..... ១
២. ចំណោទបញ្ហា ..... ២
៣. គោលបំណងនៃការស្រាវជ្រាវ ..... ២
៤. អត្ថប្រយោជន៍នៃការស្រាវជ្រាវ ..... ៣
៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..... ៤
៦. វិធីសាស្ត្រស្រាវជ្រាវ និងគម្រោងវិភាគ ..... ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៧

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១. ទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ(International Trade) ..... ៨
១.១.១. និយមន័យពាណិជ្ជកម្មអន្តរជាតិ ..... ៨
១.១.២. អត្ថប្រយោជន៍ពាណិជ្ជកម្មអន្តរជាតិ ..... ៨
១.១.៣. ការនាំចេញ(Export) ..... ៩
១.១.៤. ការនាំចូល(Import) ..... ៩
១.២. ទ្រឹស្តីផលប្រយោជន៍ប្រៀបធៀប (Comparative Advantage) ..... ១០
១.២.១. លោក David Richardo ..... ១០
១.២.២. លោក Porter ..... ១១
១.៣. ទ្រឹស្តីប្រយោជន៍ដាច់ខាត (Absolute Advantage) ..... ១២
១.៣.១. ទ្រឹស្តី Adam Smith ..... ១២
១.៣.២. ទ្រឹស្តី H-O ..... ១៣
១.៤. សញ្ញាណទូទៅនៃទំនិញនាំចូល ..... ១៤
១.៤.១. ប្រវត្តិនៃការនាំចូលទំនិញនៅកម្ពុជា ..... ១៤
១.៤.២. និយមន័យ ..... ១៥

១.៤.៣. ប្រភេទទំនិញនាំចូល ...... ១៦
១.៤.៤. ភាគីពាក់ព័ន្ធ ...... ១៨

## ជំពូកទី២

## នីតិវិធីនៃការគ្រប់គ្រងទំនិញនាំចូលតាមផ្លូវគោក

២.១. កានាំចូលទំនិញមកដល់ដែនកម្ពុជា ...... ២០
២.១.១. ការរាយការណ៍ពីទំនិញនាំចូលដែលមកដល់ ...... ២០
២.១.២. ប្រតិវេទន៍គយ ...... ២០
២.១.២.១. បុគ្គលដែលមាននីតិសម្បទា ...... ២២
២.១.២.២. ឯកសារចាំបាច់ដែលត្រូវមាន ...... ២២
២.១.២.៣. ភារកិច្ច និងការទទួលខុសត្រូវរបស់ជើងសាគយ ឬប្រតិវេទករ ...... ២៣
២.១.៣. នីតិវិធីនៃការបញ្ចេញទំនិញពីគយដែលមានលក្ខណៈពាណិជ្ជកម្ម ...... ២៤
២.២. ការនាំចូលទំនិញតាមរូបភាពផ្សេងទៀត ...... ៣០
២.២.១. ទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ ...... ៣០
២.២.២. ទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ ...... ៣២
២.២.៣. ការគ្រប់គ្រងទំនិញគ្មានការទាមទារ ...... ៣៣
២.២.៤. នីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស(SEZ) ...... ៣៣
២.២.៥. ទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម ...... ៣៥
២.៣. ទោសទណ្ឌ ...... ៣៦

## ជំពូកទី៣

## កំណែទម្រង់របស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការនាំចូលទំនិញ

៣.១. កំណែទម្រង់របស់រដ្ឋាភិបាលទៅលើនីតិវិធីនាំចូល ...... ៣៧
៣.១.១. កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ...... ៣៧
៣.២. យន្តការលើកទឹកចិត្តធុរជនមានអនុលោមភាពខ្ពស់ ...... ៣៩
៣.២.១. លក្ខខណ្ឌដើម្បីក្លាយជាធុរជនល្អបំផុត ...... ៤០
៣.២.២. លក្ខខណ្ឌដើម្បីចុះឈ្មោះជាសមាជិក ...... ៤០
៣.២.៣. អត្ថប្រយោជន៍ដែលទទួលបានរបស់យុវជនល្អបំផុត ...... ៤១
៣.៣. ការបង្កើតនីតិវិធីដើម្បីសម្រួលបន្ថែមទៀតដល់វិនិយោគិន និងអ្នកពាក់ព័ន្ធ ...... ៤១

៣.៤. ការកាត់បន្ថយអត្រាពន្ធអាករលើទំនិញមួយចំនួន ........................................................ ៤២
៣.៤.១. កិច្ចព្រមព្រៀងATIGA របស់បណ្តាប្រទេសសមាជិកអាស៊ាន ........................... ៤២
៣.៤.២. ភាពជាដៃគូសេដ្ឋកិច្ចគ្រប់តំបន់RCEP ........................................................ ៤៣
៣.៤.៣.ការដាក់ពន្ធអាករជាបន្ទុករបស់រដ្ឋ.................................................................... ៤៤

## ជំពូកទី៤

## ការវាយតម្លៃលើការគ្រប់គ្រងការនាំចូលតាមផ្លូវគោក

៤.១. កត្តាដែលមានឥទ្ធិពលដល់ការនាំចូល......................................................................... ៤៦
៤.១.១. ចំណេះដឹង និងការអប់រំ ........................................................................................ ៤៦
៤.១.២. របាំងពន្ធ.......................................................................................................... ៤៦
៤.១.៣. កិច្ចសម្រួលពាណិជ្ជកម្ម........................................................................................ ៤៧
៤.១.៤. ថ្លៃ ................................................................................................................... ៤៧
៤.២. ការវិភាគ SWOT.......................................................................................................... ៤៧
៤.២.១.ភាពខ្លាំង............................................................................................................ ៤៨
៤.២.២. ភាពខ្សោយ....................................................................................................... ៤៩
៤.២.៣. ឱកាស............................................................................................................. ៥១
៤.២.៤. ការគម្រាមកំហែង ............................................................................................. ៥២

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន.......................................................................................................... ៥៤
២. ការផ្តល់អនុសាសន៍ ....................................................................................................... ៥៥
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# បញ្ជីតារាងអក្សរកាត់

| | |
|---|---|
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |
| ATIGA | កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន |
| ASEAN | សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| RCEP | តំបន់ដែលមានភាពជាដៃគូសេដ្ឋកិច្ច |
| FTA | កិច្ចព្រមព្រៀងចរចារពាណិជ្ជកម្មសេរី |
| GDCE | អគ្គនាយកដ្ឋាគយនិងរដ្ឋាករកម្ពុជា |
| SAD | ប្រតិវេទន៍គយ |
| CD | ពន្ធគយ |
| ST | អាករពិសេស |
| VAT | អាករលើតម្លៃបន្ថែម |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| ICT | ប្រព័ន្ធពត៌មាន និងទំនាក់ទំនងបច្ចេកវិទ្យា |

# បញ្ជីរូបភាព

រូបភាពទី១៖ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ០៧
រូបភាពទី២៖ ភាគីពាក់ព័ន្ធ ............ ១៨
រូបភាពទី៣៖ នីតិវិធីប្រតិវេទន៍គយតាមប្រព័ន្ធ ASYCUDA ............ ២៥
រូបភាពទី៤៖ តារាងអត្រាពន្ធនាំចូល អាករពិសេស និងអាករលើតម្លៃបន្ថែម ............ ២៨
រូបភាពទី៥៖ វាក្យស័ព្ទពាណិជ្ជកម្ម ............ ២៩
រូបភាពទី៦៖ លំហូរនៃនីតិវិធីការនាំចូលទំនិញមកSEZ ............ ៣៤
រូបភាពទី៧៖ កម្រិតពិន្ទុក្នុងការចាត់ថ្នាក់ហានិភ័យទាក់ទងនឹងការនាំចូល ............ ៣៨
រូបភាពទី៨៖ ដំណើរការនៃការផ្តល់ពិន្ទុដល់ធុរជន ............ ៣៨
រូបភាពទី៩៖ តំបន់ RCEP ............ ៤៣
រូបភាពទី១០៖ ការលើកលែងពន្ធ និងអាករ ............ ៤៤

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ជាទូទៅ ប្រទេសភាគច្រើននៅលើពិភពលោកតែងជ្រើសរើសវិធីសាស្ត្រការនាំចេញ នាំចូលតាមរយៈការដោះដូរទំនិញ និងសេវារវាងប្រទេស និងប្រទេស ដើម្បីបំពេញតម្រូវការប្រជាជនរបស់ខ្លួនដែលមានកំណើនឥតឈប់ឈរ ពីមួយថ្ងៃទៅមួយថ្ងៃ។ ប៉ុន្តែទំហំពាណិជ្ជកម្មការនាំចេញ និងការនាំចូលនេះ មិនមែនមានសមាមាត្រទាំងអស់នោះទេ។ សព្វថ្ងៃប្រទេសកំពុងអភិវឌ្ឍ ធ្វើការនាំចូលច្រើនជាងការនាំចេញ ពីព្រោះធនធានមានកម្រិត ក៏ដូចជាលទ្ធភាពក្នុងការផលិតផលិតផលប្រើប្រាស់ក្នុងស្រុកដោយខ្លួនឯងស្ថិតក្នុងកម្រិតមធ្យមនៅឡើយ។ ជាការពិត វិនិយោគិន ក៏ដូចជាអ្នកប្រើប្រាស់បានដឹងរួចមកហើយថា ដំណើរការនៃការយកទំនិញបរទេសមកប្រើប្រាស់ក្នុងស្រុកពុំមែនជាការងាយស្រួលទេ ពោលអ្នកដែលពាក់ព័ន្ធទាំងអស់ត្រូវគោរព និងអនុវត្តតាមច្បាប់ប្រទេសរបស់ខ្លួនដែលបានចងក្រង និងនីតិវិធីក្នុងការនាំចូលនេះ ក្នុងគោលបំណងដើម្បីរក្សាផលិតករក្នុងស្រុក ការការពារសុវត្ថិភាពសង្គម និងប្រជាជន ពិសេសគឺដើម្បីរក្សាលំនឹងសេដ្ឋកិច្ចជាតិទាំងមូលឲ្យមានស្ថេរភាពផងដែរ។ ដូចគ្នានេះ សម្រាប់ប្រទេសកម្ពុជា ដែលជាប្រទេសប្រកាន់យករបបគ្រប់គ្រងរដ្ឋមានលក្ខណៈប្រជាធិបតេយ្យសភានិយម បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការនាំចូល ព្រោះសន្ទុះនៃការនាំចូលនេះបានកើនឡើងជាលំដាប់ ជារៀងរាល់ឆ្នាំ។ មិនត្រឹមតែប៉ុណ្ណោះគម្លាតនៃការនាំចេញ និងការនាំចូលមានកាន់តែធំ ដែលធ្វើឲ្យរដ្ឋាភិបាលមានការបារម្ភ និងដាក់ចេញនូវគោលនយោបាយជាបន្តបន្ទាប់ដើម្បីទប់ស្កាត់ការនាំចូលហួសព្រំដែន និងបាតុភាពដែលអាចកើតមានឡើងតាមរូបភាពផ្សេងៗដូចជាទំនិញរត់គេចពន្ធ ឬការនាំចូលទំនិញហាមឃាត់ជាដើម។

វិសាលភាពនៃការនាំចូលទំនិញមកកម្ពុជាគឺមានភាពទូលំទូលាយ ជាកត្តាតម្រូវឲ្យមាននីតិវិធីក្នុងការគ្រប់គ្រងឲ្យបានម៉ត់ចត់ និងមានប្រសិទ្ធិភាព។ ជាក់ស្តែងដូចជា ប្រភេទនៃទំនិញនាំចូលត្រូវបានបែងចែកជាច្រើនក្រុមដើម្បីរក្សាបាននូវការគ្រប់គ្រងល្អ។ លើសពីនេះទៀត ការនាំចូលអាចប្រព្រឹត្តទៅនៅក្រោមរបបរូបភាពផ្សេងៗគ្នាជាច្រើន ដែលជាការចាំបាច់ត្រូវធ្វើការចាត់ថ្នាក់ឲ្យសមស្របទៅនឹងកម្មវត្ថុ និងទំហំនៃការនាំចូល។ ជាមួយគ្នានេះការជ្រើសរើសតម្រាយផ្លូវសម្រាប់ការនាំចូលទំនិញក៏មានសារៈសំខាន់ដែរ ដូចជាតាមតម្រាយផ្លូវគោក ផ្លូវទឹក ឬ ផ្លូវអាកាសជាដើម។ ឧទាហរណ៍: ក្នុងករណី ″ការនាំចូលទំនិញមកកម្ពុជាតាមផ្លូវគោក″ គឺមាននីតិវិធីកំណត់ច្បាស់លាស់ដើម្បីធានាអំពីការគ្រប់គ្រងឲ្យបានល្អ និងគ្រប់ជ្រុងជ្រោយគិតចាប់តាំងពីទំនិញមកដល់ព្រំដែន

រហូតដល់ការប្រើប្រាស់ របៀបនៃការរាយការណ៍ និងការត្រួតពិនិត្យ និងការយកទំនិញចេញពីដែនសមត្ថកិច្ចគយ។

ក្រៅអំពីការបង្កើតគោលនយោបាយ និងនីតិវិធីផ្សេងៗក្នុងការនាំចូលទំនិញ ទៀតសោតរដ្ឋាភិបាលក៏បានធ្វើការយកចិត្តទុកដាក់ តាមរយៈការពិភាក្សាជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន ព្រមទាំងបណ្តាប្រទេសជាដៃគូអភិវឌ្ឍន៍រិះរកគំនិត និងការចរចារផ្សេងៗដើម្បីបម្រើឲ្យផលប្រយោជន៍ជាតិ ដូចជាកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការបន្ធូរបន្ថយពន្ធនាំចូល កិច្ចសម្រួលពាណិជ្ជកម្មជាដើម។ លើសពីនេះទៅទៀត ក្នុងកំឡុងពេលថ្មីៗនេះរដ្ឋាភិបាលបានបង្កើតកិច្ចប្រជុំជាមួយនឹងវិស័យឯកជនក្នុងគោលបំណងសម្របសម្រួល ពង្រឹងសកម្មភាពការធ្វើអាជីវកម្មនាំចេញ នាំចូលនេះឲ្យកាន់តែមានតម្លាភាព និងប្រសិទ្ធិភាពកាន់តែប្រសើរឡើង។

## ២. ចំណោទបញ្ហា

កម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ ដែលពឹងផ្អែកលើការនាំចូល ដើម្បីផ្គត់ផ្គង់តម្រូវការរបស់ប្រជាជននៅក្នុងប្រទេសនាពេលបច្ចុប្បន្ននេះ ជំនួសឲ្យការផលិតផលិតផលក្នុងស្រុក។ ជាពិសេសគឺបណ្តាប្រទេសជិតខាង និងប្រទេសជាប់ព្រំដែនដែលអាចធ្វើការដឹកជញ្ជូននាំចូលមកកម្ពុជាតាមផ្លូវគោកបាន។ លើសពីនេះទៅទៀត តាមរយៈទ្រឹស្តីសិក្សា នៅពេលដែលការនាំចូល ច្រើនជាងការនាំចេញ វានឹងធ្វើឲ្យជញ្ជីងពាណិជ្ជកម្មបាត់បង់លំនឹង និងគ្មានស្ថេរភាពសេដ្ឋកិច្ច។ ហេតុដូចនេះហើយ ទើបធ្វើឲ្យមានចំណោទបញ្ហាលើកឡើងដូចខាងក្រោមៈ

១.តើប្រទេសកម្ពុជាមាននីតិវិធីក្នុងការគ្រប់គ្រងទំនិញការនាំចូលតាមផ្លូវគោកដោយរបៀបណា?

២.តើប្រទេសកម្ពុជានឹងទទួលបានអត្ថប្រយោជន៍ និងចំណាយអ្វីខ្លះពីការនាំចូលនេះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

- ស្រាវជ្រាវពីនីតិវិធីក្នុងការនាំចូលទំនិញមកដល់កម្ពុជាតាមផ្លូវគោក
- ស្វែងយល់ពីរបៀបនៃការគ្រប់គ្រងទំនិញដែលនាំចូលមកតាមផ្លូវគោក និងរបាំងពន្ធ
- ផលប៉ះពាល់ពីការនាំចូលទំនិញមកកម្ពុជាមកលើផលិតករ អ្នកនាំចូល អ្នកប្រើប្រាស់ចុងក្រោយ និងសង្គមជាតិទាំងមូល
- យល់ដឹងអំពីយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលដែលបានដាក់ចេញ ដូចជារនាំងនៃការនាំចូល ការពិភាក្សាជាមួយផ្នែកឯកជនដើម្បីឆ្ពោះទៅរកតម្លាភាព និងយុត្តិធម៌ក្នុងការធ្វើអាជីវកម្មនាំចូល និងការប្រកួតប្រជែងពេញលេញ

- សិក្សាអំពីស្ថានភាពសេដ្ឋកិច្ចកម្ពុជាក្នុងកំឡុងពេលប្រាំឆ្នាំចុងក្រោយ ដោយផ្តោតលើការនាំចូល

- សិក្សាពីលទ្ធភាពក្នុងការស្វែងយល់ទៅលើទស្សនៈផ្សេងៗទៀត អំពីអនាគតនៃការនាំចូលទំនិញមកកម្ពុជា ពិសេសក្នុងលក្ខខណ្ឌដែលកម្ពុជាចូលសមាហរណកម្មអាស៊ាន

- វិភាគ SWOT ទៅលើការនាំចូលទំនិញមកដល់កម្ពុជាតាមផ្លូវគោក

- ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍

## ៤. អត្ថប្រយោជន៍នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **នីតិវិធីនៃការនាំចូលទំនិញមកដល់ប្រទេសកម្ពុជាតាមផ្លូវគោក** ត្រូវបានធ្វើឡើងដើម្បីទទួលបាននូវអត្ថប្រយោជន៍រួមមាន៖

***<u>ភាគីដែលពាក់ព័ន្ធ៖</u>***

- ផ្តល់ជាព័ត៌មានដល់អ្នកដែលមានបំណងចង់ធ្វើការនាំចូលទំនិញមកកម្ពុជា
- រៀបរាប់ជានីតិវិធីលម្អិតដែលអាចឲ្យអ្នកដែលមានចំណាប់អារម្មណ៍ទៅលើបញ្ហានេះងាយយល់ និងចាប់យកចំណុចសំខាន់ៗ
- រំលេចឲ្យឃើញពីតួនាទី និងភារកិច្ចរបស់អ្នកនាំចូល អ្នកដែលពាក់ព័ន្ធ និងស្ថាប័នមានសមត្ថកិច្ចនៅពេលធ្វើការនាំចូលទំនិញ

***<u>អ្នកសិក្សាស្រាវជ្រាវ៖</u>***

- ផ្តល់ជាចំណេះដឹងបន្ថែម ក៏ដូចជាព័ត៌មានដល់អ្នកអានឲ្យបានដឹងអំពីនីតិវិធីក្នុងការនាំចូលទំនិញមកប្រទេសកម្ពុជាតាមផ្លូវគោក មុនពេលយកទៅចែកចាយបន្ត ឬយកទៅប្រើប្រាស់។
- ជាឱកាសវិជ្ជមានសម្រាប់អ្នកអានក្នុងប្រទេសទាំងឡាយដែលមានបំណងចង់ស្វែងយល់អំពីនីតិវិធីនៃការនាំចូលទំនិញមកកាន់ប្រទេសរបស់ខ្លួន ជាពិសេសបានស្វែងយល់អំពីច្បាប់ ក៏ដូចជាលំហូរទំនិញផងដែរ។
- ជាឱកាសមួយសម្រាប់អ្នកស្រាវជ្រាវក្នុងការវិភាគ ស្វែងយល់ និងយកទ្រឹស្តីទាំងឡាយដែលបានសិក្សាក្នុងសាលា មកប្រៀបធៀប និងអនុវត្តនៅក្នុងស្ថានភាពជាក់ស្តែងនិងអាចឲ្យអ្នកស្រាវជ្រាវថ្លឹងថ្លែង និងយល់ដឹងពីភាពខុសគ្នារវាងក្នុងមេរៀន និងសង្គមពិតប្រាកដ។
- ផ្តល់ទុកជាឯកសារដល់អ្នកអាន ក៏ដូចជាអ្នកជំនាន់ក្រោយ ព្រោះព័ត៌មាន និងឯកសារ ការនាំចូលទំនិញមកដល់ប្រទេសកម្ពុជាតាមផ្លូវគោកកន្លងមកនេះនៅមានកម្រិតតិចតួចនៅឡើយ។

**សង្គមជាតិ៖**

- បង្ហាញឱ្យឃើញពីរបៀបនៃការគ្រប់គ្រង ទាក់ទងទៅនីតិវិធីនាំចូលទំនិញរបស់ប្រទេសកម្ពុជា
- ការអភិវឌ្ឍលើការគ្រប់គ្រងទំនិញរបស់ប្រទេសកម្ពុជាក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ធៀបទៅនឹងការគ្រប់គ្រងពីឆ្នាំកន្លងទៅ
- ការរីកចម្រើនផ្នែកបច្ចេកវិទ្យារបស់ប្រទេសកម្ពុជាទៅលើការរៀបចំការគ្រប់គ្រងលំហូរ នីតិវិធីនៃការគ្រប់គ្រងទំនិញ

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ផ្តោតសំខាន់ទៅលើទិដ្ឋភាពផ្នែកដំណើរការ និងវិធីសាស្ត្រនៃការគ្រប់គ្រងទំនិញដែលបាននាំចូលតាមផ្លូវគោក ដោយមិនរាប់បញ្ចូលតាមមាត់ច្រកផ្សេងៗទៀតដូចជាផ្លូវទឹក និងផ្លូវអាកាសឡើយ។ លើសពីនេះទៀត ការនាំចូលនេះគឺគិតចាប់ពីព្រំប្រទល់ប្រទេសកម្ពុជាចូលមកក្នុងប្រទេស ដោយមិនផ្តោតទៅលើការនាំចេញពីប្រទេសនាំចេញនោះទេ។

ច្បាប់ ប្រកាស និងទ្រឹស្តីមួយចំនួនត្រូវបានលើកយកមកបង្ហាញនៅក្នុងការសិក្សាស្រាវជ្រាវនេះ ទាក់ទងទៅនឹងមូលហេតុនៃការធ្វើពាណិជ្ជកម្មនាំចូល ក៏ដូចជានីតិវិធីក្នុងការយកទំនិញចូលក្នុងប្រទេសកម្ពុជា ព្រោះឯកសារគតិយុត្តិទាំងអស់នេះពាក់ព័ន្ធទៅនឹងប្រធានបទស្រាវជ្រាវ ទាំងការធ្វើជាលំនាំ និងទាំងជាជំនួយដល់ការសម្រេចឲ្យបាននូវការស្រាវជ្រាវនេះផងដែរ។ ទន្ទឹមនេះ ក៏ដើម្បីជាការរំលឹកឡើងវិញនូវអ្វីដែលធ្លាប់បានសិក្សាយកមកវិភាគ ក្នុងទម្រង់មួយសង្ខេបមានលក្ខណៈគ្រប់គ្រាន់។

ព័ត៌មានដែលបានយកមកសរសេរនៅក្នុងអត្ថបទស្រាវជ្រាវនេះ គ្របដណ្តប់គិតចាប់ពីឆ្នាំ ២០១២ ដល់ឆ្នាំ២០១៧នេះតែម្តង គិតមកទល់ត្រឹមខែមេសា។ ការស្រាវជ្រាវនេះ គឺពាក់ព័ន្ធរបៀបនៃការគ្រប់គ្រងទំនិញដែលត្រូវបាននាំចូលមកដល់ក្នុងប្រទេសកម្ពុជាតាមផ្លូវគោក មុនពេលយកចេញពីដែនគយ ក្នុងគោលបំណងផ្សេងទៀតដូចជាការចែកចាយលក់ ឬការយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ឬជាអំណោយជាដើម។ ការសិក្សាស្រាវជ្រាវចេញជាអត្ថបទមួយនេះ គឺជាការប្រមូលផ្តុំឯកសារ និងព័ត៌មានពីប្រភពផ្សេងៗដែលមានលក្ខណៈជាសាធារណៈ និងផ្លូវការ រួចយកមកចងក្រង ដកស្រង់ និងសង្ខេបយកគន្លឹះសំខាន់ៗ ព្រមទាំងធ្វើការវិភាគធៀបទៅនឹងទ្រឹស្តី និងមេរៀនដែលធ្លាប់បានសិក្សាពីមុនមក។

# ៦. វិធីសាស្ត្រស្រាវជ្រាវ និងគម្រោងវិភាគ

## ក.វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហា និងសម្រេចនូវគោលបំណងក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ ការប្រមូលទិន្នន័យ និងព័ត៌មានត្រូវបានរៀបចំឡើងដោយប្រើប្រាស់៖

**ការប្រមូលទិន្នន័យបន្ទាប់បន្សំ (SECONDARY DATA)**

ក្នុងការស្រាវជ្រាវនេះ ការប្រមូលទិន្នន័យមិនបានធ្វើឡើងដោយពឹងផ្អែកលើការសម្ភាសន៍ដោយផ្ទាល់ ឬដោយប្រយោលនោះឡើយ ពីព្រោះទិន្នន័យ និងព័ត៌មានដ៏ទូលំទូលាយអាចផ្តល់ភាពជឿជាក់បាន។ មូលដ្ឋានចំបងនៃប្រភពឯកសារ និងព័ត៌មាន ដែលប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវនេះ គឺបានមកពីកម្រងឯកសារដែលបានបោះពុម្ពចេញផ្សាយយ៉ាងសម្រិតសម្រាំង មានដូចជាច្បាប់ ប្រកាស សារាចរណែនាំ សេចក្តីជូនដំណឹង និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតដោយអង្គភាពរដ្ឋដូចជា ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ បន្ថែមពីនេះទៀត ក៏នៅមានឯកសារមួយចំនួនដកស្រង់ចេញពីសៀវភៅ សារព័ត៌មាន ព្រមទាំងសៀវភៅបោះពុម្ពផ្សេងទៀតដែលអាចស្វែងរកនៅតាមបណ្ណាគារ បណ្ណាល័យជាតិ និងតាមរយៈការប្រើប្រាស់គេហទំព័ររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬការប្រើប្រាស់បណ្តាញអ៊ិនធឺណែតជាជំនួយផងដែរ។

គួរគូសបញ្ជាក់ផងដែរថាក្នុងការតាក់តែងឲ្យលេចចេញជាអត្ថបទស្រាវជ្រាវមួយនេះគឺជាការប្រើប្រាស់នូវវិធីសាស្ត្រគុណភាព ព្រោះអត្ថន័យអត្ថបទស្រាវជ្រាវទាំងមូលនេះផ្តោតសំខាន់ទៅលើការប្រមូលឯកសារគតិយុត្តិទាំងឡាយមកធ្វើការរៀបរាប់ពន្យល់បកស្រាយ និងវិភាគអំពីព័ត៌មាន និងស្ថានការណ៍របស់ប្រទេសកម្ពុជា ឲ្យងាយយល់ និងមានលក្ខណៈសាមញ្ញ។

## ខ.គម្រោងវិភាគ

អថេរពីរត្រូវបានកំណត់ ដើម្បីធ្វើការវិភាគ រួមមានអថេរសំខាន់ និងអថេរមានឥទ្ធិពល។

### ខ.១ អថេរសំខាន់

**នីតិវិធីក្នុងការនាំចូលទំនិញមកដល់កម្ពុជាតាមផ្លូវគោក** គឺជាអថេរសំខាន់ក្នុងការស្រាវជ្រាវនេះ។ យើងបានប្រើប្រាស់ទិន្នន័យបន្ទាប់បន្សំដូចបានរៀបរាប់ខាងលើ ដោយធ្វើការប្រមូលព័ត៌មានទាំងឡាយ រួចសង្ខេបយកគន្លឹះសំខាន់ៗ និងធ្វើការបកស្រាយពន្យល់ជាជំហានៗ និងប្រើប្រាស់វិធីសាស្ត្រយ៉ាងណា ដើម្បីងាយស្រួលដល់អ្នកអានក្នុងការស្វែងយល់។ លើសពីនេះទៀត យើងក៏បាន

ធ្វើការវិភាគអំពីលទ្ធផលដែលយើងបានបកស្រាយពីភាពខ្លាំង ឬចំណុចខ្វះខាតទាំងឡាយដែលនៅមាន និងគួរកែលម្អផងដែរ។ បន្ទាប់មកយើងក៏បានធ្វើការសិក្សាទៅកត្តាផ្សេងៗដែលរងឥទ្ធិពលពីអថេរដទៃទៀត ដែលគេស្គាល់ថាជាអថេរមានឥទ្ធិពល។

## ខ.២ អថេរមានឥទ្ធិពល

អថេរមានឥទ្ធិពលនៅពេលនេះ គឺសំដៅលើកត្តាទាំងឡាយដែលអាចធ្វើឲ្យ អថេរសំខាន់មានការប្រែប្រួល ឬការប៉ះទង្គិចចេញពីលទ្ធផលនៃការប្រែប្រួលអថេរមានឥទ្ធិពល ពោលគឺកត្តាទាំងឡាយណាដែលអាចធ្វើឲ្យមានការប្រែប្រួលលើការនាំចូលទំនិញមកកម្ពុជាតាមផ្លូវគោក។

អថេរមានឥទ្ធិពលដែលត្រូវកំណត់មានដូចជា៖

- ចំណេះដឹង និងការអប់រំ
- របាំងពន្ធ
- កិច្ចសម្រួលពាណិជ្ជកម្ម
- ថ្លៃ

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រូបភាពទី១៖ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**សេចក្តីផ្តើម**

↓

**ជំពូកទី១ រំលឹកទ្រឹស្តី**

-ទ្រឹស្តីអន្តរជាតិ

-សញ្ញាណទូទៅនៃប្រភេទទំនិញនាំចូល

↓

**ជំពូកទី២ នីតិវិធីនៃការគ្រប់គ្រងទំនិញនាំចូលតាមផ្លូវគោក**

-ទំនិញមកដល់ដែនកម្ពុជា

-ការគ្រប់គ្រងទំនិញនាំចូលតាមរូបភាពផ្សេងៗទៀត

-ទោសទណ្ឌ

↓

**ជំពូកទី៣ កំណែទម្រង់របស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការនាំចូលទំនិញ**

-កំណែទម្រង់របស់រដ្ឋាភិបាលទៅលើនីតិវិធីនាំចូល

-យន្តការលើកទឹកចិត្តធុរជនមានអនុលោមភាពខ្ពស់

-ការបង្កើតនីតិវិធីដើម្បីសម្រួលបន្ថែមទៀតដល់វិនិយោគិន និងអ្នកពាក់ព័ន្ធ

-ការកាត់បន្ថយអត្រាពន្ធអាករលើទំនិញមួយចំនួន

↓

**ជំពូកទី៤ ការវាយតម្លៃលើការគ្រប់គ្រងទំនិញនាំចូលកតាមផ្លូវគោក**

-កត្តាដែលមានឥទ្ធិពលដល់ការនាំចូល

-ការវិភាគ SWOT

↓

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

# ជំពូកទី១
# រំលឹកទ្រឹស្តី

# ជំពូកទី១

# រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ ទ្រឹស្តីដែលជាប់ពាក់ព័ន្ធមួយចំនួននឹងត្រូវបានលើកយកមកបង្ហាញ ដូចជា ទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ និងពាក្យគន្លឹះមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទ ជាពិសេសគឺធ្វើការពិភាក្សាស៊ីជម្រៅទៅលើនិយមន័យដែលពាក់ព័ន្ធនឹងនីតិវិធីនៃការគ្រប់គ្រងទំនិញនាំចូលនៅកម្ពុជា ដែលរួមមានទាំង ប្រវត្តិនៃការបើកឱ្យមានការនាំចូលទំនិញមកកាន់ប្រទេសកម្ពុជា និងប្រភេទនៃទំនិញនាំចូលផងដែរ។ បន្ថែមពីនេះទៅទៀត ភាគីដែលពាក់ព័ន្ធនឹងកិច្ចការទាំងនេះក៏ត្រូវបានលើកយកមកបង្ហាញផងដែរ ដែលជាមូលដ្ឋានគ្រឹះក្នុងការធ្វើការពិភាក្សាដើម្បីឲ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រងឲ្យមានភាពច្បាស់លាស់ និងត្រឹមត្រូវ។

## ១.១ ទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ ( International Trade )

### ១.១.១ និយមន័យពាណិជ្ជកម្មអន្តរជាតិ

ពាណិជ្ជកម្មអន្តរជាតិគឺជាដំណើរការនៃការដោះដូរនូវមូលធន ទំនិញ និងសេវាកម្មផ្សេងៗដោយឆ្លងកាត់ព្រំដែនអន្តរជាតិ ឬព្រំដែនប្រទេស។[1] នៅតាមបណ្តាប្រទេសភាគច្រើន ការធ្វើពាណិជ្ជកម្មអន្តរជាតិ គឺជាការបង្ហាញពីការបែងចែកផលិតផលដុលក្នុងស្រុក(GSP) ។ ឧទាហរណ៍៖ សកម្មភាពនៃការដោះដូរសំលៀកបំពាក់រវាងកម្ពុជា និងចិន ការនាំចូលនំ និងភេសជ្ជៈពីប្រទេសម៉ាឡេស៊ី មកលក់ក្នុងប្រទេសកម្ពុជា គឺជាដំណើរការធ្វើពាណិជ្ជកម្មអន្តរជាតិ។

### ១.១.២ អត្ថប្រយោជន៍ពាណិជ្ជកម្មអន្តរជាតិ

ពាណិជ្ជកម្មអន្តរជាតិ គឺជាការបើកទ្វារពាណិជ្ជកម្មដោយផ្តល់ឱកាសដល់សហគ្រិននៅក្នុងពិភពលោក និងផ្តល់នូវជម្រើសដ៏សម្បូរបែបដល់ប្រជាជនក្នុងការទិញទំនិញ និងសេវាទាំងឡាយ។ មិនត្រឹមតែប៉ុណ្ណោះ វាធ្វើឲ្យទំនិញមានគុណភាពល្អជាងមុន ដោយសារតែមានការប្រកួតប្រជែងនៅក្នុងទីផ្សារ ជាពិសេសផលិតករក្នុងស្រុកខិតខំពង្រឹងគុណភាពទំនិញរបស់ខ្លួនឱ្យកាន់តែមានភាពល្អប្រសើរ ដើម្បីអាចលក់នៅលើទីផ្សារបាន ជាពិសេសបានបង្កើននូវជម្រើសយ៉ាងសម្បូរបែបសម្រាប់អ្នកប្រើប្រាស់។ ពាណិជ្ជកម្មអន្តរជាតិអនុញ្ញាតឲ្យអ្នកផលិត និងចែកចាយ ធ្វើការស្វែងរកផលិតផល សេវាកម្ម និងសមាសភាពផលិតនៅប្រទេសក្រៅ។ ការធ្វើបែបនេះ ក្រុមហ៊ុនទទួលផលប្រយោជន៍ខាងថ្លៃដើម ឬដើម្បីសិក្សាអំពីបច្ចេកវិទ្យាជឿនលឿន ដែលប្រើប្រាស់នូវបរទេស។ ក្រៅពី

[1] Steve Suranovic , International Trade Theory And Policy, May 2010

នេះ វាបានផ្តល់ឲ្យអ្នកប្រើប្រាស់នូវទំនិញ និងសេវាកម្មផ្សេងៗគ្នា ហើយបង្កើននូវចំណូល និងចំនួនការងារធ្វើៗបន្ថែមលើសពីនេះទៅទៀត ការធ្វើពាណិជ្ជកម្មអន្តរជាតិអាចអន្តរជាតិអាចធ្វើឱ្យចំណងមិត្តភាពរវាងប្រទេសជាដៃគូកាន់តែមានភាពល្អប្រសើរឡើងក្នុការវិនិយោគទុន ព្រមទាំងការនាំចេញនាំចូលនូវផលិតផល និងសេវាឲ្យកាន់តែមានភាពស៊ីចង្វាក់គ្នាថែមទៀត។[2]

**១.១.៣ ការនាំចេញ** ( Export )

ការនាំចេញជាអ្វី? ការនាំចេញគឺជាលក់ទំនិញ ឬសេវាចេញពីប្រទេសមួយ ទៅប្រទេសមួយទៀតដោយឆ្លងកាត់ព្រំដែនប្រទេស ពោលគឺជាការធ្វើពាណិជ្ជកម្មចេញទៅក្រៅប្រទេស។[3] ការនាំចេញត្រូវបានទទួលរ៉ាប់រងដោយក្រុមហ៊ុននានា ឬដោយរដ្ឋាភិបាល ហើយវាមិនធ្វើឡើងតាមបែបបទជាច្រើន ដោយបានបែងចែកទំនិញនាំចេញជាពីរដាច់ដោយឡែកពីគ្នា រួមមានដូចជា៖

ក. ទំនិញ

ខ. សេវា

ការនាំចេញគឺជាការផ្ញើ ឬ ការដឹកជញ្ជូនទំនិញពីប្រទេសមួយដើម្បីទៅលក់នៅប្រទេសមួយទៀត។ ក្នុងការដោះដូរនៅតាមទីផ្សារអន្តរជាតិ អ្នកនាំចេញតែងតែជាអ្នកលក់ ឬជាភ្នាក់ងាររបស់អ្នកលក់។ ការនាំចេញគឺជាការលក់ទំនិញដោយភ្នាក់ងារសេដ្ឋកិច្ចដែលមានទីតាំងនៅក្នុងប្រទេសមួយទៅឲ្យភ្នាក់ងារជាច្រើនដែលមានទីតាំងនៅក្នុងប្រទេសមួយផ្សេងទៀត។

**១.១.៤ ការនាំចូល** (Import)

តើការនាំចូលជាអ្វី?

- ការនាំចូល គឺជាការទិញ ឬទទួលទំនិញ ឬសេវាកម្មផ្សេងៗពីបរទេស ដើម្បីលក់ ឬក្នុងគោលបំណងផ្សេងទៀតចូលមកក្នុងប្រទេសមួយទៀត។
- ឬការនាំចូលរបស់ប្រទេសមួយ គឺជាការនាំចេញរបស់ប្រទេសមួយផ្សេងទៀតដោយផលិតផលដែលធ្វើការនាំចូល និងចែកចាយនៅក្នុងទីផ្សារក្នុងស្រុកដោយអ្នកផលិតបរទេសដោយឆ្លងកាត់របាំងព្រំដែន។[4] គេនាំចូលប្រភេទទំនិញទាំងឡាយដែលមានប្រភពពីបរទេស ដោយមានកំណើតមកពីប្រទេសផលិត ឬប្រទេសអន្តរការី (Intermediary)។ វាត្រូវបានទុកសម្រាប់ធ្វើការប្រើប្រាស់ឯកជនដូចជាក្នុងឧស្សាហកម្ម

[2] Harri Daniel, Benefits of International Trade, March 16, 2011

[3] www.businessdictionary.com (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧)

[4] www.businessdictionary.com (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧)

កសិកម្ម។ល។ ឬក៏គេអាចធ្វើការបំលែងដើម្បីប្រើប្រាស់ក្នុងប្រទេសអ្នកនាំចូល ឬសម្រាប់ធ្វើការនាំចេញទៅប្រទេសទី៣។

ការនាំចេញ គឺជាការកាត់បន្ថយទិន្នន័យដែលត្រូវការ ហើយការនាំចូលគឺជាការបង្កើនផលិតផលត្រូវការ។ ដូចនេះឥទ្ធិពលនៃពាណិជ្ជកម្មអន្តរជាតិទៅលើផលិតផលដែរត្រូវការ អាចត្រូវបាវាស់វែងដោយភាពខុសប្លែកគ្នា រវាងការទូទាត់សោហ៊ុយក្នុងការនាំចេញពោលគឺពេលកើនឡើង គឺវាមានឥទ្ធិពលដល់កំណើនផលិតផលដែលត្រូវការ ហើយនៅពេលដែលមានការថយចុះ តំហាយនៃផលិត ផលដែលត្រូវការក៏មានការថយចុះផងដែរ។

## **១.២ ទ្រឹស្តីផលប្រយោជន៍ប្រៀបធៀប** (Comparative Advantage)

### **១.២.១ លោក** DAVID RICARDO

ទ្រឹស្តីរបស់លោក David Ricardo គឺនិយាយអំពីឧត្តមភាពប្រៀបធៀប ដែលបានចែងក្នុងសៀវភៅរបស់លោកមានឈ្មោះថា ″Principles of Political Economy and Taxation″។ យោងតាមសៀវភៅ ″International Business(ឆ្នាំ២០០២)″ បានលើកឡើងពីទ្រឹស្តីរបស់លោក David Ricardo អំពីផលប្រយោជន៍ប្រៀបធៀប នៅពេលដែលប្រទេសមួយមានឧត្តមភាពដាច់ខាតលើមុខទំនិញ។ គាត់និយាយថា ″វាពិតជាត្រឹមត្រូវសម្រាប់ប្រទេសមួយ ដែលបានឯកទេសកម្មក្នុងការផលិតប្រកបដោយប្រសិទ្ធភាពខ្ពស់ ការធ្វើការទិញទំនិញ ដែលខ្លួនមិនសូវមានប្រសិទ្ធភាពក្នុងការផលិត។″[5]

ដូច្នេះហើយ នៅក្នុងសៀវភៅរបស់លោក បាននិយាយថា ហេតុអ្វីបានជាប្រទេសមួយត្រូវការទិញទំនិញពីប្រទេសមួយទៀត ទោះបីទំនិញនោះខ្លួនអាចផលិតបានក៏ដោយ។ លោកបានអះអាងថា ការចំបាច់មិនមែនជាហេតុផល ដែលធ្វើឲ្យមានពាណិជ្ជកម្មអន្តរជាតិទេ ប៉ុន្តែ″ឧត្តមភាព (Advantage)″នោះទេ ទើបជាមូលហេតុសំខាន់ដែលនាំឲ្យមានការធ្វើពាណិជ្ជកម្មអន្តរជាតិ។ ជាមួយគ្នានេះដែរលោកបានបញ្ជាក់ថា ទ្រឹស្តីភាពកម្រនៃធនធានសេដ្ឋកិច្ច (Scarcity Of Economic Resources) ដែលក្នុងនោះមានកត្តាសំខាន់បីគឺ ធនធានមនុស្ស ធនធានធម្មជាតិ និងទំនិញវិនិយោគ ដែលនាំឲ្យប្រទេសមានឯកទេសកម្ម។ ដោយសារតែធនធានមានកំណត់នេះ ហើយដែលជាកត្តាធ្វើឲ្យប្រទេសមានឯកទេសកម្មក្នុងទំនិញច្រើននោះ ត្រូវបានប្រៀបធៀបរវាងទំនិញទាំងពីរថាត្រូវផលិតមួយណា និងទាមទារឲ្យមានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសផ្សេងៗទៀត ដែលមានឯកទេសកម្មជាង និងមានតម្លៃឱកាសទាបជាង។ ការបោះបង់ផលិតផលមួយ

[5] Charles W.L.Hill, International Business, New York MaGraw, 2002, Page 128

ដោយគិតថាទំនិញនោះទទួលបានផលប្រយោជន៍ច្រើនជាងហៅថា តម្លៃឱកាស។ តាមរយៈការស្រាវជ្រាវរបស់លោក David Ricardo ស្តីអំពីបាតុភូតសេដ្ឋកិច្ច គាត់បានបង្ហាញពីច្បាប់នៃផលប្រយោជន៍ប្រៀបធៀប (Comparative Advantage) គឺជាមូលដ្ឋានសំខាន់នៃពាណិជ្ជកម្មជាតិពីព្រោះថាប្រទេសនីមួយៗធ្វើឯកទេសកម្មលើមុខទំនិញ ឬសេវាកម្មរបស់ខ្លួនមានឧត្តមភាពប្រៀបធៀប ហើយធ្វើពាណិជ្ជកម្មអន្តរជាតិ ដើម្បីដោះដូរយកមុខទំនិញ ឬសេវា ដែលខ្លួនត្រូវការ និងគ្មានប្រយោជន៍ប្រៀបធៀបពីប្រទេសដទៃវិញនោះ គេទាំងអស់គ្នានឹងទទួលបានអត្ថប្រយោជន៍ និងចំណេញពីគ្នាទៅវិញទៅមកយ៉ាងច្រើន។[6] ឧទាហរណ៍ ប្រទេសចិនអាចផលិតសំលៀកបំពាក់បាន ៤យ៉ាតក្នុងមួយម៉ោង ប៉ុន្តែសហរដ្ឋអាមេរិកផលិតបានតែ២យ៉ាតដោយប្រើពេលមួយម៉ោងដូចគ្នា។ តែចំពោះការផលិតស្រូវសំលីវិញអាមេរិកអាចផលិតបាន ៦តៅ ក្នុងមួយម៉ោង តែប្រទេសចិនផលិតបានត្រូវតែ៤តៅក្នុងមួយម៉ោង។ ដូចនេះយើងឃើញថាប្រទេសចិនមានផលប្រយោជន៍ប្រៀបធៀបក្នុងការផលិតសម្លៀកបំពាក់ ហើយសហរដ្ឋអាមេរិកវិញមានផលប្រយោជន៍ប្រៀបធៀបក្នុងការផលិតស្រូវសំលី។

ជាទូទៅ ទ្រឹស្តីប្រយោជន៍ប្រៀបធៀប មានសក្តានុពលនៅក្នុងពិភពនៃផលិតកម្ម ដោយសារតែវាមិនដាក់កម្រិតទៅលើការពាណិជ្ជកម្មសេរី ប៉ុន្តែដាក់កម្រិតលើការផ្លាស់ប្តូរទំនិញ។ ទ្រឹស្តីនេះបានបង្ហាញថាអ្នកប្រើប្រាស់គ្រប់ជាតិសាសន៍អាចប្រើប្រាស់នូវផលិតផលច្រើនជាងនេះ ប្រសិនបើមិនមានការដាក់កម្រិតផ្លាស់ប្តូរទំនិញ។ កត្តាទាំងនេះភាគច្រើនកើតមានឡើងនៅក្នុងប្រទេសដែលខ្វះនូវផលប្រយោជន៍ដាច់ខាតក្នុងការផលិតទំនិញផ្សេងៗ។[7]

**១.២.២ លោក** PORTER

ទ្រឹស្តីរបស់លោក Michael Porter អំពីផលប្រយោជន៍ប្រៀបធៀបនៃជាតិមួយបានបញ្ជាក់ថា គំរូពាណិជ្ជកម្មនៃជាតិមួយកំណត់ដោយឥទ្ធិពល៤យ៉ាងគឺ ៖

១. កត្តាធម្មជាតិ (Factor Endowment)

២. លក្ខខ័ណ្ឌតំរូវការក្នុងស្រុក

៣. ឧស្សាហាកម្មទំនាក់ទំនង (Relating and Supporting Industry) និងលើកទឹកចិត្ត

៤. យុទ្ធសាស្ត្ររចនាសម្ព័ន្ធ និងការប្រកួតប្រជែងរបស់ក្រុមហ៊ុន។[8]

---

[6] Mason A. Carpenter and Sanjyot P. Dunung, Challenges and Opportunities in International Business, 2012

[7] Charles W.L. Hill, International Business. New York MaGraw, 2002, Page 130

[8] John J. Wild, Kenneth L. Wild and Jerry C. Y. Han, International Business, 2003

Porter បានកំណត់សម្គាល់ថាកត្តាមួយចំនួនក្នុងចំណោមកត្តាសំខាន់ៗជាច្រើនដែលផ្តល់ជាលទ្ធផលក្នុងការបង្កើតផលប្រយោជន៍ប្រៀបធៀបរបស់ជាតិក្នុងឧស្សាហកម្មនោះ គឺវត្តមាននៃកត្តាអត្ថប្រយោជន៍នៃផលិតកម្មនាំមុខអ្នកទិញក្នុងស្រុកដែលមានការវិនិច្ឆ័យល្អ និងការជឿនលឿន ឧស្សាហកម្មដែលទំនាក់ទំនង និងការលើកទឹកចិត្តល្អ ហើយនិងការប្រកួតប្រជែងក្នុងស្រុកដ៏ខ្លាំងក្លា។[9] Porter បានបញ្ជាក់ថានយោបាយរបស់រដ្ឋាភិបាល និងក្រុមហ៊ុនពាណិជ្ជកម្មអាចធ្វើឲ្យការសន្មតទាំងបួនដែលសំរេចដោយផលប្រៀបធៀបរបស់ប្រទេសមួយប្រសើរឡើង ឬអន់ថយ។

## ១.៣ ទ្រឹស្តីប្រយោជន៍ដាច់ខាត (Absolute Advantage )

### ១.៣.១ ទ្រឹស្តី ADAM SMITH

នៅក្នុងសៀវភៅនិយាយអំពីទ្រព្យសម្បត្តិរបស់ជាតិ ( The Wealth of Nation ) ដែលគួរឲ្យកត់សម្គាល់របស់លោកក្នុងឆ្នាំ១៧៧៦ លោក Adam Smith បានរិះគន់យ៉ាងខ្លាំងដល់ការសន្មតរបស់ពាណិជ្ជកម្មវិទូដែលបាននិយាយថា ពាណិជ្ជកម្មគឺជាល្បែងផលបូកដែលមានចំនួនសូន្យមួយ (Zero – Sum game) Smith បានបញ្ជាក់ដោយលើកឧទហរណ៍បញ្ជាក់ពីការពិតចំពោះប្រទេសពីរដែលធ្វើពាណិជ្ជកម្មជាមួយគ្នាដោយស្ម័គ្រចិត្តដែលប្រទេសទាំងពីរនោះត្រូវបានទទួលផល។[10] ប្រសិនបើប្រទេសមួយមិនបានទទួលផល ឬខាតបង់នោះជាធម្មតា គេនឹងបដិសេធន៍មិនធ្វើពាណិជ្ជកម្មទេ។[11]

យោងតាមសំដីរបស់ Adam Smith ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរនោះគឺពឹងផ្អែកលើផលប្រយោជន៍ដាច់ខាត (Absolute Advantage) ។ នៅពេលដែលប្រទេសមួយមានសមត្ថភាពជាង (ឬមានផលប្រយោជន៍ដាច់ខាតលើស) ប្រទេសដទៃទៀតក្នុងផលិតកម្មនៃទំនិញទី១ ប៉ុន្តែមានសមត្ថភាពទាបជាង (ឬមានចំពោះមិនមែនប្រយោជន៍ដាច់ខាត (Absolute Disadvantage)) ប្រទេសដទៃទៀតក្នុងផលិតកម្មទំនិញទី២នោះ បន្ទាប់មកប្រទេសទាំងពីរអាចទទួលបានផលដោយការធ្វើឯកទេសកម្មនូវផលិតកម្មនៃទំនិញដែល មានផលប្រយោជន៍ដាច់ខាត ។តាមដំណើរនេះ ប្រភពធនធានជាច្រើនត្រូវបានប្រើប្រាស់ក្នុងមធ្យោបាយប្រកបដោយប្រសិទ្ធភាពភាគច្រើន ហើយទិន្នផលនៃទំនិញទាំងពីរនឹងកើនឡើង។

---

[9] John J. Wild, Kenneth L. Wild and Jerry C. Y. Han, International Business, 2003

[10] Mason A. Carpenter and Sanjyot P. Dunung, Challenges and Opportunities in International Business, 2012

[11] John J. Wild, Kenneth L. Wild and Jerry C. Y. Han, International Business, 2003

ការកើនឡើងនូវទិន្នផលនៃទំនិញទាំងពីរ បានវាស់វែងពីផលចំណេញដែលបានពីការធ្វើឯកទេសកម្មក្នុងផលិតកម្មដែលបានបំរុងទុកនៃដំណើរការផលិតខ្ពស់របស់គេ។ ទ្រឹស្តីរបស់លោក Adam Smith បានលើកហេតុផលថាជាមួយនឹងការកើនឡើងនៃចំនួនប្រជាជនរបស់ប្រទេសដែលធ្វើពាណិជ្ជកម្មជាមួយគ្នាទាំងសងខាងទទួលបានអត្ថប្រយោជន៍ ហើយការធ្វើពាណិជ្ជកម្មគួរតែត្រូវបានលើកទឹកចិត្ត។ ម្យ៉ាងទៀត ជនជាតិបារាំងគឺជាអ្នកផលិតស្រាដ៏មានរសជាតិបំផុតនៃពិភពលោក ដោយមានការរួមផ្សំពីអាកាសធាតុអនុគ្រោះ ទឹកដីល្អ និងឯកទេសកម្មកើនឡើង(Accumulated Expertise)។ ហេតុនេះប្រទេសជាតិមួយមានផលប្រយោជន៍ដាច់ខាតក្នុងផលិតកម្មនៃផលិតផលមួយគឺនៅពេលដែលខ្លួនមានសមត្ថភាពភាពជាងប្រទេសដទៃទៀតក្នុងការផលិត។

**១.៣.២ ទ្រឹស្តី** Heckscher – Ohlin

សេដ្ឋកិច្ចវិទូជនជាតិស៊ុយអែតឈ្មោះ Eli Heckscher (ក្នុងឆ្នាំ១៩១៩) និង Bertil Ohlin (ក្នុងឆ្នាំ១៩៩៣) បានដាក់ការពន្យល់ខុសប្លែកគ្នាមួយអំពីផលប្រយោជន៍ប្រៀបធៀប ដែលកើតចេញពីការខុសក្នុងកត្តាទាយជ្ជទាន (ធម្មជាតិ) របស់ជាតិ។ តាមរយៈកត្តាទាយជ្ជទាន ពួកគាត់ចង់មានន័យថា វិសាលភាពចំពោះប្រទេសមួយដែលផ្តល់ឲ្យនូវប្រភពធនធានដូចជា ទឹកដី កម្លាំងពលកម្ម និងមូលធន។ ប្រទេសផ្សេងៗគ្នាមានកត្តាទាយជ្ជទានខុសៗគ្នា។ ភាពសម្បូរហូរហៀរជាកត្តាមួយដែលធ្វើឲ្យតម្លៃចុះទាប ដូច្នេះទ្រឹស្តីរបស់ Heckscher- Ohlin បានទស្សន៍ទាយថា ប្រទេសទាំងឡាយនឹងនាំចេញទំនិញដែលប្រើប្រាស់កត្តាសំបូរក្នុងស្រុកច្រើន ហើយនាំចូលនូវទំនិញដែលប្រើប្រាស់កត្តាកម្រនៅក្នុងស្រុក។[12] ហេតុនេះ ទ្រឹស្តីរបស់ H-O គឺចង់ពន្យល់ពីគំរូពាណិជ្ជកម្មអន្តរជាតិដែលយើងសង្កេតឃើញនៅក្នុងសេដ្ឋកិច្ចពិភពលោក។

ទ្រឹស្តី Heckscher-Ohlin បានញែកថា គំរូពាណិជ្ជកម្មអន្តរជាតិត្រូវបានកំណត់ដោយកត្តាទាយជ្ជទានខុសប្លែកគ្នា។ វាបានព្យាករណ៍ថាប្រទេសជាច្រើននឹងនាំចេញទំនិញ ដែលប្រើប្រាស់កត្តាសម្បូរក្នុងស្រុកច្រើន ហើយនាំចូលទំនិញដែលប្រើប្រាស់កត្តាកំរក្នុងស្រុកច្រើន។

ប្រទេសមួយដែលមានការផ្គត់ផ្គង់ធនធានច្រើន គឺទាក់ទងទៅនឹងការផ្គត់ផ្គង់ប្រភពធនធានផ្សេងទៀតគឺជាប្រភពធនធានដែលសំបូរ។ ប្រទេសមួយនឹងទោរទៅរកផលិតផលទំនិញជាច្រើនដែលទាក់ទងនឹងការប្រើប្រាស់ប្រភេទមានទំនោរទៅរកការនាំចេញនូវទំនិញដែលខ្លួនមានលើសតម្រូវការ។

[12] Steve Suranovic , International Trade Theory And Policy , May 2010

ទ្រឹស្តី H-O ថាប្រទេសមួយនឹងនាំចេញផលិតផលដែលផលិតកម្មត្រូវការកត្តាសម្បូរ ហើយថោករបស់ប្រទេសនោះច្រើន និងនាំចូលនូវផលិតផលណាដែលផលិតកម្មត្រូវការកត្តាកំរ ហើយថ្លៃរបស់ប្រទេសនោះច្រើន។ យោងតាមកត្តាសមភាពថ្លៃធៀប និង ថ្លៃដាច់ខាតត្រលប់មកចំពោះកត្តាដូចគ្នាដោយឆ្លងកាត់ប្រទេស។[13]

## ១.៤. សញ្ញាណទូទៅនៃទំនិញនាំចូល

### ១.៤.១ ប្រវត្តិនៃការនាំចូលទំនិញនៅកម្ពុជា

រដ្ឋខ្មែរដំបូងត្រូវបានបង្កើតឡើងដែលស្គាល់ថា ជាសម័យនគរភ្នំ ក្រោមអំណាចរបស់ព្រះមហាក្សត្រនៅក្នុងសតវត្សទី១។ ចាប់តាំងពីសម័យនគរភ្នំនេះមក ជនជាតិខ្មែរធ្វើទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ជាពិសេសទៅលើរបស់មួយចំនួនដូចជាមាស និងប្រាក់ជាមួយនឹងចក្រភពឥណ្ឌា ចិន អ៊ីរ៉ង់ រ៉ូម៉ាំង ចាម ភូមាជាដើម ដែលបន្សល់ទុកនូវភស្តុតាងតាមកំពង់ផែបុរាណអូកែវ និងកំពង់ផែមួយចំនួនទៀតនៅភាគខាងត្បូងប្រទេសថៃ។ ទោះបីជាសម័យនោះមានការយកចិត្តទុកដាក់ខ្លាំងលើវិស័យពន្ធដារ ដូចជាការកាន់កាប់ដីធ្លីក៏ដោយ ក៏វត្តមាននៃពាណិជ្ជកម្មអន្តរជាតិពោលការនាំចូលទំនិញនៅតែបន្តមានអាទិភាព។

បន្ទាប់មក នៅក្រោយសម័យអង្គរ រដ្ឋបាលគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិត្រូវបានកាន់កាប់ភាគច្រើនទៅតាមបក្សពួក និងអ្នកដែលជិតស្និទ្ធ សមាជិករាជវង្ស ផ្តាច់មុខលើទំនិញសំខាន់ៗដូចជាអាវុធ អាភៀន ភ្លុកដំរី ចានព័រសឺលែន គ្រឿងសក្ការៈ និងត្បូងពេជ្រជាដើម ហើយវិធីសាស្ត្រនៃការគ្រប់គ្រងនេះបន្តមកដល់សម័យអាណានិគមនិយមបារាំង។

ក្រោយសម័យអាណានិគមបារាំង ទើបមានការកែប្រែមួយចំនួនហាក់មានភាពប្រសើរជាងមុន និងចាប់ផ្តើមធ្វើការប្រមូលពន្ធលើទំនិញនាំចូល បូករួមទាំងអាករ និងកម្រៃផ្សេងៗទៀតចាប់តាំងពីពេលនោះមក។ លុះរបបប៉ុលពតចូលមកដល់ កិច្ចដំណើរការរបស់រដ្ឋបាលគយ ពោលពាណិជ្ជកម្មអន្តរជាតិត្រូវបានបញ្ឈប់ទាំងស្រុង។ ក្នុងឆ្នាំ១៩៧៩ ស្ថាប័នរបស់រដ្ឋាភិបាលក៏បានចាប់ផ្តើមបង្កើតឡើងវិញ ហើយការធ្វើពាណិជ្ជកម្មក៏ចាប់ផ្តើមបន្តិចម្តងៗរហូតមកដល់បច្ចុប្បន្ននេះ ដែលកម្ពុជាជាប្រទេសដែលមានសន្តិភាព និងពឹងផ្អែកភាគច្រើនលើការនាំចូលដើម្បីផ្គត់ផ្គង់តម្រូវការនៅក្នុងប្រទេស។

[13] Mason A. Carpenter and Sanjyot P. Dunung, Challenges and Opportunities in International Business ,2012

### ១.៤.២ និយមន័យ

តើការនាំចូលទំនិញជាអ្វី? ការនាំចូលទំនិញក្នុងន័យនេះចង់សំដីដល់ការនាំនូវផលិតផលទំនិញចូលពីបរទេសមកក្នុងប្រទេស ដែលធ្វើការនាំចូលដោយឆ្លងកាត់នូវព្រំដែនពីបរទេសមួយទៅប្រទេសមួយដោយស្របច្បាប់។

ដើម្បីយល់កាន់តែស៊ីជម្រៅបន្ថែមទៀតយើងគម្បីត្រូវយល់ឲ្យបានច្បាប់នូវពាក្យគន្លឹះមួយចំនួនសិនដូចជាពាក្យថា "នីតិវិធី" "ការនាំចូល" "ទំនិញ" និងពាក្យ"ផ្លូវគោក"។

- នីតិវិធី មកពី៖ នីតិ+ វិធី

ពាក្យនីតិ (នី.តិ) ន.(បាលី) ប្រែថាច្បាប់ ,ឧបាយជាគ្រឿងណែនាំ ,បែបផែន, ទំនៀមទំលាប់, ប្រពៃណី។[14]

រីឯពាក្យថា វិធី = ពិធី ន.(បាលី) គឺជាបែបបទ, បែបផែន, បែបយ៉ាង, បែបរបៀប។

ដូចនេះពាក្យថា "នីតិវិធី" មានន័យថាគឺជាបែបបទ ឬបែបផែននៃច្បាប់ដែលកំណត់លើអ្វីមួយសម្រាប់ណែនាំដល់ការប្រតិបត្តិឬដំណើរការផ្សេងៗ។

តាមន័យមួយទៀត ពាក្យមួយទៀត "នីតិវិធី" មានន័យថាជាបែបបទ ដំណើរការសម្រាប់អនុវត្តឬវិធានទាំងឡាយសម្រាប់ដំណើរការកិច្ចការ ឬរឿងហេតុអ្វីមួយ។[15]

- "ការនាំចូល" ពាក្យនេះពាក់ព័ន្ធទៅនឹងការទំនិញ អាចនិយាយបានថាការមកដល់របស់ទំនិញទោះបីជាតាមរូបភាពស្របច្បាប់ ឬមិនស្របច្បាប់ក៏ដោយឲ្យតែឆ្លងកាត់ព្រំដែនមកដល់ដែនគយ ឬទីកន្លែងនៅក្រៅដែនគយ។[16]
- "ទំនិញ" តាមច្បាប់ស្តីពីគយ សម្តៅដល់ចលនទ្រព្យទាំងឡាយ។[17] តែបើតាមវចនានុក្រមសម្តេចសង្ឃ ជួន ណាត ពាក្យថា"ទំនិញ" (ន) ជាអ្វីៗដែលសម្រាប់ឲ្យគេទិញលក់ ឬដោះដូរសម្រាប់ធ្វើការប្រើប្រាស់។[18]
- "ផ្លូវគោក" គឺមកពីពាក្យថា ផ្លូវ+គោក ។ ពាក្យ"ផ្លូវ" (ន) ប្រែថាគន្លងសម្រាប់ដើរ, សម្រាប់ទៅមក ,ចន្លោះ,លំអាន, ដំណើរ, លំនាំ, ហេតុ,វិធី។[19]

---

[14] វចនានុក្រមខ្មែរ ភាគ១ ភាគ២,បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១២ គ.ស១៩៨៦,ទំព័រ៥១៦

[15] លោក ម៉ឹក គឹមស្រួយ, សន្ទានុក្រមពាក្យច្បាប់ និងធុរកិច្ច,បោះពុម្ពលើកទី១,២០១៥ ,ទំព័រ៣៩

[16] មាត្រា៩ នៃច្បាប់ស្តីពីគយនៃព្រះរាជាណាចក្រកម្ពុជា

[17] មាត្រា៩ នៃច្បាប់ស្តីពីគយនៃព្រះរាជាណាចក្រកម្ពុជា

[18] វចនានុក្រមខ្មែរ ភាគ១ ភាគ២,បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១២ គ.ស១៩៨៦,ទំព័រ៤៥៨

[19] វចនានុក្រមខ្មែរ ភាគ១ ភាគ២,បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១២ គ.ស១៩៨៦,ទំព័រ៧១៤

រីឯពាក្យ "គោក" ១.(គុ.ន) ដែលទីទៃពីមានទឹក គឺដែលគ្មានទឹកទីគោក ។[20]

សរុបមកពាក្យថា"ផ្លូវគោក" មានន័យថាគឺជាគន្លងដែលទីទៃពីទឹក កន្លែងទៅមកដែលគ្មានទឹក។

**១.៤.៣. ប្រភេទទំនិញនាំចូល**

ជាការពិត ទំនិញទាំងអស់នាំចូលតាមរូបភាពតែមួយ តែមានសណ្ឋានច្រើនដែលពិបាកក្នុងការចាត់ថ្នាក់ ក៏ដូចជាចំណាំផងដែរ។ ក្នុងន័យនេះ ដើម្បីងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ និងបកស្រាយពន្យល់ ទំនិញដែលត្រូវបានរៀបរាប់នៅក្នុងឯកសារគតិយុត្តិទាំងឡាយត្រូវបានលើកយកមកសង្ខេប និងចាត់ថ្នាក់ដូចខាងក្រោម៖

- **ទំនិញនាំចូលជាស្ថាពរ៖** ជាប្រភេទទំនិញដែលនាំចូលមកក្នុងប្រទេសក្នុងគោលបំណងលក់ចែកចាយ ឬយកទៅប្រើប្រាស់ដោយមិននាំចេញទៅវិញ ឬនាំចេញទៅប្រទេសទី៣ទៀតនោះទេ។ ឧទាហរណ៍ ការនាំចូលសាប៊ូដុសខ្លួនម៉ាក Shukubutsu មកលក់នៅក្នុងផ្សារទំនើបបាយ័ន។ នេះជាការនាំចូលជាស្ថាពរ ព្រោះមិនមែនបំណង ឬធ្វើការនាំចេញទៅវិញទេ។
- **ទំនិញនាំចូលបណ្តោះអាសន្ន៖**[21] ជាប្រភេទទំនិញដែលនាំចូលមកក្នុងប្រទេសក្នុងគោលបំណង មួយច្បាស់លាស់ មានរយៈពេលកំណត់ត្រឹមត្រូវ ព្រមទាំងមានការអនុញ្ញាតិពីស្ថាប័នសមត្ថកិច្ច ហើយនឹងត្រូវនាំចេញទៅវិញនៅពេលកាលកំណត់នោះត្រូវបានបញ្ចប់។
- **ទំនិញនាំចូលដើម្បីនាំចេញទៅវិញ៖** ជាប្រភេទទំនិញដែលនាំចូលក្នុងប្រទេសក្នុងគោលបំណងកែច្នៃ ឬបំលែងផលិតផលពាក់កណ្តាលសម្រេចឲ្យទៅជាផលិតផលសម្រេច រួចធ្វើការនាំចេញទៅប្រទេសដើមវិញ ឬទៅប្រទេសទីបី។ ឧទាហរណ៍ ការនាំចូលផលិតផលសម្លៀកបំពាក់ដែលមិនទាន់សម្រេច(មិនទាន់ដេរកអាវ ឬដៃអាវ)មកកម្ពុជា រួចឆ្លងកាត់ការកែច្នៃឲ្យចេញជាផលិតផលសម្រេច ហើយធ្វើការនាំចេញទៅវិញ។ គួរគូសបញ្ជាក់ដែរថាទំនិញប្រភេទនេះនឹងត្រូវបានលើកលែងពន្ធ និងអាករ[22]។ គោលបំណងចំបងគឺការបង្កើតឲ្យមានការងារធ្វើដល់ប្រជាជនក្នុងស្រុក។
- **ទំនិញនាំចូលមានលក្ខណៈពាណិជ្ជកម្ម៖** ជាប្រភេទទំនិញដែលនាំចូលមកក្នុងប្រទេសក្នុងគោលបំណងធ្វើពាណិជ្ជកម្មដូចជាការលក់ដុំ ឬលក់រាយ ច្រើនជាងការយកមកប្រើប្រាស់

[20] វចនានុក្រមខ្មែរ ភាគ១ ភាគ២,បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១២ គ.ស១៩៨៦,ទំព័រ១៩១
[21] មាត្រា១៥ នៃច្បាប់ស្តីពីគយនៃព្រះរាជាណាចក្រកម្ពុជា

ផ្ទាល់ខ្លួន។ ឧទាហរណ៍ ការនាំចូលស្បែកជើងមួយរយគូពីប្រទេសវៀតណាម មកកម្ពុជាក្នុងគោលបំណងដើម្បីលក់នៅផ្សារធំថ្មី។ នេះជាគម្រូនៃការនាំចូលដែលមានលក្ខណៈពាណិជ្ជកម្ម។

- **ទំនិញប្រើប្រាស់ផ្ទាល់ខ្លួន៖** ជាប្រភេទទំនិញនាំចូលមកក្នុងប្រទេស ឬជាប្រភេទទំនិញជាប់នឹងខ្លួន ឥវ៉ាន់អ្នកដំណើរក្នុងគោលបំណងសម្រាប់តែការប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ។ ឧទាហរណ៍ សុខបានទិញទូរស័ព្ទថ្មីមួយគ្រឿង ព្រមទាំងមានសម្លៀកបំពាក់មួយចំនួនមកជាប់ជាមួយចេញដំណើរពីប្រទេសអាមេរិច មកប្រទេសកម្ពុជា។
- **ទំនិញបេសកម្មការទូត៖** ជាប្រភេទទំនិញនាំចូលមកក្នុងប្រទេស ឬជាប្រភេទទំនិញជាប់នឹងខ្លួនឥវ៉ាន់អ្នកដំណើរក្នុងគោលបំណងមកបំពេញបេសសកម្មផ្លូវការនៅប្រទេសកម្ពុជា។
- **ទំនិញជាអំណោយមនុស្សធម៌៖** ជាប្រភេទទំនិញនាំចូលមកក្នុងប្រទេស ដែលមានលក្ខណៈជាអំណោយ ដែលមិនយកប្រើប្រាស់ផ្ទាល់ខ្លួន ឬការយកចែកចាយលក់បន្តនោះទេ។ ឧទាហរណ៍ការនាំចូលរបស់អង្គការមួយចំនួន ដូចជារទេះរុញសម្រាប់ចាស់ជរា ដើម្បីជាជូនដល់អ្នកក្រីក្រជនពិការ ឬទុកសម្រាប់ផ្គត់ផ្គង់គោលបំណងរបស់អង្គការ។
- **ទំនិញពិពរណ៌៖** ជាប្រភេទទំនិញនាំចូលមកក្នុងប្រទេសក្នុងគោលបំណងដើម្បីដាក់តាំងបង្ហាញនូវផលិតផលរបស់ខ្លួន។ ឧទាហរណ៍ ការពិពរណ៌ទំនិញផលិតផលថៃនៅប្រទេសកម្ពុជាចាប់ពីថ្ងៃ ២៥ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៧។ ទំនិញប្រភេទនេះអាចជាកម្មវត្ថុនៃការបង់ពន្ធ និងអាករប្រសិនបើផលិតផលទាំងនោះត្រូវបានលក់នៅក្នុងប្រទេសនាំចូល។
- **ទំនិញគ្មានការទាមទារ៖** ជាប្រភេទទំនិញដែលបាននាំចូលមកក្នុងប្រទេសហើយទុកនៅក្នុងឃ្លាំងគយលើសរយៈកាលកំណត់ ហើយម្ចាស់ទំនិញមិនមកទទួលយកទំនិញនោះទៅវិញ ឬជាប្រភេទទំនិញដែលម្ចាស់ទំនិញធ្វើការបោះបង់ចោលជាលាយលក្ខណ៍អក្សរ។ ឬអាចជាទំនិញបញ្ញើតាមប្រៃសនីយន៍ដែលមិនអាចរកម្ចាស់ឃើញ និងមិនអាចផ្ញើត្រលប់ទៅវិញបាន។

### ១.៤.៤. ភាគីពាក់ព័ន្ធ

រូបភាពទី២៖ ភាគីដែលពាក់ព័ន្ធនឹងប្រតិបត្តិការនាំចូល




រាល់ប្រតិបត្តិការលើការនាំចូលទំនិញនេះ តែងតែមានការចូលរួមពី៖

- ❖ អ្នកនាំចូល៖ អាចជាម្ចាស់ទំនិញ ឬតំណាងម្ចាស់ទំនិញដែលជាភាគីសំខាន់នឹងធ្វើឲ្យកើតមានប្រតិបត្តិការនេះឡើង។
- ❖ ជើងសារគយ៖ ក្នុងករណីខ្លះ ម្ចាស់ទំនិញមិនបានធ្វើការនាំចូលទំនិញដោយផ្ទាល់នោះទេ ដូច្នេះតាមរយៈនេះ គេអាចរកអ្នកដែលបំពេញប្រតិបត្តិការនេះជំនួស។ ទន្ទឹមនេះ ដើម្បីទទួលបាននិតិសម្បទាជាជើងសារគយត្រូវបំពេញលក្ខខណ្ឌមួយចំនួន និងជាពិសេសត្រូវឆ្លងកាត់ការប្រលងជាមុនសិន។
- ❖ មន្រ្តីគយ៖ ជាមន្រ្តីមានសមត្ថកិច្ចដែលមានតួនាទីក្នុងការត្រួតពិនិត្យមើលលើរាល់ទំនិញនាំចូល ការអនុញ្ញាតិ ការទទួលការបង់ពន្ធអាករលើទំនិញនាំចូល ព្រមទាំងឆ្លងកាត់នូវនីតិវិធីគយឲ្យបានចប់សព្វគ្រប់ទើបអាចយកទំនិញចេញពីដែនគយបាន។[23]
- ❖ ស្ថាប័នមានសមត្ថកិច្ច៖ ក្នុងករណីខ្លះដើម្បីធានាសុវត្ថិភាពសង្គម ទំនិញខ្លះមិនត្រូវបានអនុញ្ញាតឲ្យនាំចូលនោះទេប្រសិនបើមិនមានការឯកភាព ឬការត្រួតពិនិត្យឲ្យបានត្រឹមត្រូវពី

[23] មាត្រា៥៦ នៃច្បាប់ស្តីពីគយព្រះរាជាណាចក្រកម្ពុជា

ស្ថាប័នជំនាញ។ ពេលខ្លះទំនិញមួយចំនួនក៏ត្រូវមានការត្រួតពិនិត្យឲ្យបានម៉ត់ចត់ និងមានការអនុញ្ញាតពីស្ថាប័នមានជំនាញទៀតផងទើបអាចធ្វើការនាំចូលបាន។ ឧទាហរណ៍ លិខិតអនុញ្ញាតពីក្រសួងសុខាភិបាលក្នុងការនាំចូលថ្នាំពេទ្យ លិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្មក្នុងការនាំចូលសារធាតុគីមីជាដើម។

# ជំពូកទី២
# នីតិវិធីនៃការគ្រប់គ្រង
# ទំនិញនាំចូលតាមផ្លូវគោក

# ជំពូកទី២
# នីតិវិធីនៃការគ្រប់គ្រងទំនិញនាំចូលតាមផ្លូវគោក

ដោយយោងតាមទៅតាមច្បាប់ និងបទប្បញ្ញត្តិគយនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់អនុវត្តន៍ទៅលើទំនិញនាំចូលដែលបាននាំចូលមកដល់ក្នុងដែនដីកម្ពុជា ជាទូទៅគេត្រូវគោរពទៅតាមនីតិវិធីដូចខាងក្រោម ៖

## ២.១. ការនាំចូលទំនិញមកដល់ដែនកម្ពុជា

នៅពេលទំនិញនាំចូលទាំងអស់បានឆ្លងកាត់ព្រំដែនអន្តរជាតិ ចូលមកក្នុងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ដែនសមត្ថកិច្ចគយ មុននឹងត្រូវបញ្ចេញទៅដល់ក្រុមហ៊ុនសម្រាប់ធ្វើការចែកចាយបន្តដោយស្របច្បាប់។ រាល់ទំនិញនាំចូលត្រូវរាយការណ៍ទៅកាន់ការិយាល័យគយ ឬទីកន្លែងផ្សេងទៀតទៅតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ហើយត្រូវគោរពទៅតាមលក្ខខណ្ឌដែលខាងគយបានកំណត់ មុននឹងត្រូវបានបញ្ចេញចេញពីដែនដីគយទៅវិញ។ ទំនិញនាំចូលមកដល់កម្ពុជាត្រូវ រាយការណ៍អំពីទំនិញនាំចូល បំពេញនូវប្រតិវេទន៍គយ ទទួលនូវការត្រួតពិនិត្យគយ ព្រមទាំងបង់ពន្ធ និងអាករ ទៅតាមការកំណត់តម្លៃគិតពន្ធគយទំនិញនាំចូលដែលមានចែងក្នុងបញ្ជីតារាងពន្ធគយ កំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាធរមាន ទៅតាមពេលវេលាកំណត់។

### ២.១.១ ការរាយការណ៍ពីទំនិញនាំចូលដែលមកដល់

ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍នៅការិយាល័យគយដែលនៅជិតបំផុតតាមតម្រាយផ្លូវស្របច្បាប់ដូចជា ៖

- ក្នុងករណីទំនិញ ដែលកាន់រក្សាដោយជនណាម្នាក់ ដែលបានមកដល់កម្ពុជា ឬ ជាផ្នែកនៃអីវ៉ាន់ផ្ទាល់ខ្លួន ត្រូវរាយការណ៍ដោយជននោះផ្ទាល់។
- ក្នុងករណីទំនិញ ដែលបាននាំចូលដោយសេវាកម្មបញ្ញើ ឬតាមរយៈបញ្ញើប្រៃសណីយត្រូវរាយការណ៍ដោលបុគ្គលដែលបាននាំចេញទំនិញនោះមកកម្ពុជា។
- ក្នុងករណីទំនិញ ដែលបានផ្ទុកនៅលើមធ្យោបាយដឹកជញ្ជូនរាប់បញ្ចូលទាំងមធ្យោបាយដឹកជញ្ជូនយោធាដែលមកដល់កម្ពុជា ត្រូវរាយការណ៍ដោយជននទទួលខុសត្រូវមធ្យោបាយទាំងនោះផ្ទាល់។
- ក្នុងករណីទំនិញ ដែលនាំចូលតាមបែបផ្សេងទៀតត្រូវរាយការណ៍ដោយបុគ្គលដែលធ្វើក្នុងនាមជាអ្នកនាំចូល។ បុគ្គលគ្រប់រូបដែលរាយការណ៍ពីទំនិញ ក្រោមបញ្ញត្តិនៃមាត្រានេះត្រូវះ

- ឆ្លើយនូវរាល់សំណួរដែលសួរដោយមន្ត្រីគយពាក់ព័ន្ធនឹងទំនិញរបស់ខ្លួន។
- បង្ហាញនូវទំនិញ តាមរបៀបដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងគោលបំណងសម្រាប់ធ្វើអធិការកិច្ចនៅពេលដែលមានការតម្រូវ។

លើសពីនេះទៀត គ្មានជនណាម្នាក់អាចរើទំនិញចេញពីមធ្យោបាយដឹកជញ្ជូនពេលមកដល់កម្ពុជាបានទេមុនពេលដែលទំនិញទាំងនោះ ត្រូវបានរាយការណ៍ដល់គយស្របតាមច្បាប់នេះ លើកលែងតែក្នុងករណីដែលសុវត្ថិភាពមធ្យោបាយដឹកជញ្ជូនទំនិញ ជននានាលើមធ្យោបាយដឹកជញ្ជូន ឬ តតិយជនផ្សេងទៀតត្រូវបានគំរាមកំហែងក្នុងល័ក្ខខ័ណ្ឌមានអាសន្ន។

**២.១.២. ប្រតិវេទន៍គយ** (SAD)

ប្រតិវេទន៍គយ ឬគេអាចហៅបានថាជា ឯកសាររដ្ឋបាលតែមួយ (Single Administrative Document) គឺជាឯកសារដែលគេប្រើប្រាស់សម្រាប់សង្ខេបព័ត៌មានសំខាន់ៗដែលគេត្រូវរាយការណ៍អំពីទំនិញដែលគេនាំចូលមកក្នុងប្រទេស។

ជាទូទៅពេលទំនិញមកដល់ដែនកម្ពុជា ដែលជាចាំបាច់ ឯកសារ SAD នេះត្រូវតែបំពេញរួចជាស្រេច ដោយម្ចាស់ទំនិញ ឬជើងសារគយ។ តាមរយៈឯកសាររដ្ឋបាលតែមួយវាអាចកាត់បន្ថយពេលវេលា ក៏ដូចជាផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ភាគីអ្នកនាំចូល និងខាងស្ថាប័នមានសមត្ថកិច្ចគយរួមមាន៖

- កាត់បន្ថយពេលវេលាពីការរាយការណ៍ផ្ទាល់មាត់ ទៅជាការរាយការណ៍សង្ខេប និងអស់ខ្លឹមសារនៅក្នុង SAD
- មានទម្រង់ជាឯកសារផ្លូវការ និងអាចរក្សាទុកបានយូរ
- តាមរយៈឯកសារ SAD អាចបញ្ជាក់ពីវត្ថុបំណងនៃការនាំចូល, ចេញពីណាទៅណា ទំនិញនោះជាអ្វី, មានផលប៉ះពាល់ឬទេ។

នៅក្នុង SAD មួយឯកសារមាន ៥៤ ប្រអប់សម្រាប់បំពេញដើម្បីជាពត៌មានទុកសម្រាប់រាយការណ៍ជូនមន្ត្រីគយនៅពេលមុនយកទំនិញចេញពីសន្និធិគយ។[24] ទោះបីទំនិញទាំងនោះត្រូវជាប់កាតព្វកិច្ចពន្ធ និងអាករ ឬត្រូវបានលើកលែងក្តី តែឯកសាររដ្ឋបាលតែមួយនេះជាចាំបាច់ត្រូវតែបំពេញ។ ទន្ទឹមនេះ ដើម្បីជាភស្តុតាងបញ្ជាក់ពីភាពត្រឹមត្រូវ និងការពិត ឯកសារភ្ជាប់ក៏តម្រូវឲ្យមានដែរ ដូចជាវិក្ក័យបត្រទំនិញ (Invoice) បញ្ជីវេចខ្ចប់ (Packing list) និងឯកសារដឹកជញ្ជូន (Bill of Lading) គឺចាំបាច់

[24] ប្រកាសលេខ ១៤៤៧ សហវ.ប្រក ស្តីពីបទបញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ, ឧបសម្ព័ន្ធ ក

ត្រូវភ្ជាប់ជាមួយ។ ក្រៅពីនេះ ដូចជា អាជ្ញាប័ណ្ណ វិញ្ញាបនបត្រដើមកំណើតទំនិញ លិខិតធានារ៉ាប់រង និងឯកសារផ្សេងៗទៀតក៏តម្រូវឲ្យភ្ជាប់មកជាមួយដែរក្នុងករណីចាំបាច់មួយចំនួន។

ក្រោយពីការដាក់ SAD ជូនដល់មន្ត្រីគយរួចហើយ អ្នកដែលជាម្ចាស់បំពេញ SAD នោះឬអាចហៅបានថាជា ប្រតិវេទករ អាចធ្វើការកែតម្រូវទិន្នន័យរបស់ខ្លួនដែលយល់ថាមានបញ្ហា ឬមានចន្លោះប្រហោងត្រង់ណានោះ អាចធ្វើការកែប្រែបានតែក្នុងថ្ងៃដែលខ្លួនបានចុះបញ្ជីកា និងមុនពេលដែលសមត្ថកិច្ចគយត្រួតពិនិត្យទំនិញជាក់ស្តែងតែប៉ុណ្ណោះ។ ទន្ទឹមនេះ ចំណុចដែលមានផលប៉ះពាល់ដល់ប្រាក់ពន្ធមិនអនុញ្ញាតិឲ្យកែតម្រូវដោយមិនទាន់មានការអនុញ្ញាតិពីថ្នាក់ដឹកនាំអង្គភាពគយនោះទេ ពោលដូចជាបរិមាណទំនិញ និងតម្លៃជាដើម។

មួយវិញទៀត ក្រៅអំពីការប្រកាសនៅក្នុង SAD ការត្រួតពិនិត្យទំនិញជារូបវន្តក៏ត្រូវបានធ្វើឡើងដែរក្នុងករណីមានការសង្ស័យទៅលើការប្រកាស។

**២.១.២.១ បុគ្គលដែលមាននីតិសម្បទា**

- នីតិបុគ្គល ឬ ក្រុមហ៊ុនដែលមានវិញ្ញាប័នប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
- ម្ចាស់ទំនិញ ឬ តំណាង
- ជើងសាគយដែលទទួលស្គាល់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ
- បុគ្គលរបស់ក្រុមហ៊ុនដែលទទួលបានសិទ្ធិស្របច្បាប់

**២.១.២.២ ឯកសារចាំបាច់ដែលត្រូវមាន**

ឯកសារត្រូវភ្ជាប់ជាមួយប្រតិវេទន៍គយ រួមមាន៖

- វិក្កយបត្រ និងបញ្ជីវេចខ្ចប់
- ឯកសារដឹកជញ្ជូន

ក្នុងករណីតម្រូវចាំបាច់

- និវេទន៍ប័ណ្ណ
- អាជ្ញាប័ណ្ណ
- លិខិតអនុញ្ញាត
- វិញ្ញាបនបត្រដើមកំណើតទំនិញ
- វិញ្ញាបនបត្រធានារ៉ាប់រង
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច

### ២.១.២.៣ ភារកិច្ចនិងការទទួលខុសត្រូវរបស់ជើងសាគយ ឬ ប្រតិវេទករ

គិតចាប់ទំនិញហៀបនឹងមកដល់មាត់ច្រកនាំចូលរបស់កម្ពុជា ជើងសាគយ ឬប្រតិវេទករមានភារកិច្ចដូចតទៅ៖

- បញ្ចូលទិន្នន័យប្រតិវេទន៍គយ
- បោះពុម្ពប្រតិវេទន៍គយចុះបញ្ជិការរួចពីប្រព័ន្ធកំព្យូទ័រ (តែករណីចាំបាច់ប៉ុណ្ណោះ) ទម្រង់ជាក្រដាស ទំហំ A4 ចំនួនពីរ (២) ច្បាប់ (ប្រតិវេទន៍គយបោះពុម្ពបានតែក្រោយពេលចុះបញ្ជិការួច)
- យកប្រតិវេទន៍គយដែលចុះបញ្ជិកាបានបោះពុម្ពភ្ជាប់ជាមួយនូវឯកសារយោងចាំបាច់នានាទៅដាក់ ជូនមន្ត្រីគយផ្នែកទទួលការដាក់ឯកសារ (ដាក់ក្នុងថាសដែលបានកំណត់ទុកសម្រាប់ដាក់ឯកសារ) និង ចុះហត្ថលេខាលើប្រតិវេទន៍គយនោះ នៅចំពោះមុខមន្ត្រីគយផ្នែកទទួលការដាក់ឯកសារ
- ប្រសិនបើមន្ត្រីគយទទួលការដាក់ឯកសារមិនទទួលយកប្រតិវេទន៍គយ ត្រូវទំនាក់ទំនងទៅផ្នែកសាកសួរព័ត៌មាន
- ប្រសិនបើមានផ្នែកគ្រប់គ្រងស្កេន និងបើមានការចាំបាច់ត្រូវស្កេន យកច្បាប់ចម្លងប្រតិវេទន៍គយ សម្រាប់ជើងសារ ឬ ប្រតិវេទករ ទៅកាន់កន្លែងស្កេន ដើម្បីស្កេនកុងតឺន័រ
- ប្រសិនបើប្រតិវេទន៍គយតម្រូវឲ្យមានការត្រួតពិនិត្យជារូបវន្តទំនិញ ត្រូវទំនាក់ទំនងទៅប្រធានត្រួតពិនិត្យដើម្បីចាត់ចែងធ្វើការត្រួតពិនិត្យទំនិញជារូបវន្ត
- ប្រសិនបើប្រតិវេទន៍គយត្រូវបានសាកសួរដោយមន្ត្រីគយ ទៅកាន់ផ្នែកសាកសួរព័ត៌មានសម្រាប់ ការសាកសួរ ព័ត៌មានចាំបាច់
- ប្រសិនបើការបង់ប្រាក់ធ្វើឡើងតាមរយៈធនាគារទទួលយកសក្ខីប័ត្របង់ប្រាក់ពីធនាគារមកប្រគល់ឲ្យផ្នែកគណនេយ្យគយ ដើម្បីបញ្ជាក់ការបង់ប្រាក់ទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- ប្រសិនបើការបង់ប្រាក់ដោយផ្ទាល់ដល់គយយកសាច់ប្រាក់ឬ មូលប្បទានប័ត្រមកប្រគល់ ឲ្យផ្នែកគណនេយ្យគយ ដើម្បីបញ្ជាក់ការបង់ប្រាក់ទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- ក្រោយពីការបង់ប្រាក់ពន្ធនិងអាករ ឬក៏ចំពោះទំនិញដែលបានប្រកាសដោយប្រើប្រាស់គណនី បង់ប្រាក់ជាមុន ទទួលយកបង្កាន់ដៃពីបេឡាករគយ និងបន្ទាប់មកទទួលយកបង្កាន់ដៃ ពន្ធយានយន្ត (ប្រសិនបើមាន)និងប័ណ្ណបញ្ចេញទំនិញពីប្រធានគណនេយ្យ
- យកប័ណ្ណដឹកជញ្ជូន ពីមន្ត្រីគយដែលប្រចាំការឃ្លាំង ឬទីលាន និងបន្តបញ្ចេញទំនិញពីឃ្លាំង ឬទីលាន និងនៅច្រកទ្វារចេញ

- ប្រសិនបើមានការសម្រេចនិងអនុញ្ញាតឲ្យធ្វើការបង្វិលសងវិញទាំងស្រុងឬ ភាគខ្លះនូវពន្ធ និងអាករ ដែលបានបង់រួចស្របតាមបទបញ្ញត្តិច្បាប់ជាធរមាន យកឯកសារចាំបាច់នានា រួមមាន សេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច ប្រតិវេទន៍គយ បង្កាន់ដៃពន្ធ អញ្ញត្តិប័ណ្ណ មកប្រគល់ឲ្យផ្នែកគណនេយ្យនិងបេឡាគយ ដើម្បីបញ្ជាក់ការបង្វិលសងវិញនូវពន្ធនិងអាករ ដែលបានបង់ទៅក្នុងប្រព័ន្ធកំព្យូទ័រ។

### ២.១.៣ នីតិវិធីនៃការបញ្ចេញទំនិញពីគយដែលមានលក្ខណៈពាណិជ្ជកម្ម

ក្រោយមកទៀតដោយសារសម័យបច្ចេកវិទ្យាកាន់តែទំនើប ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (ASYCUDA) ត្រូវបានបង្កើត និងដាក់ឲ្យប្រើប្រាស់ដើម្បីឲ្យកាន់តែមានភាពងាយស្រួល និងឈានទៅដល់ការធ្វើការតាមប្រព័ន្ធបច្ចេកវិទ្យា។

ប្រព័ន្ធ ASYCUDA ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីបង្កើនប្រសិទ្ធភាពការងារឲ្យកាន់តែប្រសើរឡើង។ ជាមួយគ្នានេះ ប្រតិវេទន៍គយក៏ត្រូវកែទម្រង់ និងដាក់ឲ្យបំពេញតាមប្រព័ន្ធអេឡិចត្រូនិចផងដែរ។ ហើយនីតិវិធីថ្មីក្នុងការបំពេញបែបបទបញ្ចេញទំនិញពីគយគឺមានលក្ខណៈជាប្រព័ន្ធដែលចាប់ផ្តើមចេញពី ប្រតិវេទន៍ករ បន្ទាប់មកមន្ត្រីគយផ្នែកត្រួតពិនិត្យឯកសារ និងជាបន្តបន្ទាប់រហូតដល់ផ្នែកគណនេយ្យជាផ្នែកចុងក្រោយដើម្បីអនុញ្ញាតឲ្យម្ចាស់ ឬតំណាងម្ចាស់ទំនិញបំពេញកាតព្វកិច្ចពន្ធ និងអាករមុននឹងធ្វើការយកទំនិញចេញពីដែនគយ។

ដូច្នេះជាការចាំបាច់ ការធ្វើការបញ្ចេញទំនិញពីដែនគយនេះ ត្រូវការប្រើប្រាស់នូវប្រព័ន្ធអ៊ីនធឺណែតដើម្បីដំណើរឯកសារ និងបញ្ចប់បែបបទគយ។

**រូបភាពទី៣៖ នីតិវិធីប្រតិវេទន៍គយតាមប្រព័ន្ធ ASYCUDA[25]**




**CUSTOMS DATA CENTER ជាដំណាក់កាលដំបូងនៃដំណើរការប្រតិវេទន៍គយក្នុងប្រព័ន្ធអាស៊ីគូដា៖**

គឺជាបន្ទប់បញ្ចូលទិន្នន័យរបស់ប្រតិវេទន៍ករ (ជើងសារគយ ឬម្ចាស់ទំនិញ ) ។ប្រតិវេទន៍ករត្រូវបញ្ចូលទិន្នន័យនាំចូលក្នុងប្រព័ន្ធ អាស៊ីគូដា ឲ្យបានគ្រប់គ្រាន់និងត្រឹមត្រូវ បន្ទាប់មកត្រូវចុះបញ្ជីកាប្រតិវេទន៍គយនោះ ដោយបោះពុម្ពជា ០២ច្បាប់ ដោយអមជាមួយឯកសារភ្ជាប់(ដូចជា៖វិក្ក័យបត្រ បញ្ជីវេចខ្ចប់ វិក្ក័យបត្រដឹកជញ្ជូន លិខិតអនុញ្ញាត បណ្ណប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ជាដើម) ដាក់ជូនមន្ត្រីគយទទួលបន្ទុកទទួលឯកសារ ។

[25] រូបភាពដកស្រង់ចេញពីវេបសាយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (www.customs.gov.kh/ប្រតិវេទន៍គយ/),ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៧)

FACE VETTING (ប្រើរយៈពេលប្រមាណ ១០នាទី)

មន្ត្រីគយ ទទួលបន្ទុកទទួលប្រតិវេទន៍គយផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ គ្រប់គ្រាន់ និង សុពលភាព នៃឯកសារភ្ជាប់ ជាមួយទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ។ បន្ទាប់មក មន្ត្រីគយទទួលបន្ទុកនឹងបញ្ជាអោយប្រព័ន្ធវាយតម្លៃប្រតិវេទន៍គយដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់ប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធនឹងកំណត់អំពីច្រកប្រតិវេទន៍គយដែលមានច្រកពណ៌ ៤ប្រភេទដូចខាងក្រោម៖

- ច្រកពណ៌បៃតង៖ ជាប្រភេទច្រកល្អបំផុត ហើយមិនទាមទារឲ្យមានការរើទំនិញដើម្បីត្រួតពិនិត្យនោះទេ។ មន្ត្រីគយគ្រាន់តែធ្វើការបញ្ជាក់ពីភាពត្រឹមត្រូវនិងបោះពុម្ពបង្កាន់ដៃពន្ធគយ និងបញ្ចេញទំនិញពីគយជាការស្រេច។ ចំពោះនីតិវិធីនៃការរក្សាប្រតិវេទន៍គយទម្រង់ជាក្រដាសត្រូវបានរក្សាទុកនៅដដែល ដើម្បីធ្វើជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដោយសវនករមានសមត្ថកិច្ច។
- ច្រកពណ៌ខៀវ៖ ជាប្រភេទច្រកពណ៌ដែលមានលក្ខណៈវិនិច្ឆ័យប្រហាក់ប្រហែលគ្នាទៅនឹងច្រកពណ៌បៃតងដោយគ្រាន់តែប្តូរច្រកពណ៌ទៅជា ច្រកបៃតង ធ្វើការបង់ពន្ធអាករនិងបោះពុម្ពបង្កាន់ដៃពន្ធគយ ឯកសារបញ្ចេញទំនិញពីគយជាការស្រេច ។ ចំពោះនីតិវិធីនៃការរក្សាប្រតិវេទន៍គយទម្រង់ជាក្រដាសត្រូវបានរក្សាទុកនៅដដែល ដើម្បីធ្វើជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដោយសវនករមានសមត្ថកិច្ច។
- ច្រកពណ៌លឿង៖ ប្រតិវេទន៍គយដែលស្ថិតក្នុងច្រកពណ៌លឿង ជាប្រភេទប្រតិវេទន៍ស្ថិតក្នុងកម្រិតហានិភ័យមធ្យម ដែលនឹងត្រូវបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឯកសារ និងវាយតំលៃដោយមន្ត្រីគយទទួលបន្ទុកពិនិត្យឯកសារ មុនពេលធ្វើការប្តូរច្រកប្រតិវេទន៍គយទៅកាន់ ច្រកបៃតង បន្ទាប់មកធ្វើការបោះពុម្ពបង្កាន់ដៃពន្ធ និងប័ណ្ណបញ្ចេញទំនិញពីគយ ជូនម្ចាស់ទំនិញ។
- ច្រកពណ៌ក្រហម៖ ប្រតិវេទន៍គយដែលស្ថិតក្នុងច្រកពណ៌ក្រហម ជាប្រភេទប្រតិវេទន៍ស្ថិតក្នុងកម្រិតហានិភ័យខ្ពស់ ដែលនឹងត្រូវធ្វើការត្រួតពិនិត្យរូបវន្តទំនិញជាក់ស្តែងផ្ទៀងផ្ទាត់ជាមួយឯកសារ និង មុនពេលធ្វើការប្តូរច្រកប្រតិវេទន៍គយទៅ **ច្រកបៃតង** បន្ទាប់មកធ្វើការបោះពុម្ពបង្កាន់ដៃពន្ធ និងប័ណ្ណបញ្ចេញទំនិញពីគយជូនម្ចាស់ទំនិញ។

### ក. ការត្រួតពិនិត្យគយ

ទោះបីជាប្រព័ន្ធ ASYCUDA ដែលដាក់ឲ្យដំណើរការប្រតិវេទន៍គយប្រព្រឹត្តទៅងាយស្រួល និងឆាប់រហ័សជាងមុនក៏ដោយ តែការត្រួតពិនិត្យគយក៏នៅតែតម្រូវ និងចាំបាច់ផងដែរ។ ជាការពិត

តាមរយៈឯកសារ អាចបង្ហាញឲ្យឃើញអំពីអត្តសញ្ញាណ ប្រភព និងលំហូរនៃទំនិញ ក៏ដូចជាបំណងនៃការនាំចូល និងពិតមានសំខាន់ៗទាំងឡាយ ប៉ុន្តែការត្រួតពិនិត្យទំនិញជារូបវ័ន្តពិតជាមានសារៈសំខាន់ និងមិនអាចបំភ្លេចចោលបាននោះទេ។ ព័ត៌មានលម្អិតអាចរកឃើញនៅក្នុងឯកសារ តែទំនិញជាក់ស្តែងគឺមានតែការត្រួតពិនិត្យតែប៉ុណ្ណោះ។

ការត្រួតពិនិត្យគយធ្វើឡើងនៅពេលដែលទំនិញចូលមកដល់ដែនគយ ក្នុងគោលបំណងការត្រួតពិនិត្យអនុលោមភាពទំនិញ ឬក្នុងករណីសង្ស័យ ឬមានភាពមិនប្រក្រតី។ មន្ត្រីគយមានសមត្ថកិច្ចមានសិទ្ធិពិនិត្យទំនិញ បើក ឬបញ្ជាឲ្យបើកកញ្ចប់ណាមួយរបស់ម្ចាស់ទំនិញ ដើម្បីយកមកត្រួតពិនិត្យតាមលក្ខខណ្ឌសមស្រប។[26] ការត្រួតពិនិត្យនេះអាចធ្វើឡើងជាភាគក្នុងបំណែកណាមួយសមរម្យ និងយល់ថាគ្រប់គ្រាន់ និងត្រឹមត្រូវ ក្នុងករណីទំនិញផ្ទុកក្នុងកុងតឺន័រ។

ក្នុងករណីដែលមានការសង្ស័យមន្ត្រីគយមានសិទ្ធិសាកសួរ និងឃាត់ទុកបណ្តោះអាសន្ននូវទំនិញទាំងនោះ រួចធ្វើកំណត់ហេតុ និងរង់ចាំការសម្រេចបន្តពីថ្នាក់ដឹកនាំ។ [27] ក្នុងករណីទំនិញមិនជាប់អាយ័ត ជាពិសេសទំនិញដែលមានសុពលភាពខ្លី ឬងាយនឹងបាត់បង់គុណភាពម្ចាស់ទំនិញអាចធ្វើការយកទំនិញចេញបានដោយតម្រូវឲ្យតម្កល់និមុត្តិនាដល់មន្ត្រីគយដែលមានសមត្ថកិច្ច។

**ខ. ការបង់ពន្ធ និងអាករ**

កាតព្វកិច្ចសំខាន់របស់អ្នកនាំចូលក្នុងការបំពេញជូនរដ្ឋ គឺការបង់ពន្ធ និងអាករមុនពេលយកទំនិញចេញពីដែនគយក្នុងគោលបំណងផ្សេងៗរបស់អ្នកនាំចូល។ ដំណើរការប្រព្រឹត្តទៅនៃការបំពេញកាតព្វកិច្ចពន្ធ និងអាករនេះគឺជាដំណាក់កាលចុងក្រោយបង្អស់ នៅពេលដែលការត្រួតពិនិត្យឯកសារ និងការត្រួតពិនិត្យទំនិញជារូបវ័ន្តត្រូវបានផ្ទៀងផ្ទាត់។ ការបង់ពន្ធ និងអាករផ្អែកតាមយថាប្រភេទនៃទំនិញ។ ហើយអត្រាពន្ធ និងអាករគឺយកតាមតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន និងតម្លៃគិតពន្ធគយគឺជាថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដរបស់ភាគីអ្នកទិញ ឬអ្នកនាំចូល។

[26] មាត្រាទី៥៦ នៃច្បាប់ស្តីពីគយព្រះរាជាណាចក្រកម្ពុជា,ជំពូកទី១០ សិទ្ធិអំណាច និងកាតព្វកិច្ច

[27] មាត្រាទី៦៦ នៃច្បាប់ស្តីពីគយព្រះរាជាណាចក្រកម្ពុជា

**រូបភាពទី៨៖ តារាងអត្រាពន្ធនាំចូល(CD) អាករពិសេស(ST) និងអាករលើតម្លៃបន្ថែម (VAT)[28]**

| ល.រ | CD | ST | VAT |
|---|---|---|---|
| 1 | 0% | 0% | 10% |
| 2 | 7% | 5% | - |
| 3 | 15% | 10% | - |
| 4 | 35% | 15% | - |
| 5 | - | 20% | - |
| 6 | - | 25% | - |
| 7 | - | 30% | - |
| 8 | - | 35% | - |
| 9 | - | 40% | - |
| 10 | - | 50% | - |

- អត្រាពន្ធនាំចូលនៅកម្ពុជាមាន ០៤ប្រភេទ
- អត្រាអាករពិសេសនៅកម្ពុជាមាន ១០ប្រភេទ
- អត្រាអាករលើតម្លៃបន្ថែមនៅកម្ពុជាមាន ០១ប្រភេទ

ការបង់ពន្ធ និងអាករនេះអាចធ្វើឡើងដោយបង់ជាសាច់ប្រាក់ដល់គណនេយ្យករ ឬជាមូលប្បទានបត្រក៏បាន។ ហើយការទូទាត់នេះធ្វើឡើងនៅពេលមុនយកទំនិញចេញពីគយ ដោយមិនមានការជំពាក់ បង់រំលោះ ឬជាដំណាក់កាលនោះទេ។

រីឯតម្លៃគិតពន្ធគយ គឺជាតម្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកទិញ។ ជាការចាំបាច់ ការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាគឺជាការទទួលយកតម្លៃគិតពីរោងចក្រផលិតរហូតមកដល់ព្រំដែនកម្ពុជា។ ទន្ទឹមនេះគឺមាន TERM ដែលបានដាក់កំណត់ និងការបញ្ជាក់របស់ម្ចាស់ទំនិញថា ទំនិញទាំងនោះត្រូវបានទូទាត់គិតត្រឹមចំណុចណា។

[28] តារាងពន្ធគយកម្ពុជាឆ្នាំ២០១៧

## រូបភាពទី៥៖ វាក្យស័ព្ទពាណិជ្ជកម្ម[29]

| Incoterm 2010 | Export-Customs declaration | Carriage to port of export | Unloading of truck in port of export | Loading charges in port of export | Carriage (Sea Freight/Air Freight) to port of import | Unloading charges in port of import | Loading on truck in port of import | Carriage to place of destination | Insurance | Import customs clearance | Import taxes |
|---|---|---|---|---|---|---|---|---|---|---|---|
| EXW | Buyer | Buyer | Buyer | Buyer | Buyer | Buyer | Buyer | Buyer | | Buyer | Buyer |
| FCA | Seller | Buyer | Buyer | Buyer | Buyer | Buyer | Buyer | Buyer | | Buyer | Buyer |
| FAS | Seller | Seller | Seller | Buyer | Buyer | Buyer | Buyer | Buyer | | Buyer | Buyer |
| FOB | Seller | Seller | Seller | Seller | Buyer | Buyer | Buyer | Buyer | | Buyer | Buyer |
| CFR | Seller | Seller | Seller | Seller | Seller | Seller | Buyer | Buyer | | Buyer | Buyer |
| CIF | Seller | Seller | Seller | Seller | Seller | Seller | Buyer | Buyer | Seller | Buyer | Buyer |
| CPT | Seller | Seller | Seller | Seller | Seller | Seller | Seller | Seller | | Buyer | Buyer |
| CIP | Seller | Seller | Seller | Seller | Seller | Seller | Seller | Seller | Seller | Buyer | Buyer |
| DAT | Seller | Seller | Seller | Seller | Seller | Seller | Seller | Seller | | Buyer | Buyer |
| DAP | Seller | Seller | Seller | Seller | Seller | Seller | Seller | Seller | | Buyer | Buyer |
| DDP | Seller | Seller | Seller | Seller | Seller | Seller | Seller | Seller | | Seller | Seller |

Allocations of costs of buyer and seller according to Incoterms 2010

ឧទាហរណ៍៖

- EXW = Ex Works គឺមានន័យថាអ្នកទិញអ្នករ៉ាប់រងរាល់ចំណាយទាំងអស់គិតចាប់ពីរោងចក្រផលិត។
- FCA = Free Carrier គឺមានន័យថាអ្នកលក់ជាអ្នកចំណាយក្នុងការដឹកទំនិញចេញពីរោងចក្រផលិត តែបន្ទាប់ពីនោះគឺជាចំណាយរបស់អ្នកទិញ។
- FOB = Free On Board គឺមានន័យថាអ្នកលក់បានចំណាយទៅលើប្រតិបត្តិការគិតចាប់ពីការដឹកជញ្ជូនចេញពីរោងចក្រ, ចំណាយការដឹកជញ្ជូន និងលើកដាក់នៅកំពង់ផែនៅប្រទេសនាំចេញ។ ហើយគិតចាប់ពីការចេញដំណើរពីប្រទេសនាំចេញមកគឺជាបន្ទុករបស់អ្នកទិញ។

សម្រាប់ប្រទេសកម្ពុជា គឺកំណត់យកត្រឹម CIF ដែលមានន័យថាថ្លៃដែលត្រូវយកមកគិតពន្ធគឺគិតចាប់ពីមាត់ច្រកចេញពីរោងចក្រមកដល់ព្រំដែនរបស់ប្រទេសនាំចូល។

[29] វេបសាយhttps://www.google.com.kh/search?q=INCOTERM&source, (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧)

## ២.២ ការនាំចូលទំនិញតាមរូបភាពផ្សេងទៀត

ទំនិញនាំចូលខ្លះទៀត ត្រូវបាននាំចូលមកក្រោមរូបភាពផ្សេងៗ។ ដូចនេះដើម្បីឲ្យដំណើរការនៃការគ្រប់គ្រងនូវទំនិញនាំចូលប្រកបដោយប្រសិទ្ធភាព គេបានបែងចែកទំនិញនាំចូលទៅតាមលក្ខណៈនៃការនាំចូលនោះ ដែលរួមមានជាអាទិ៍ ទំនិញហាមឃាត់និងជាប់កម្រិតកំណត់ ទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ ទំនិញគ្មានការទាមទារ ទំនិញនាំចូលគ្មានលក្ខណៈជាពាណិជ្ជកម្ម និងនីតិវិធីគយពិសេសដែលអនុវត្តសម្រាប់តែក្នុងតំបន់សេដ្ឋកិច្ចពិសេសជាដើម។

### ២.២.១ ទំនិញហាមឃាត់ និងជាប់កម្រិតកំណត់

ទំនិញហាមឃាត់ ឬទំនិញជាប់អាយ័ត និងទំនិញជាប់កម្រិតកំណត់ គឺជាប្រភេទទំនិញដែលមានហានិភ័យខ្ពស់ ដែលស្ថិតនៅក្រោមល័ក្ខខណ្ឌនៃការនាំចេញ ឬនាំចូល។ ទំនិញជាប់អាយ័ត និងទំនិញជាប់កម្រិតកំណត់រួមមានមុខទំនិញចំនួន១៥៣៧[30] បន្ទាត់អត្រាពន្ធនៃតារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ។ ឧទាហរណ៍ៈ សារធាតុគីមី ថ្នាំពេទ្យ ឧស្ម័ន រថយន្តចង្កូតស្តាំ ទំនិញល្មើសច្បាប់កម្មសិទ្ធិបញ្ញាជាដើម។ ទោះបីជាទំនិញជាប់អាយ័ត និងទំនិញជាប់កម្រិតកំណត់ជាទំនិញដែលហាមឃាត់នាំចូលក៏ពិតមែនតែវានៅតែមានករណីដែលធ្វើការនាំចូលបានតាមលក្ខខណ្ឌកំណត់។

**ក. គោលបំណង**

ថ្វីត្បិតតែវាជាទំនិញដែលមានហានិភ័យខ្ពស់ក៏ដោយ ក៏នៅតែត្រូវបាននាំចូលបានដែរតែការអនុញ្ញាតឲ្យនាំចូលនោះគឺមានគោលបំណងនាំចូលច្បាស់លាស់គឺៈ

- ដើម្បីរក្សាសន្តិសុខប្រទេសជាតិ
- ដើម្បីថែរក្សាសណ្តាប់ធ្នាប់សង្គម សុជីវធម៌ និងសីលធម៌សាធារណៈ
- ការពារដល់សុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិ
- អភិរក្សធនធានធម្មជាតិ ការពារដល់សម្បត្តិបេតិកភណ្ឌជាតិ
- តម្រូវទៅតាមច្បាប់បញ្ញត្តិនានានៃច្បាប់ណាមួយជាធរមាននៃព្រះរាជាណាចក្រកម្ពុជាដែលតម្រូវឲ្យនាំនូវទំនិញប្រភេទនេះចូលមក
- ដើម្បីបំពេញនូវកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិជាដើម។

**ខ. ការអនុញ្ញាតឲ្យនាំចូលទំនិញហាមឃាត់ និងជាប់កម្រិតកំណត់**

[30] អនុក្រឹត្យលេខៈ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

ទំនិញជាប់អាយ៉តទាំងអស់អាចធ្វើការនាំចូលបានលុះត្រាតែបានគោរពនូវល័ក្ខខណ្ឌដូចខាងក្រោម៖

- មានការអនុញ្ញាតនាំចូល ដោយមានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រផ្សេងទៀត ពីអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដូចជា ក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចពាក់ព័ន្ធស្របតាមច្បាប់ ឬបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។
- សម្ភារៈ ឬឧបករណ៍បច្ចេកទេសសម្រាប់ដាក់ឲ្យប្រើប្រាស់លើការហោះហើរ ប៉ុន្តែត្រូវតែមានការឯកភាពពីរដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល។
- ទំនិញនាំចូលត្រូវគោរពតាមស្តង់ដារឧស្សាហកម្មកម្ពុជា និងវិធានគុណភាព និងសុវត្ថិភាព
- ករណីនាំចូលនូវឧបករណ៍ត្រជាក់ រឺឧបករណ៍ផ្សេងទៀតដែលប្រើប្រាស់នូវសារធាតុដែលបំផ្លាញដល់ស្រទាប់អូហ្សូន អាចនាំចូលបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងបរិស្ថាន
- ក្នុងករណីទំនិញជាប់អាយ៉តស្ថិតនៅលេខសម្គាល់ប្រព្រឹត្តិកម្មលេខ(4) និង(6)មិនអាចធ្វើការនាំចូលបានជាដាច់ខាតទោះមានលិខិតបញ្ជាក់ពីស្ថាប័នណាក៏ដោយ

**គ. លេខសម្គាល់ប្រព្រឹត្តកម្ម៖**

(1) ត្រូវបំពេញបែបបទនាំចេញ-នាំចូលតាមនីតិវិធីជាធរមាន ដោយគ្រាន់តែតម្រូវឲ្យតម្កល់ឯកសាររដ្ឋបាលតែមួយ( Single Administrative Document – SAD) នៅពេលបំពេញបែបបទមាត់ច្រក់ចូល ព្រមទាំងឯកសារភ្ជាប់ផ្សេងទៀតដូចជា វិក័យប័ត្រពាណិជ្ជកម្ម ឯកសារដឹកជញ្ជូន បញ្ជីវេចខ្ចប់ និងឯកសារចាំបាច់ផ្សេងៗទៀតតាមការតម្រូវ លើកលែងតែទំនិញដែលស្ថិតនៅក្រោមការក្រោមរបរលើកលែង ឬព្យូរទាំងស្រុង ឬជាភាគនៃពន្ធ និងអាករ។ ឧទាពហរណ៍ ការនាំចូលក្រណាត់ជាដើម។

(2) ត្រូវមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតឲ្យនាំចូល លិខិតគតិយុត្តិប្រហាក់ប្រហែលដែលចេញពីក្រសួង ស្ថាប័ន ឬអង្គភាពដែលមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ ឧទាហរណ៍៖ សារធាតុក្លរ អ៊ីយ៉ូត អ៊ីដ្រូសែន អុកស៊ីសែន...។

(3) ត្រូវមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតឲ្យនាំចូល លិខិតគតិយុត្តិប្រហាក់ប្រហែលពីក្រសួង ស្ថាប័ន ឬអង្គភាពជំនាញដែលមានសមត្ថកិច្ចនៃក្រសួង ឬស្ថាប័ននេះ។ ឧទាហរណ៍៖ ផ្តៅ ឫស្សី កាំជ្រួច...។

(4) ត្រូវបានហាមឃាត់ដាច់ខាតសម្រាប់ការនាំចូល។ ឧទាហរណ៍៖ កាកសំណល់ និង កំទេចអាលុយមីញ៉ូម មេកានិច គីមី....។

(5) ត្រូវបានហាមឃាត់ដាច់ខាតសម្រាប់ការនាំចេញ។

(6) ត្រូវបានហាមឃាត់ដាច់ខាតទាំងការនាំចេញ និងនាំចូល

(7) ត្រូវមានវិញ្ញាបនបត្របញ្ជាក់សុខភាពសត្វតាមការតម្រូវរបស់ប្រទេសនាំចូល។ ឧទាហរណ៍ ៖ប្រភេទសាច់សត្វ បក្សី ...។

(8) ត្រូវមានវិញ្ញាបនបត្រភូតគាមអនាម័យតាមការតម្រូវរបស់ប្រទេសនាំចូល។ ឧទាហរណ៍៖ ដើមផ្កាអរគីដេសម្រាប់ដាំ ផ្សិតឈើ...។

(9) ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផលរបស់ប្រទេសអ្នកនាំចេញ។ ឧទាហរណ៍៖ ត្រីទឹកប្រៃ ត្រីទឹកសាប ពូជត្រីជាដើម។

### ២.២.២ ទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ

យោងតាមប្រកាសលេខ១០៥ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ បានធ្វើការកំណត់ប្រភេទទំនិញទាំងនេះដោយកំណត់ដូចខាងក្រោម៖

- ទំនិញដែលនាំចូលសម្រាប់សកម្មភាពការទូត ឬកុងស៊ុលបរទេស អង្គការអន្តជាតិ និងភ្នាក់ងារសហប្រតិបត្តិការ ហើយត្រូវយកទៅវិញនៅពេលសកម្មភាពពួកគេត្រូវបញ្ចប់ ហើយមិនអនុញ្ញាតឲ្យលក់ ផ្ទេរ បង្វិលទៅប្រើប្រាស់អ្វីផ្សេងពីគម្យដ្ឋានដែលបានអនុគ្រោះ ឬបំផ្លាញចោយដោយកគ្មានអនុញ្ញាតពីរដ្ឋបាលគយ។
- ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកនៃការទូត ឬកុងស៊ុល អង្គការអន្តរជាតិនានាផ្សេងទៀត
- ទំនិញដែលមានដើមកំណើតពីកម្ពុជា ឬទំនិញដែលនាំចូលដែលបានបង់ពន្ធ និងអាករួចនៅពេលនាំចេញទៅក្រៅមុនពេលកែច្នៃ
- ទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករក្រោមបទបញ្ញត្តិនៃច្បាប់ផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា

- ទំនិញនាំចូលក្រោមរូបភាពជាអំណោយមនុស្សធម៌ដើម្បីជួយដល់ការផ្នែកស្រាវជ្រាវ ក្នុងគោលបំណងវិទ្យាសាស្ត្រ ទំនិញគំរូ និងទំនិញតាំងពិព័រណ៍ដែលគ្មានតម្លៃពាណិជ្ជកម្ម

### ២.២.៣ ការគ្រប់គ្រងទំនិញគ្មានការទាមទារ

ទំនិញគ្មានការទាមទារគឺជាប្រភេទទំនិញដែលមិនត្រូវបានអនុញ្ញាតឲ្យមានការយកទៅវិញហើយ ទំនិញទាំងនេះជាប្រភេទទំនិញដែល ៖

- ទំនិញដែលបានរក្សាទុកក្នុងឃ្លាំងរបស់អគរ ដែលហួសពេលកំណត់
- ទំនិញដែលបានផ្ញើរតាមប្រៃសណីយ៍ ដោយពុំមានអ្នកមកទទួលយក ហើយពុំអាចធ្វើការផ្ញើត្រលប់ទៅវិញបាន
- ទំនិញដែលមានសរសេរបោះបង់ចោលជាលាយល័ក្ខអក្សរនៅកន្លែងបញ្ចេញទំនិញពីគយ

ក្នុងករណីដែលម្ចាស់ទំនិញ ត្រូវបានស្គាល់រដ្ឋបាលគយនឹងធ្វើការជូនដំណឹងជាបន្ទាន់ដល់ពួកគាត់ ហើយប្រសិនបើមិនមានការមកយកទេក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង ទំនិញទាំងនោះនឹងត្រូវបានដាក់លក់ដោយដេញថ្លៃជាសាធារណៈដោយរដ្ឋបាលគយ។ ទំនិញគ្មានការទាមទារទាំងនេះនឹងត្រូវអនុញ្ញាតឲ្យយកចេញពីគយបាន ប្រសិនមានការទាមទារក្នុងកំឡុងពេលកំណត់នោះ ដោយត្រូវបង់ពន្ធ អាករ កម្រៃផ្សេងៗ ទោសទណ្ឌនានា ព្រមទាំងល័ក្ខខ័ណ្ឌកម្រិតកំណត់ផ្សេងៗត្រូវបានបំពេញរួចរាល់។ បន្ថែមពីនេះទៀត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិចេញប្រកាសពីទំនិញគ្មានការទាមទារត្រូវបានបំផ្លាញចោល ការដាក់លក់ដេញថ្លៃ រឺត្រូវបោះបង់ចោល ឬឲ្យយកទៅប្រើប្រាស់ជាប្រយោជន៍សាធារណៈក្នុងករណីរកម្ចាស់មិនឃើញ។ ចំណែកឯការកំណត់ថ្លៃចំពោះការដាក់លក់ដេញថ្លៃ អគ្គនាយកដ្ឋានគយនិងរដ្ឋាករជាអ្នកកំណត់ថ្លៃអប្បបរមា ប៉ុន្តែបើទំនិញនេះមិនត្រូវបានលក់ក្នុងតម្លៃនេះទេ អគ្គនាយកដ្ឋានគយនិងរដ្ឋាករអាចសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបោះបង់ចោល ឬទុកប្រើប្រាស់ជាប្រយោជន៍សារធាណៈ។

### ២.២.៤ នីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZ)

ទំនិញដែលនាំចូលក្នុងតំបន់សេដ្ឋកិច្ចពិសេសត្រូវបានលើកលែងពន្ធ និងអាករ។ ទំនិញទាំងនោះរួមមាន សម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ ធាតុចូលផលិតកម្ម និងត្រូវបានលើកទឹកចិត្តដល់អ្នកវិនិយោគ ដែលនាំចូលមកក្នុងគោលបំណងច្បាស់លាស់ដើម្បីចូលរួមចំនែកអភិវឌ្ឍន៍ជាតិ។

ដំណើរការប្រព្រឹត្តទៅនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ គឺអ្នកវិនិយោគត្រូវរៀបចំបញ្ជីទំនិញដែលខ្លួននាំចូលនោះដាក់ជូនរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសពិនិត្យ។ ទន្ទឹមនេះការពិនិត្យ

និងសម្រេចគឺធ្វើការផ្តល់ជូននៅនឹងកន្លែងតែម្តង។ បន្ទាប់មករដ្ឋបាល SEZ ធ្វើការរាយការណ៍ជូនដល់គណៈកម្មាធិការតំបន់ SEZ និងស្ថាប័នគ្រប់គ្រងដើម្បីជ្រាបជាព័ត៌មាន។

រីឯមន្ត្រីគយមានសមត្ថកិច្ចមានតួនាទីកំណត់តម្រាយផ្លូវស្របច្បាប់ និងរយៈពេលសមស្របមួយដល់ទំនិញវិនិយោគទាំងនោះដើម្បីធ្វើដំណើរចេញពីមាត់ច្រកនាំចូល ទៅកាន់តំបន់សេដ្ឋកិច្ចពិសេស។ លើសពីនេះទៀត អ្នកនាំចូលត្រូវបង្ហាញ និងផ្តល់ជូនដល់មន្ត្រីគយមានសមត្ថកិច្ចនៅមាត់ច្រកផ្លូវការដែលខ្លួននាំចូលនោះ នូវឯកសារចម្លងដែលពាក់ព័ន្ធនឹងទំនិញឆ្លងកាត់ទៅ SEZ។ ឯកសារដែលត្រូវភ្ជាប់រួមមាន វិក្កយបត្រ ឯកសារដឹកជញ្ជូន និងឯកសារផ្សេងទៀតដែលអាចបង្ហាញបាននូវទិន្នន័យទំនិញ ឬថាទំនិញនេះត្រូវដឹកជញ្ជូនទៅ SEZ ដែលនៅជិតមាត់ច្រកនាំចូលនោះបំផុត។

នៅពេលដែលទៅដល់ទីតាំង SEZ មន្ត្រីគយមានសមត្ថកិច្ច ត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណដែលពាក់ព័ន្ធនឹងការនាំចូលនេះឲ្យមានភាពស៊ីចង្វាក់គ្នារួចហើយអាចឲ្យគេចូលទៅក្នុង និងចាត់ចែងតាមការងាររបស់ពួកគេ។ អ្នកនាំចូលអាចចាត់ចែងរើទំនិញរបស់ខ្លួន ដើម្បីប្រើប្រាស់ ឬកែច្នៃតាមតម្រូវការនៃការវិនិយោគ របស់ខ្លួន ដោយពុំចាំបាច់មានវត្តមានមន្ត្រីគយមានសមត្ថកិច្ចឡើយ លើកលែងតែមានការតម្រូវ ជាពិសេស ពីមន្ត្រីទាំងនេះ ដើម្បីធ្វើការពិនិត្យរូបវន្តលើទំនិញ។

**រូបភាពទី៦៖ លំហូរនៃនីតិវិធីការនាំចូលទំនិញមក SEZ**




១. អ្នកវិនិយោគត្រូវដាក់ពាក្យស្នើសុំ និងត្រូវបញ្ជាក់ពីវត្ថុបំណងឲ្យបានច្បាស់ ព្រមទាំងត្រូវភ្ជាប់នូវឯកសារពាក់ព័ន្ធទាំងឡាយ ក្នុងការស្នើសុំនាំចូលនូវទំនិញវិនិយោគទាំងនោះ។

២. បន្ទាប់មកត្រូវដាក់ឯកសារទាំងអស់នោះជូនដល់មន្ត្រីគយប្រចាំ SEZ ដើម្បីពិនិត្យ និងបញ្ជាក់ពីការឯកភាពដោយធ្វើការបោះត្រា។ មន្ត្រីគយមានសមត្ថកិច្ចនៅទីនោះត្រូវបញ្ចប់ឯកសារក្នុងរយៈពេល ២ម៉ោងធ្វើការយ៉ាងយូរ។

៣. នៅពេលដែលទំនិញមកដល់មាត់ច្រកនាំចូលនោះ មន្ត្រីគយដែលនៅមាត់ច្រកមានកាតព្វកិច្ចត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់អនុលោមភាពលើឯកសារ និងក្នុងករណីសង្ស័យត្រូវធ្វើការត្រួតពិនិត្យទំនិញជារូបវន្ត ដែលប្រតិបត្តិការនេះត្រូវធ្វើក្នុងរយៈ២ម៉ោងយ៉ាងយូរ។ ដូច្នេះក្នុងការត្រួតពិនិត្យ អាចមានមន្ត្រីគយចូលរួមរហូតដល់ ៣នាក់ រួមជាមួយនឹងម្ចាស់ ឬតំណាងម្ចាស់ទំនិញ ដើម្បីឆាប់បញ្ចប់បែបបទ។ ក្នុងនោះដែរ មន្ត្រីគយត្រូវបញ្ជាក់ពីតម្រាយផ្លូវដែលអនុញ្ញាតឲ្យដឹកទំនិញនោះនាំចូលមកដល់គោលដៅ (SEZ) និងប៉ាន់ស្មានពីរយៈពេលដែលធ្វើដំណើរ។

៤. មន្ត្រីគយនៅ SEZ មានតួនាទីពិនិត្យមើលលើឯកសារម្តងទៀត ហើយបើយល់ថាគ្មានបញ្ហា និងគ្មានការសង្ស័យ គឺត្រូវអនុញ្ញាតឲ្យទំនិញនោះចូលក្នុងតំបន់ SEZ និងត្រូវរក្សាទុកឯកសារដើម្បីតម្កល់។

### ២.២.៥ ទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម

ការនាំចូលទំនិញគ្មានលក្ខណៈពាណិជ្ជកម្មនេះមានច្រើនរូបភាពផ្សេងៗទៀត ដូចជា

**១. <u>ទំនិញនាំចូលម្តងម្កាលៈ</u>** ជាទំនិញរបស់ម្ចាស់ផ្ទាល់ដែលធ្វើការនាំចូលពីប្រទេសក្រៅមកក្នុងគោលបំណងដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន។ ទំនិញប្រភេទនេះប្រសិនបើជាទំនិញថ្មី និងមានតម្លៃថ្លៃដែលលើសពីការអនុគ្រោះ គឺតម្រូវឲ្យធ្វើការបង់ពន្ធនិងអាករ តាមច្បាប់ជាធរមាន ដោយតម្រូវឲ្យបូកថែម ៥០%នៃតម្លៃពិតប្រាកដ។

**២.<u>ទំនិញរបស់អ្នកដំណើរៈ</u>** ប្រសិនបើទំនិញទាងអស់នោះជាផ្នែកសម្ភារៈរបស់អ្នកដំណើរដែលនៅជាប់នឹងខ្លួនសម្រាប់តែការប្រើប្រាស់ក្នុងបរិមាណមួយសមស្រប ទំនិញទាំងនោះអាចជាកម្មវត្ថុនៃការត្រួតពិនិត្យ តែមិនតម្រូវឲ្យធ្វើការបង់ពន្ធ និងអាករទេ។ តែក្នុងករណីដែលរកឃើញថា ទំនិញទាំងនោះលើសពីការប្រើប្រាស់សម្រាប់ការធ្វើដំណើរ ឬមានបំណងក្នុងការទិញយកទៅលក់ ឬក្នុងគោលបំណងគេចវេសពន្ធ ទំនិញទាំងនោះត្រូវជាកម្មវត្ថុនៃការឃាត់ទុកបណ្តោះអាសន្ន និងរង់ចាំការបង់ពន្ធ អាករ និងពិន័យផ្សេងៗ។

**៣.<u>ទំនិញរបស់បេសកម្មការទូតៈ</u>** ទំនិញប្រភេទនេះ ជាប្រភេទទំនិញរបស់អ្នកដំណើរដែលមានបេសកម្មផ្លូវការ ដែលកាតព្វកិច្ចពន្ធ និងអាករត្រូវបានលើកលែង។

**៤. <u>ទំនិញជាអំណោយៈ</u>** ប្រសិនបើទំនិញទាំងនោះបានបញ្ជាក់ពីគោលបំណងច្បាស់លាស់ព្រមទាំងមានឯកសារគាំទ្រត្រឹមត្រូវ ថាទំនិញទាំងនោះជាអំណោយ កាតព្វកិច្ចពន្ធ និងអាករ

នឹងត្រូវបានលើកលែង។ ករណីនេះភាគច្រើនជួបប្រទះទៅលើអង្គការមិនមែនរដ្ឋាភិបាលនានា ដែលនាំចូលមកក្នុងគោលបំណងទ្រទ្រង់អង្គការ ឬជាផ្នែកនៃការអភិវឌ្ឍជាតិ។

## ២.៣ ទោសទណ្ឌ

ជាការពិត ប្រទេសណា ក៏ដូចប្រទេសណាដែរ ដើម្បីទប់ស្កាត់អំពើអសកម្មនានា និងការគេចវេសពន្ធនិងអាករ រដ្ឋាភិបាលបានបង្កើតឲ្យមានច្បាប់ក្នុងការដាក់ទោសទណ្ឌទៅលើអ្នកដែលប្រព្រឹត្តល្មើស។ ក្នុងនោះច្បាប់បានកំណត់ថា៖

- ប្រសិនបើជនណាខកខានក្នុងការប្រកាស និងបំពេញប្រតិវេទន៍គយឲ្យបានគ្រប់ជ្រុងជ្រោយ ហើយមិនមានប៉ះពាល់ដល់ប្រាក់ពន្ធ និងអាករ ត្រូវរងការពិន័យជាប្រាក់ពី ១០០.០០០រៀល ទៅ ៥០០.០០០រៀល។
- ប្រសិនបើជនណាខកខានក្នុងការប្រកាស និងបំពេញប្រតិវេទន៍គយឲ្យបានគ្រប់ជ្រុងជ្រោយ ហើយប៉ះពាល់ដល់ប្រាក់ពន្ធ និងអាករ តែជាទំនិញមិនជាប់អាយ័តនោះ ត្រូវពិន័យ ១ដង រហូតដល់៣ដង នៃប្រាក់ពន្ធ និងអាករដែលបានគេចវេស និងត្រូវទទួលទោសទណ្ឌតាមផ្លូវតុលាការ ព្រមទាំងឃាត់ទុកបណ្តោះអាសន្ននូវទំនិញ និងដាក់ពន្ធធនាគារពី ១ខែ ទៅ ១ឆ្នាំ។
- ប្រសិនបើជនណាមានបំណង ឬប៉ុនប៉ងធ្វើឲ្យមានការរាំងស្ទះដល់ការត្រួតពិនិត្យ និងឆែកឆេររបស់មន្ត្រីគយ ឬធ្វើឲ្យមានភាពយឺតយ៉ាវ បង្កជាឧបសគ្គ និងមិនស្តាប់តាមបញ្ជារបស់មន្ត្រីគយមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រៀល ទៅ ៥.០០០.០០០រៀល និងផ្តន្ទាទោសដាក់ពន្ធធនាគារពី ១ខែ ដល់ ៦ខែ។
- ប្រសិនបើជនណាដែលល្មើស ឬមានបំណងរំលោភបំពានចំពោះទំនិញដែលជាប់អាយ័ត ត្រូវផ្តន្ទាទោសពិន័យរហូតដល់ ៣ដងនៃតម្លៃទំនិញ ព្រមទាំងឃាត់ទុកបណ្តោះអាសន្ននូវទំនិញ និងដាក់ពន្ធធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ ឬទោសណាមួយនៃទោសទាំងពីរ។

# ជំពូកទី៣
# កំណែទម្រង់
# របស់រដ្ឋាភិបាលពាក់ព័ន្ធនឹង
# ការនាំចូលទំនិញ

# ជំពូកទី៣

# កំណែទម្រង់របស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការនាំចូលទំនិញ

ដើម្បីឲ្យមានភាពស្របគ្នាទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យា និងការប្រែក្លាយខ្លួនឲ្យទៅជាប្រភេទការិយាល័យទំនើប (smart office) ក្នុងការបំពេញកិច្ចការ ពោលគឺការគ្រប់គ្រង និងបំពាក់ឧបករណ៍បច្ចេកវិទ្យាទំនើបក្នុងការតាមដានរាល់សកម្មភាពការងារពិតជាមានសារៈសំខាន់។ ហេតុដូច្នេះហើយទើបរដ្ឋាភិបាលបានខិតខំប្រឹងប្រែង កែលម្អរបៀបនៃការគ្រប់គ្រង និងការកែសម្រួលនីតិវិធីឲ្យកាន់តែមានភាពងាយស្រួល និងមានប្រសិទ្ធភាពជាងមុន។ លើសពីនេះទៀត ការធ្វើពាណិជ្ជកម្មអន្តរជាតិរវាងប្រទេស និងប្រទេសនាពេលបច្ចុប្បន្ននេះ ពោលការនាំចេញទំនិញ ឬសេវា ពីប្រទេសមួយ ដែលវាជាការនាំចូលរបស់ប្រទេសមួយទៀតនោះ មានការកើនឡើងជាលំដាប់គួរឲ្យកត់សម្គាល់ ដែលវាផ្តល់ទាំងផលវិជ្ជមាន និងអវិជ្ជមាន ដែលជាហេតុធ្វើឲ្យត្រូវមានការរឹតបន្តឹងទៅលើជនទាំងឡាយណាដែលប្រព្រឹត្តអំពើល្មើស ឬសកម្មភាពមិនប្រក្រតីនានា និងបង្កើតយន្តការលើកទឹកចិត្តដល់ធុរជនល្អ ស្មោះត្រង់ និងគោរពច្បាប់របស់ប្រទេសផងដែរ។

## ៣.១ កំណែទម្រង់របស់រដ្ឋាភិបាលទៅលើនីតិវិធីនាំចូល

ជាជំហានដំបូងនៃការធ្វើកំណែទម្រង់ រដ្ឋាភិបាលបានគិតគូរដល់អ្នកនាំចូលទាំងឡាយមានភាពលំបាក និងស្មុគស្មាញច្រើនក្នុងការនាំចូលទំនិញមកកម្ពុជា។ ហេតុដូច្នេះហើយ ទើបបង្កើតជាយន្តការ និងការកែសម្រួលនីតិវិធីមួយចំនួនឲ្យមានភាពធូរស្រាលជាងមុនដូចខាងក្រោម:

### ៣.១.១ កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

ដើម្បីឆ្លើយតបទៅនឹងការរីចម្រើន និងការដើរទៅមុខនៃវិស័យផ្សេងៗទៀតជាច្រើនរបស់ប្រទេសកម្ពុជារដ្ឋាភិបាលបានគិតគូរយ៉ាងខ្លាំង និងរិះរកគ្រប់មធ្យោបាយបង្កើតជាយន្តការក្នុងការសម្រួលពាណិជ្ជកម្មជាអតិបរមា និងព្យាយាមកាត់បន្ថយនូវរបាំងផ្សេងៗតាមលទ្ធភាពក្នុងន័យជួយសម្រួលដល់ប្រជាជនក្នុងប្រទេស ក៏ដូចជាការពារទប់ស្កាត់ និងរក្សាលំនឹងរបស់សេដ្ឋកិច្ចជាតិផងដែរ។ ក្នុងន័យនេះ ថ្នាក់ដឹកនាំបានបង្កើតជាយន្តការ ធ្វើកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីជួយដល់ពាណិជ្ជករ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងឡាយតាមរយៈការគ្រប់គ្រងហានិភ័យ។ ដំណើរការនៃការប្រព្រឹត្តទៅមានដូចខាងក្រោមៈ

១. ជ្រើសរើសសូចនាករហានិភ័យ (risk indicators) ដើម្បីយកមកធ្វើការវិភាគ និងពិភាក្សាស៊ីជម្រៅ។ សូចនាករទាំងនោះបង្កើតឡើងក្នុងគោលបំណងដើម្បីអាចឲ្យមានជាមូលដ្ឋានក្នុង

ការកំនត់នូវកម្រិតហានិភ័យមកធ្វើការវាយតម្លៃ។ និតិបុគ្គលបីប្រភេទដែលត្រូវកំណត់កម្រិតនៃហានិភ័យនេះ គឺកម្រិតហានិភ័យខ្ពស់ កម្រិតហានិភ័យមធ្យម និងកម្រិតហានិភ័យទាប។

២. ការវាយតម្លៃ និងកំណត់កម្រិតហានិភ័យទៅតាមការណែនាំ ដោយធ្វើការវាយតម្លៃបានផ្អែកលើការផ្តល់ពិន្ទុ ដែលបានគណនាដោយប្រព័ន្ធកំណត់ប្រភេទបុគ្គល។

៣. តម្រូវឲ្យធុរជន ឬនិតិបុគ្គលប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច និងផ្តល់ព័ត៌មានចាំបាច់ ដែលតម្រូវឲ្យមាននៅក្នុងប្រព័ន្ធវាយតម្លៃ។

៤. ប្រសិនបើមានពិតមានពីប្រភពដែលអាចជឿជាក់បាន រដ្ឋបាលគយកម្ពុជា វាយតម្លៃ និងពិចារណាឡើងវិញនូវកម្រិតហានិភ័យទាំងឡាយ។

**រូបភាពទី៧៖ កម្រិតពិន្ទុក្នុងការចាត់ថ្នាក់ហានិភ័យទាក់ទងនឹងការនាំចូល**

| **ពិន្ទុ** | ក្រោម 20 | 20 – 40 | 40 - 60 | 60 - 80 | 80 ឡើង |
|---|---|---|---|---|---|
| **កម្រិតហានិភ័យ** | ល្អ | ល្អបង្គួរ | មធ្យម(ខ្ពស់) | មធ្យម | ទាប |

**រូបភាពទី៨៖ ដំណើរការនៃការផ្តល់ពិន្ទុដល់ធុរជន[31]**




[31] សារាចរណែនាំលេខ០០៧សហវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

ដើម្បីបង្កភាពងាយស្រួលបន្ថែមទៀតដល់អ្នកនាំចូល និងអ្នកពាក់ព័ន្ធទាំងឡាយ រដ្ឋាភិបាលបានបង្កើតនីតិវិធីមួយចំនួនទៀតដើម្បីឲ្យមន្ត្រីគយអនុវត្តមានដូចតទៅ៖

១. ជម្រុញការធ្វើការឲ្យបានកាន់តែឆាប់រហ័ស ដោយក្នុងការបញ្ជាក់ការបំពេញបែបបទបញ្ចេញទំនិញពីគយគឺមិនឲ្យលើសពីមួយថ្ងៃនោះទេ។ ប្រសិនបើឯកសារដាក់ជូនមន្ត្រីគយមានសមត្ថកិច្ចមុនម៉ោង ប្រាំបួនព្រឹក ត្រូវធ្វើការបញ្ចប់នៅក្នុងថ្ងៃដដែល។ ហើយប្រសិនបើឯកសារដាក់ក្រោយម៉ោងប្រាំបួនព្រឹក បែបបទនេះត្រូវបញ្ចប់យ៉ាងយូរនៅថ្ងៃធ្វើការបន្ទាប់។

២. ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងឲ្យបានទូលំទូលាយដល់វិស័យឯកជនដែលមានការពាក់ព័ន្ធឲ្យបានដឹង និងយល់អំពីករណីនេះ។

៣. ការឃាត់ និងត្រួតពិនិត្យផែកឆេរទំនិញនៅតាមដងផ្លូវត្រូវធ្វើឡើងក្នុងករណីមានការសង្ស័យតែប៉ុណ្ណោះ ដោយព្យាយាមកុំឲ្យមានភាពយឺតយ៉ាវដល់ម្ចាស់ ឬការដឹកជញ្ជូនទំនិញ។ ក្នុងនោះដែរ ការត្រួតពិនិត្យ មិនគួរធ្វើឲ្យលើស ២% នៃចំនួនមធ្យោបាយដឹកជញ្ជូនទំនិញ និងមិនត្រូវបង្កការលំបាក និងយឺតយ៉ាវដល់ធុរជនត្រឹមត្រូវនោះទេ។ ក្នុងករណីមានការសង្ស័យទើបត្រូវធ្វើការត្រួតពិនិត្យជាបន្តបន្ទាប់។

៤. រាល់ឯកសារដែលចារបានបញ្ជាក់ ឬផ្ទៀងផ្ទាត់ពី GDCE រួច សម្រាប់ការអនុវត្តការបំពេញបែបបទគយនៅអង្គភាពនានាតាមមាត់ច្រកព្រំដែន ឬការិយាល័យផ្សេងទៀតតាមការកំណត់ ពុំតម្រូវឲ្យធ្វើការស្នើសុំចារ ឬបញ្ជាក់នៅតាមសាខាគយ និងរដ្ឋាករពាក់ព័ន្ធទៀតនោះទេ។

៥. សម្រាប់ការនាំចូល ធាតុចូលផ្សេងៗរបស់ខាងវិនិយោគកាត់ដេរ និងវិនិយោគិនក្នុង SEZ ក្រោមប្រព័ន្ធមេ ដែលមានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ចនានា តម្លៃទំនិញនាពេលបំពេញបែបបទសុំនាំចូល ឬបំពេញបែបបទបញ្ចេញទំនិញពីគយ ត្រូវឯកភាពជាបណ្ដោះអាសន្នទៅតាម invoice ដែលបានប្រកាស និងទុកជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ៣.២ យន្តការលើកទឹកចិត្តធុរជនមានអនុលោមភាពខ្ពស់

រាជរដ្ឋាភិបាល តែងគិតគូរដល់ប្រជាជនក៏ដូចជាធុរជនទាំងឡាយក្នុងការប្រកបអាជីវកម្មរបស់ខ្លួនដើម្បីឲ្យមានភាពងាយស្រួលជាងមុន និងសម្រាលបន្ទុកនានាផងដែរ។ ទន្ទឹមនឹងការបង្កើតឲ្យមានច្បាប់ដើម្បីរក្សាសណ្ដាប់ធ្នាប់ ក៏ដូចជាតម្លាភាពនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន រដ្ឋាភិបាលក៏បានរក្សាភាពទន់ភ្លន់ និងលើកទឹកចិត្តដល់ធុរជនទាំងឡាយណាដែលគោរពច្បាប់ និងស្មោះត្រង់

ផងដែរ ហេតុដូច្នេះហើយ ទើបបង្កើតឲ្យមានយន្តការលើកទឹកចិត្តធុរជនមានអនុលោមភាពខ្ពស់នេះឡើង។ កម្មវិធីនេះចាប់ផ្តើមបង្កើតឡើងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤។[32]

### ៣.២.១ លក្ខខណ្ឌដើម្បីក្លាយជាធុរជនល្អបំផុត

ដើម្បីអាចក្លាយជាធុរជនល្អបំផុតនៅកម្ពុជា ធុរជន ឬបុគ្គលពាក់ព័ន្ធដែលស្នើសុំពាក់ព័ន្ធនឹងការនាំចូលត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ស្ថិតក្នុងបញ្ជីធុរជនចំណាត់ថ្នាក់លេខ១ (Rank 1) នៃប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជននាពេលដាក់ពាក្យស្នើសុំ
- ជានីតិបុគ្គលដែមានដើមទុនចុះបញ្ជីមិនតិចជាង ១ពាន់លានរៀល
- មិនធ្លាប់ប្រព្រឹត្តបទល្មើសគយធ្ងន់ធ្ងរដោយចេតនាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ គិតត្រឹមថ្ងៃ ដាក់ពាក្យស្នើសុំ
- មិនធ្លាប់ជំពាក់បំណុលពន្ធអាករគយហួសកាលកំណត់ ឬ បំណុលផ្សេងទៀតដែលមិនអាចសងបាន
- អនុវត្តបានពេញលេញនូវកាតព្វកិច្ចគ្រប់គ្រងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មាន ផ្សេងទៀតពាក់ ព័ន្ធនឹងការនាំចូលតាមបទប្បញ្ញត្តិជាធរមាន
- ត្រូវមានទំហំពាណិជ្ជកម្មនាំចេញនាំចូលប្រចាំឆ្នាំមិនតិចជាង ២លានដុល្លារអាមេរិក និងមានកាតព្វកិច្ចធ្វើរបាយការតាមទម្រង់នានាដែលកំណត់ដោយអង្គភាពគ្រប់គ្រងធុរជនល្អបំផុតនៃGDCE ។

### ៣.២.២ លក្ខខណ្ឌដើម្បីចុះឈ្មោះជាសមាជិក

ធុរជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីក្លាយជាសមាជិកក្រុមធុរជនល្អបំផុត ត្រូវដាក់ពាក្យ ស្នើសុំមកអគ្គនាយគយនិងរដ្ឋាករកម្ពុជា (GDCE) អមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន អមបញ្ជីម្ចាស់ភាគហ៊ុននាថ្ងៃស្នើសុំ
- ការប្រកាសពីស្ថានភាពហិរញ្ញវត្ថុ (Financial Statement) នាពីរឆ្នាំចុងក្រោយ (បើមានការតម្រូវ)
- លិខិតបញ្ជាក់ទទួលស្គាល់អនុលោមភាពពីសហគមន៍ធុរកិច្ចពាក់ព័ន្ធ

[32] វេបសាយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (www.customs.gov.khនីតិវិធីពិសេស/ធុរជនល្អបំផុត/), (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧)

- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមនិង/ឬ បណ្ណប៉ាតង់ ឬ លិខិតអនុញ្ញាតប្រហាក់ប្រហែល
- ច្បាប់ចម្លងនៃអត្តសញ្ញាណបណ្ណ ឬ ឯកសារប្រហាក់ប្រហែលរបស់ថ្នាក់ដឹកនាំក្រុមហ៊ុន
- ទំហំនៃការនាំចូលការនាំចេញ និងការលក់ចូលទីផ្សារក្នុងស្រុកនាឆ្នាំចុងក្រោយ។

### ៣.២.៣ អត្ថប្រយោជន៍ដែលទទួលបានរបស់ធុរជនល្អបំផុត

នីតិបុគ្គល ឬរូបវន្តបុគ្គលទាំងឡាយណាដែលបានជាប់ជាធុរជនល្អបំផុតនឹងទទួលបាននូវ**ការលើកទឹកចិត្ត ក៏ដូចជាការអនុគ្រោះមួយចំនួនដូចខាងក្រោម៖**

- អាទិភាពមិនរង់ចាំតាមជួរលំដាប់លំដោយតាមគោលការណ៍មកមុនផ្តល់សេវាមុន (First-in First-out principle)ទាំងក្នុងដំណាក់កាលដាក់ឯកសារ ដំណាក់កាលត្រួតពិនិត្យទំនិញឬ ឯកសារ និង ដំណាក់អនុញ្ញាតឲ្យយកទំនិញចេញ តាមរូបភាពរហ័សនិងលទ្ធភាព ដែលអាចធ្វើទៅបាន
- អាចទទួលបាននូវការអនុញ្ញាតឲ្យជំពាក់បែបបទគយ ដោយលើកលែងការតម្កល់និមុត្តិធានា
- ការលើកលែងនីតិវិធីនៃការផ្ទៀងផ្ទាត់ជាមុននូវតម្លៃគិតពន្ធគយនិងវិញ្ញាបនបត្រប្រភពដើមទំនិញ
- ការលើកលែងកាតព្វកិច្ចអមលិខិតអនុញ្ញាតដឹកជញ្ជូនកាតព្វកិច្ចត្រាពន្ធគយ និងការកាត់បន្ថយកាតព្វកិច្ចឆ្លងម៉ាស៊ីនស្កេន
- លទ្ធភាពនៃការបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-arrival Clearance) និងការបំពេញបែបបទគយចុងទី (Destination Clearance) ក្រោមរបបគយឆ្លងកាត់ ជាដើម។

## ៣.៣ ការបង្កើតនីតិវិធីដើម្បីសម្រួលបន្ថែមទៀតដល់វិនិយោគិន និងអ្នកពាក់ព័ន្ធ

ដើម្បីបង្កភាពងាយស្រួលបន្ថែមទៀតដល់អ្នកនាំចូល និងអ្នកពាក់ព័ន្ធទាំងឡាយ រដ្ឋាភិបាលបានបង្កើតនីតិវិធីមួយចំនួនទៀតដើម្បីឲ្យមន្ត្រីគយអនុវត្តមានដូចតទៅ៖

១. ជម្រុញការធ្វើការឲ្យបានកាន់តែឆាប់រហ័ស ដោយក្នុងការបញ្ជាក់ការបំពេញបែបបទបញ្ចេញទំនិញពីគយគឺមិនឲ្យលើសពីមួយថ្ងៃនោះទេ។ ប្រសិនបើឯកសារដាក់ជូនមន្ត្រីគយមានសមត្ថកិច្ចមុនម៉ោង ប្រាំបួនព្រឹក ត្រូវធ្វើការបញ្ចប់នៅក្នុងថ្ងៃដដែល។ ហើយប្រសិនបើឯកសារដាក់ក្រោយម៉ោងប្រាំបួនព្រឹក បែបបទនេះត្រូវបញ្ចប់យ៉ាងយូរនៅថ្ងៃធ្វើការបន្ទាប់។

២. ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងឲ្យបានទូលំទូលាយដល់វិស័យឯកជនដែលមានការពាក់ព័ន្ធឲ្យបានដឹង និងយល់អំពីករណីនេះ។

៣. ការឃាត់ និងត្រួតពិនិត្យឆែកឆេរទំនិញនៅតាមដងផ្លូវត្រូវធ្វើឡើងក្នុងករណីមានការសង្ស័យតែប៉ុណ្ណោះ ដោយព្យាយាមកុំឲ្យមានភាពយឺតយ៉ាវដល់ម្ចាស់ ឬការដឹកជញ្ជូនទំនិញ។ ក្នុងនោះដែរ ការត្រួតពិនិត្យ មិនគួរធ្វើឲ្យលើស ២% នៃចំនួនមធ្យោបាយដឹកជញ្ជូនទំនិញ និងមិនត្រូវបង្កការលំបាក និងយឺតយ៉ាវដល់ធុរជនត្រឹមត្រូវនោះទេ។ ក្នុងករណីមានការសង្ស័យទើបត្រូវធ្វើការត្រួតពិនិត្យជាបន្តបន្ទាប់។

៤. រាល់ឯកសារដែលចារបានបញ្ជាក់ ឬផ្ទៀងផ្ទាត់ពី GDCE រួច សម្រាប់ការអនុវត្តការបំពេញបែបបទគយនៅអង្គភាពនានាតាមមាត់ច្រកព្រំដែន ឬការិយាល័យផ្សេងទៀតតាមការកំណត់ ពុំតម្រូវឲ្យធ្វើការស្នើសុំចារ ឬបញ្ជាក់នៅតាមសាខាគយ និងរដ្ឋាករពាក់ព័ន្ធទៀតនោះទេ។

៥. សម្រាប់ការនាំចូល ធាតុចូលផ្សេងៗរបស់ខាងវិនិយោគកាត់ដេរ និងវិនិយោគិនក្នុង SEZ ក្រោមប្រព័ន្ធមេ ដែលមានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ចនានា តម្លៃទំនិញនាពេលបំពេញបែបបទសុំនាំចូល ឬបំពេញបែបបទបញ្ចេញទំនិញពីគយ ត្រូវឯកភាពជាបណ្ដោះអាសន្នទៅតាម invoice ដែលបានប្រកាស និងទុកជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ៣.៤ ការកាត់បន្ថយអត្រាពន្ធអាករលើទំនិញនាំចូលមួយចំនួន

ប្រទេសកម្ពុជា បានចូលជាសមាជិកអាស៊ាននៅឆ្នាំ ១៩៩៩[33] ទន្ទឹមនឹងការក្លាយជាសមាជិកជាមួយបណ្ដាប្រទេសផ្សេងៗនេះ កម្ពុជាក៏បានយល់ព្រមធ្វើកិច្ចព្រមព្រៀងមួយចំនួនពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មចេញចូលរវាងបណ្ដាប្រទេសផងដែរ ដើម្បីជាការធ្វើកិច្ចសម្រួលពាណិជ្ជកម្ម និងដើម្បីជាផលប្រយោជន៍រួមក្នុងការចូលជាសមាជិក។ ជាមួយនឹងការបង្កើតគោលការណ៍របស់ខ្លួនក្នុងការទប់ស្កាត់ការហូរចូលនូវទំនិញហួសព្រំដែន ក៏ដូចជាដើម្បីរក្សាផលិតករ និងគោលបំណងផ្សេងទៀត កម្ពុជាក៏នៅរក្សាភាពទន់ភ្លន់តាមរយៈការបន្ធូរបន្ថយពន្ធដល់ប្រទេសជាដៃគូ និងបណ្ដាប្រទេសជាសមាជិកផងដែរ។

### ៣.៤.១ កិច្ចព្រមព្រៀង ATIGA របស់បណ្ដាប្រទេសសមាជិកអាស៊ាន

ប្រទេសកម្ពុជាត្រូវលុបពន្ធនាំចូលលើគ្រប់ផលិតផលទាំងអស់គិតចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៨ តាមរយៈគម្រោងលម្អិតដូចខាងក្រោម[34] ៖

[33] សៀវភៅកម្រងសំណួរចម្លើយពាក់ព័ន្ធនឹងអាស៊ាន របស់លោក គង់ សុខហេង, ទំព័រទី២

[34] វេបសាយរបស់អគរ http://www.customs.gov.kh/អត្រាពន្ធ, (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧)

- ៨០%នៃបន្ទាត់ពន្ធគយសរុបត្រូវបញ្ចុះមកនៅត្រឹម ០-៥% ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩
- ពន្ធនាំចូលលើផលិតផល Information and Communication Technology-ICT ត្រូវបញ្ចុះមក ០% ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០
- ពន្ធនាំចូលលើផលិតផលកសិកម្មមិនទាន់កែច្នៃ នៅក្នុងបញ្ជីវេទយិតភាព ត្រូវកាត់បន្ថយ ឬ លុបមក ០-៥% នៅឆ្នាំ២០១៧។
- ពន្ធនាំចូលលើផលិតផលកសិកម្មមិនទាន់កែច្នៃនៅក្នុងបញ្ជីវេទយិតខ្ពស់ត្រូវអនុវត្តតាមអត្រា MFN ជាធរមាន។

គួរគូសបញ្ជាក់ផងដែរថា ព្រះរាជាណាចក្រកម្ពុជា អាចរក្សាទុកអត្រាពន្ធ ៥% ចំនួន ៧% នៃបន្ទាត់ពន្ធគយសរុប ឬ ស្មើនឹង ៦៦២ បន្ទាត់ពន្ធរហូតដល់ឆ្នាំ២០១៨។

### ៣.៤.២ ភាពជាដៃគូសេដ្ឋកិច្ចគ្រប់តំបន់ RCEP[35]

ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) គឺជាកិច្ចចរចារពាណិជ្ជកម្មសេរី (FTA) មួយដែលត្រូវបានបង្កើតឡើងក្នុងចំណោមប្រទេសទាំង១៦មាន៖

**រូបភាពទី៩៖ តំបន់ RCEP**




[35] វេបសាយរបស់អាស៊ាន http://asean.org/?static_post=rcep-regional-comprehensive-economic-partnership, (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧)

- សមាជិកអាស៊ានទាំង ១០ប្រទេស (ប្រ៊ុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាត )
- និងប្រទេសទាំងប្រាំមួយទៀត ដែលមានស្រាប់នូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយ អាស៊ាន (FTAs) មានដូចជាប្រទេសអូស្ត្រាលី ចិន ឥណ្ឌា ជប៉ុន កូរ៉េ និងនូវែលសេឡង់។
- ទាក់ទងជាមួយនឹង RCEP ទាំងប្រាំមួយ ប្រទេសដែលមិនមែនជាសមាជិកអាស៊ានទាំង នោះត្រូវបានគេស្គាល់ថាជាដៃគូពាណិជ្ជកម្មសេរីអាស៊ាន ( AFPs )។

បន្ទាប់ពីបានធ្វើការរៀបចំ បណ្តាប្រទេសដែលបានចូលរួមបានចាប់ផ្តើមកិច្ចចរចាជាផ្លូវការ នៅក្នុងខែឧសភា ឆ្នាំ២០១៣។ RCEP នឹងគ្របដណ្តប់ការធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម ការវិនិយោគ កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចនិងបច្ចេកទេស កម្មសិទ្ធិបញ្ញា ការប្រកួតប្រជែង ការដោះស្រាយវិវាទ/បញ្ហាផ្លូវច្បាប់ និងបញ្ហារបស់ស្ថាប័ន ព្រមទាំងបញ្ហាផ្សេងទៀតដើម្បីត្រូវបានបញ្ជាក់កំឡុងពេលនៃការចរចានេះ។

### ៣.៤.៣ ការដាក់ពន្ធ អាករជាបន្ទុករបស់រដ្ឋ

ប្រព្រឹត្តកម្មលើកទឹកចិត្ត ជាពិសេសដើម្បីគាំទ្រដល់វិស័យអាទិភាពរបស់ប្រទេសកម្ពុជា រដ្ឋាភិបាលបានសម្រេចដាក់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋលើមុខទំនិញនាំចូលមួយចំនួន និងភាគច្រើនផ្តោតលើទំនិញសម្រាប់វិស័យកសិកម្មដូចមានរៀបរាប់ខាងក្រោម៖

**រូបទី១០៖ ការលើកលែងពន្ធនិងអាករ**




**១.ពន្ធនាំចូលជាបន្ទុករបស់រដ្ឋមាន៖**

- ពូជដំណាំ
- និងពូជសត្វគ្រប់ប្រភេទ ដែលមានការបញ្ជាក់ទទួលស្គាលពីស្ថាប័នមានសមត្ថកិច្ច។

**២.អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ៖**

- ពូជដំណាំ
- និងពូជសត្វគ្រប់ប្រភេទ ដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច។
- ចំណីសត្វ និងវត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វ
- បសុឱសថដែលមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
- ជីកសិកម្មដែលមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
- ថ្នាំសម្លាប់សត្វល្អិត
- ម៉ាស៊ីនបូមទឹក
- ម៉ាស៊ីនសម្រាប់សម្ងួតកសិកម្ម
- ម៉ាស៊ីនផ្សេងៗក្នុងគោលបំណងបម្រើឲ្យការងារកសិកម្ម
- គោយន្ត និងត្រាក់ទ័រកសិកម្ម

# ជំពូកទី៤
# ការវាយតម្លៃលើការគ្រប់គ្រងទំនិញនាំចូលតាមផ្លូវគោក

# ជំពូកទី ៤

# ការវាយតម្លៃលើការគ្រប់គ្រងការនាំចូលតាមផ្លូវគោក

ការគ្រប់គ្រងបានល្អនូវទិន្នន័យនៃផលិតផលនាំចូល និងនាំចេញគឺជាកត្តាសំខាន់ ដែលចូលរួមចំណែកធ្វើឲ្យភាពរីកចម្រើន ព្រមទាំងការអភិវឌ្ឍ ដល់សង្គមជាតិទៀតផង។ ជាក់ស្តែងដូចជាការគ្រប់គ្រងទំនិញនាំចូលតាមផ្លូវគោកនេះ ដែលមានទស្សនវិស័យក្នុងការអភិវឌ្ឍខ្លួនឲ្យក្លាយទៅជាការផ្តល់របៀបគ្រប់គ្រងមួយដែលមានប្រសិទ្ធិភាព និងស្របតាមបមាណីយនិងឧត្តមានុវត្តន៍ ដោយមានការទទួលស្គាល់ពីថ្នាក់ជាតិនិងអន្តរជាតិ ដល់សហគមន៍ធុរកិច្ចនិងភាគីពាក់ព័ន្ធ។ មិនត្រឹមតែប៉ុណ្ណោះរាប់បញ្ចូលទាំងកាតព្វកិច្ច និងបេសកកម្ម ដើម្បីជួយពន្លឿន និងសម្រួលដល់ការធ្វើធុរកិច្ចស្របច្បាប់ និងការប្រមូលនិងបង្កើនចំណូលថវិកាជាតិ ការធានាឲ្យមានការប្រកួតប្រជែងសេដ្ឋកិច្ចប្រកបដោយសមធម៌ ការធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពសង្គមនិងសន្តិសុខជាតិ និងការធ្វើឲ្យមាននិរន្តភាពនៃការអភិវឌ្ឍ និងសម្រេចបានតាមគោលដៅកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។

ក្នុងន័យនេះប្រសិនបើនីតិវិធីនៃការគ្រប់គ្រងល្អម៉ត់ចត់ និងស៊ីជម្រៅ ប៉ុន្តែគ្មានការអនុវត្តនោះគម្រោងនៅតែមានភាពបរាជ័យដដែល។ ដូច្នេះហើយការអនុវត្តជាចាំបាច់ ត្រូវដើរទន្ទឹមគ្នានឹងការបង្កើត និងដាក់ឲ្យដំណើរការនូវនីតិវិធី និងយន្តការផ្សេងៗ។ បន្ទាប់ពីបានធ្វើការសិក្សាវិភាគដូចបានរៀបរាប់ខាងដើម ការធ្វើការវិភាគអំពីប្រសិទ្ធិភាពនៃនីតិវិធីមានដូចតទៅៈ

## ៤.១ កត្តាដែលមានឥទ្ធិពលដល់ការនាំចូល

ការនាំចូលទំនិញមកកម្ពុជាតាមផ្លូវគោក ទទួលរងនូវឥទ្ធិពល៥យ៉ាង ដែលធ្វើអាចធ្វើឲ្យមានការកើនឡើង អន់ថយ ឬការប៉ះពាល់ពីការនាំចូល ដែលបង្កើតឲ្យមាននីតិវិធីគ្រប់គ្រងទំនិញនេះឡើង។ កត្តាទាំងនោះរួមមានៈ

### ៤.១.១ ចំណេះដឹង និងការអប់រំ

ចំណេះដឹងគឺជាកត្តាសំខាន់ដែលផ្តល់ទាំងផលវិជ្ជមាន និងអវិជ្ជមានទៅដល់ការនាំចូល។ នៅពេលដែលអ្នកពាក់ព័ន្ធទាំងឡាយមានចំណេះដឹងកាន់តែទូលំទូលាយ នោះការយល់ដឹង និងការគោរពច្បាប់ក៏កាន់តែមានប្រសិទ្ធិភាពដែរ។ ផ្ទុយទៅវិញប្រសិនបើអ្នកទាំងនោះខ្វះចំណេះដឹង នោះនឹងអាចបង្កឲ្យមានអំពើរត់គេចពន្ធកាន់តែច្រើន និងបង្កភាពអសន្តិសុខនៅក្នុងប្រទេសទៀតផង។

### ៤.១.២ របាំងពន្ធ

រាល់ការធ្វើពាណិជ្ជកម្មអន្តរជាតិរវាងប្រទេស និងប្រទេសជាចាំបាច់តែងមានរបាំងដើម្បីការពារផលិតករក្នុងស្រុកក៏ដូចជាស្ថេរភាពសេដ្ឋកិច្ចផងដែរ។ ជាក់ស្តែងដូចប្រទេសកម្ពុជាជ្រើសរើស

យករបាំងពន្ធដើម្បីកាត់បន្ថយការនាំចូលលើសតម្រូវការ។ របាំងពន្ធជាប្រភពចំណូលមួយរបស់ប្រទេស ប៉ុន្តែ វាជាកត្តាដែលធ្វើឲ្យបរិមាណនៃការនាំចូលត្រូវកាត់បន្ថយផងដែរ។ ទោះជាយ៉ាងនេះក្តី ក៏របាំងពន្ធនេះនឹងមិនត្រូវបានលុបបំបាត់ទាំងស្រុងនោះទេ ព្រោះវាជារនាំងដែលអាចការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់ សុខភាពរបស់ប្រជាជនក្នុងប្រទេស ជាពិសេសការការពារផលិតករក្នុងស្រុកផងដែរ។

### ៤.១.៣ កិច្ចសម្រួលពាណិជ្ជកម្ម

ទន្ទឹមនឹងការដាក់ឲ្យអនុវត្តរាល់បញ្ញត្តិផ្សេងៗជាធរមាន រដ្ឋាភិបាលក៏បានតាក់តែងនិងព្យាយាមស្វែងរកវិធីយ៉ាងណាដើម្បីសម្រួលពាណិជ្ជកម្មឲ្យកាន់តែរហ័ស ងាយស្រួល និងមានប្រសិទ្ធិភាពជាងមុនផងដែរ។ ជាក់ស្តែងដូចជាការកំណត់មុខសញ្ញាដែលត្រូវធ្វើការត្រួតពិនិត្យទំនិញជារូបវន្ត ការលើកលែងពន្ធ និងអាករជាដើម ដែលសុទ្ធសឹងជាយន្តការរបស់រដ្ឋាភិបាលក្នុងការលើកទឹកចិត្ត និងសម្រួលដល់ពាណិជ្ជករទាំងឡាយដែលធ្វើការនាំចូល។ ក្នុងន័យនេះកិច្ចសម្រួលពាណិជ្ជកម្ម ក៏បានជះឥទ្ធិពលវិជ្ជមានដល់ធុរជន ដែលធ្វើឲ្យនីតិវិធីប្រព្រឹត្តមានភាពច្បាស់លាស់តាមរយៈការណែនាំ និងការជូនដំណឹងជាបន្តបន្ទាប់តាំងពីថ្នាក់រដ្ឋាភិបាល ក្រសួងរហូតដល់ស្ថាប័នមានសមត្ថកិច្ច។

### ៤.១.៤ ថ្លៃ

កត្តាថ្លៃបានជះឥទ្ធិពលទៅដល់សកម្មភាពពាណិជ្ជកម្មទាំងមូល។ ជាក់ស្តែងដូចជារបាំងពន្ធដែលបានរៀបរាប់ខាងលើ វាបានក្លាយជាបន្ទុករបស់អ្នកនាំចូលមួយកម្រិត ហើយនៅពេលដែលធ្វើការលក់ ឬចែកចាយទំនិញទាំងនោះ ចំណាយថ្លៃនៃការបំពេញកាតព្វកិច្ចពន្ធ និងអាករនឹងត្រូវបូកបញ្ចូលមុនពេលធ្វើការលក់បន្ត។ ជាលទ្ធផល អ្នកដែលរងគ្រោះពិតប្រាកដគឺអ្នកដែលប្រើប្រាស់ចុងក្រោយ ព្រោះពួកគេនឹងត្រូវទិញទំនិញក្នុងតម្លៃមួយដែលរាល់ថ្លៃចំណាយផ្សេងៗទាំងអស់ត្រូវបានបូកបញ្ចូល។ មួយវិញទៀត នៅពេលដែលមានការនាំចូលទំនិញខូចគុណភាព ឬទំនិញដែលមានសារធាតុគីមី ធ្វើឲ្យតម្លៃដើមនៃការទិញចូលទាប ដែលធ្វើឲ្យខូចតម្លៃទីផ្សារនៅក្នុងស្រុក។ ដូចជាតាមការចុះផ្សាយរបស់ freshnews កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ នៅខេត្តឧត្តរមានជ័យ ដែលនិយាយពីការនាំចូលសាច់មាន់ ឆ្អឹង និងជង្គង់មាន់ខូចគុណភាព។[36]

[36] គេហទំព័ររបស់ freshnews http://www.freshnewsasia.com/index.php/en/localnews/57267-2017-06-13-07-58-57.html, (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧)

### ៤.២ ការវិភាគ SWOT

ការវិភាគដោយប្រើប្រាស់វិធីសាស្ត្រ SWOT គឺវិធីសាស្ត្រមួយដែលអាចឲ្យដឹងអំពីភាពខ្លាំង ភាពខ្សោយ ព្រមទាំងឱកាសដើម្បីឈានទៅរកការអភិវឌ្ឍ និងបញ្ហាប្រឈមនានាផងដែរ។ នៅក្នុងអត្ថបទស្រាវជ្រាវនេះនឹងធ្វើការវិភាគសិក្សារកចំណុចខ្លាំង (Strengths) ចំណុចខ្សោយ(Weakness) ឱកាសដែលនាំទៅរកភាពរីកចម្រើន(Opportunities) និងការគម្រាមគំហែង(Threats) ពាក់ព័ន្ធទៅនឹងនីតិវិធីនៃការគ្រប់គ្រងទំនិញនាំចូលមកដល់កម្ពុជាតាមផ្លូវគោកដូចតទៅ៖

#### ៤.២.១.ភាពខ្លាំង ( Strength )

បើធ្វើការសង្កេត និងវិភាគទៅលើចំណុចវិជ្ជមាននៃការបង្កើតឲ្យមាននីតិវិធីនេះកាលពីឆ្នាំ ២០១២ ធៀបជាមួយនឹងឆ្នាំ២០១៧ ឃើញថាយន្តការរបស់រដ្ឋាភិបាលពិតជាមានប្រសិទ្ធភាពជាងមុនរួមមាន៖

**ក. ការទទួលបានពីការកែសម្រួលនីតិវិធី**

- យោងតាមការបកស្រាយខាងលើទាក់ទងនឹងចំណុចប្រតិវេទន៍គយក្នុងទំព័រទី១៩ នៃអត្ថបទស្រាវជ្រាវនេះឃើញថានីតិវិធីមានភាពសុក្រឹត្យជាងមុនក្រោយពេលមានកំណែទម្រង់គិតចាប់ពីឆ្នាំ២០១៣មក ពីព្រោះបានបញ្ជាក់ច្បាស់ពីរបៀបនៃការប្រកាសទំនិញរបស់អ្នកនាំចូលយ៉ាងល្អិតល្អន់ធៀបនឹងពេលកន្លងទៅដែលមិនទាន់ការកំណត់ដោយរដ្ឋាភិបាល លើវាល់ជំហាននៃការបំពេញការងារពាក់ព័ន្ធនឹងការនាំចូលនេះទេ។
- ដោយមានការកំណត់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការចេញប្រកាសពាក់ព័ន្ធនឹងរយៈពេលនៃការធ្វើការឃើញថា មានការកាត់បន្ថយពេលវេលានៃការធ្វើប្រតិបត្តិការឯកសារនាំចូលមកត្រឹម១ថ្ងៃ ឬ២ថ្ងៃធ្វើការយ៉ាងយូរ។

**ខ.ផលល្អចំពោះអ្នកនាំចូល**

- អ្នកនាំចូលមានភាពងាយស្រួលជាងមុនដោយធ្វើការប្រកាសតែម្តងគត់ ក្នុងដំណើរការនៃការនាំចូល តាមរយៈការដាក់ឯកសារប្រតិវេទន៍។
- អ្នកនាំចូលអាចបំពេញកាតព្វកិច្ចពន្ធ និងអាករលើទំនិញនាំចូលនៅហ្នឹងកន្លែងក្រោយបញ្ជាក់ថាទំនិញដែលបានប្រកាសមានភាពត្រឹមត្រូវ។
- អ្នកនាំចូល ឬតំណាងម្ចាស់ទំនិញយល់ច្បាស់ពីទំនិញដែលខ្លួនបានប្រកាស ព្រោះពួកគេជាអ្នកបំពេញប្រតិវេទន៍ដោយខ្លួនឯង ដែលមានភាពងាយស្រួលនៅពេលមានការសាកសួរ។

- កាត់បន្ថយភាពយឺតយ៉ាវរបស់អ្នកនាំចូល និងធ្វើឲ្យពួកគេអាចប៉ាន់ស្មានបានពីរយៈពេលនៃលំហូរនីតិវិធីនាំចូលទាំងមូលតាំងពីដើមរហូតដល់ការយកទំនិញចេញ។

**គ.ផលល្អចំពោះអ្នកគ្រប់គ្រង**

- មន្ត្រីមានសមត្ថកិច្ចអាចកំណត់បានពីប្រវត្តិរបស់ក្រុមហ៊ុននាំចូលតាមរយៈការដាក់ពណ៌របស់ប្រព័ន្ធ និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវក្នុងការត្រួតពិនិត្យ។
- កាត់បន្ថយការបង្កភាពយឺតយ៉ាវដល់ប្រតិបត្តិករតាមរយៈការជ្រើសរើសយកតែក្រុមហ៊ុនឬទំនិញដែលជាមុខសញ្ញាមានហានិភ័យឬមានការសង្ស័យក្នុងការត្រួតពិនិត្យទំនិញជារូបវន្តប៉ុណ្ណោះ។
- ភាពងាយស្រួលក្នុងការបញ្ជូនឯកសារ និងធ្វើការពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតដោយប្រើប្រាស់ប្រព័ន្ធ ASYCUDA។
- ការបរិយាយ និងការណែនាំពីនីតិវិធីមានភាពច្បាស់លាស់ ដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការអនុវត្ត។

**៤.២.២.ភាពខ្សោយ** (Weakness)

ចំនុចខ្សោយអាចកើតមានឡើងមិនមែនដោយសារច្បាប់របស់ប្រទេសមិនគ្របដណ្តប់នោះទេក៏ព្រោះតែការអនុវត្តមិនទាន់បានទាំងស្រុងនៅឡើយ។

**ក. ការអប់រំ**

- កង្វះខាតធនធានមនុស្សក្នុងការអនុវត្តនីតិវិធីទាំងឡាយឲ្យមានប្រសិទ្ធភាពខ្ពស់ព្រោះចំណេះដឹងនៅមានកម្រិតជាពិសេសផ្នែកបច្ចេកវិទ្យាដែលមានការចាំបាច់ពាក់ព័ន្ធនឹងការនាំចូលទំនិញនេះ។
- អ្នកនាំចូលមួយចំនួនតូច មិនបានធ្វើការនាំចូលដោយខ្លួនឯង និងផ្ទេរសិទ្ធិទៅឲ្យតំណាងម្ចាស់ធ្វើការនាំចូល ដែលជាហេតុធ្វើឲ្យក្នុងករណីខ្លះមិនបានដឹងច្បាស់អំពីទំនិញទាំងនោះ ធ្វើឲ្យបង្កការលំបាកនៅពេលមានការសាកសួរពីមន្ត្រីមានសមត្ថកិច្ច។
- ខ្វះការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់វិស័យឯកជនដែលជាហេតុធ្វើឲ្យមានការលំបាកដល់អ្នកដែលចង់ធ្វើការនាំចូលថ្មីដែលខ្វះព័ត៌មាន។

**ខ. កង្វះខាតការប្រុងប្រយ័ត្ន**

- ការបង្កើតឲ្យទៅជាប្រព័ន្ធស្វ័យប្រវត្តិកម្មគយដែលធ្វើការផ្សារភ្ជាប់ទៅនឹងបណ្តាញអ៊ីនធឺណែត អាចបង្កជាបញ្ហានៅពេល សេវាមានមិនគ្រប់ដណ្តប់គ្រប់ជាពិសេសនៅតំបន់ដាច់ស្រយាល ជាដើម។
- ការខូចខាត ឬកកស្ទះប្រព័ន្ធដែលអាចកើតមានជាយថាហេតុដែលបណ្តាលឲ្យមានការបាត់បង់ទិន្នន័យសំខាន់ៗ។
- ការលួចទិន្នន័យ (hacked) ពីជនខិលខូចមួយចំនួនដែលមានបំណងមិនល្អ ក៏អាចជាកត្តាធ្វើឲ្យមានលំបាក និងជាចំនុចខ្សោយនៅពេលដែលមានការអនុវត្តនៅក្នុងប្រព័ន្ធអេឡិចត្រូនិចដែរ។
- ការអនុគ្រោះ និងការលើកទឹកចិត្តក្រោមរូបភាពផ្សេងៗដូចជាឥវ៉ាន់ជាប់ខ្លួនអ្នកដំណើរជាដើម ដែលជាហេតុផលអាចឲ្យកើតមាននូវអំពើរត់គេចពន្ធ ក្នុងគោលបំណងយកមកធ្វើការលក់ចែកចាយ ដោយមិនបំពេញកាតព្វកិច្ចពន្ធ និងអាករ។

**គ. បទល្មើស**

- ការបន្ធូរបន្ថយ និងអនុគ្រោះនូវពន្ធនិងអាករទៅលើករណីមួយចំនួនអាចបង្កឲ្យទៅជាការឆ្លៀតឱកាសក្នុងការនាំចូលដោយគេចវេសកាតព្វកិច្ចពន្ធ និងអាករផងដែរ។
- ការបង្កើតឲ្យមានច្បាប់ និងនីតិវិធីតឹងរឹង រឹតត្បិតការនាំចូលនេះ អាចជាកម្មវត្ថុដល់ជនខិលខូចក្នុងការគេចវេស និងប្រព្រឹត្តផ្ទុយអំពីច្បាប់។
- ដោយសារនីតិវិធីច្បាស់លាស់ និងធ្វើជាជំហានៗ ធ្វើឲ្យអ្នកខ្លះបទពិសោធន៍ពាក់ព័ន្ធនឹងការងារទាំងនេះយល់ថាជាការលំបាកជាងមុន និងមានភាពស្មុគស្មាញ។
- ការបើកចំហរឲ្យមានការនាំចូលនេះអាចបង្កឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំង និងប៉ះទង្គិចដល់ផលិតករក្នុងស្រុកផងដែរ។
- ទោះបីជាការបង្កើតឲ្យមានច្បាប់ និងចាត់វិធានការតឹងរឹង ប៉ុន្តែសកម្មភាពគេចវេសពន្ធនៅតែមាន។

**ឃ. ទស្សនៈ និងសំណូមពរពីផ្នែកឯកជន**

- កន្លងមកមានភាពយឺតយ៉ាវមួយចំនួនដោយសារតែ ករណីខ្លះទំនិញមានច្រើនម្ចាស់ហើយផ្ទុកក្នុងកុងតឺន័រតែមួយ និងមិនអនុញ្ញាតិឱ្យយកចេញនោះទេប្រសិនបើមិនទាន់មានឯកសារ

គ្រប់គ្រាន់ដើម្បីត្រួតពិនិត្យ និងបើកកុងតឺន័រនោះ។ អ្នកខ្លះនឹងមានភាពយឺតយ៉ាវ កកស្ទះនៅពេលដែលធ្វើការរង់ចាំដល់ម្ចាស់ផ្សេងទៀតបំពេញឯកសារឲ្យបានគ្រប់គ្រាន់។[37]

- នាពេលបច្ចុប្បន្ន អ្នកនាំចូលម្តងម្កាល ឬការនាំចូលផ្ទាល់ខ្លួនមានការលំបាកពីព្រោះមិនទាន់មានប្រព័ន្ធអេឡិចត្រូនិចដើម្បីធ្វើការប្រកាសដូចក្រុមហ៊ុននាំចូលនៅឡើយ ដែលជាហេតុមានការស្មុគស្មាញ និងយឺតយ៉ាវក្នុងការបំពេញកាតព្វកិច្ចពន្ធនិងអាករ។[38]

### ៤.២.៣. **ឱកាស** (Opportunity )

#### ក. ការក្លាយជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)

កម្ពុជាបានក្លាយជាសមាជិកទី ១៤៨ របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០០៤[39]។ ការចូលជាសមាជិកនេះបានផ្តល់ផលវិជ្ជមានដល់កម្ពុជាដូចតទៅៈ

- កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍដែលមានអាទិភាពលើវិស័យកសិកម្ម ដូច្នេះហើយវិស័យឧស្សាហកម្ម និងវិស័យផ្សេងៗទៀតជាពិសេសលទ្ធភាពក្នុងការផលិតរបស់របរប្រើប្រាស់ដើម្បីផ្គត់ផ្គង់ក្នុងស្រុក នៅមានកម្រិតតិចតួចបំផុត។ តាមរយៈ WTO និងការធ្វើសមាហរណកម្មអាស៊ាននេះ កម្ពុជានឹងមានឱកាសកាន់តែច្រើនក្នុងការនាំចូលទំនិញពីប្រទេសជិតខាងមកប្រើប្រាស់ដោយតម្លៃទាបជាងមុន ដោយសារការលុបបំបាត់នូវពន្ធនាំចូលពីបណ្តាប្រទេសជាសមាជិក។
- មិនត្រឹមតែទទួលបានអត្រាពន្ធអនុគ្រោះពីបណ្តាប្រទេសជាសមាជិកអាស៊ានប៉ុណ្ណោះនោះទេ កម្ពុជាក៏បានធ្វើកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសជាដៃគូមួយចំនួនទៀត ក្នុងការធ្វើពាណិជ្ជកម្មជាមួយគ្នាទៀតផង។ ឆ្លៀតក្នុងឱកាសនេះ ក៏ជាឱកាសមួយដ៏ល្អដែលអាចទាក់ទាញវិនិយោគិនចូលមកក្នុងប្រទេស ដែលអាចជាប្រភពចំណូលមួយជូនដល់រដ្ឋផងដែរ។

#### ខ. ការវិវត្តន៍ខ្លួនទៅជារដ្ឋបាលគយទំនើប

ចាប់តាំងពីឆ្នាំ២០១៣ មករដ្ឋបាលគយកម្ពុជាបានបង្កើត និងដាក់ឲ្យដំណើរការនូវប្រព័ន្ធស្វ័យប្រវត្តិកម្មគយ ASYCUDA នៅតាមមាត់ច្រកសំខាន់ៗ និងជាប្រភពប្រមូលចំណូល។ គិតមកត្រឹមដើមឆ្នាំ២០១៧នេះ ប្រព័ន្ធ ASYCUDA បានបំពាក់ប្រមាណ១១៦ ការិយាល័យទូទាំងប្រទេស ហើយនៅសល់តែប្រមាណ៥% ភាគរយទៀតប៉ុណ្ណោះត្រូវធ្វើការប្រមូលចំណូលក្រៅប្រព័ន្ធតាមរយៈការ

[37] របាយការណ៍កិច្ចប្រជុំយន្តការភាពជាដៃគូគយ ផ្នែកឯកជនលើកទី៥, ទំព័រទី៣, សំណួមពរទី៨

[38] របាយការណ៍កិច្ចប្រជុំយន្តការភាពជាដៃគូគយ ផ្នែកឯកជនលើកទី៥, ទំព័រទី៤, សំណូមពរទី១១

[39] វេបសាយរបស់អង្គការពាណិជ្ជកម្មពិភពលោក https://www.wto.org/english/ (ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៧)

សរសេរដៃ និងរាយការណ៍ជារបាយការណ៍។ នៅថ្ងៃខាងមុខដ៏ខ្លីនេះ ប្រសិនបើប្រព័ន្ធនេះគ្របដណ្ដប់បានទូទាំងប្រទេស នោះកម្ពុជានឹងបានអភិវឌ្ឍខ្លួនមួយកម្រិតទៀត ដែលវិវត្តន៍ទៅរករដ្ឋបាលគយទំនើប ដែលអាចកត់ត្រា រក្សា និងទាញយកទិន្នន័យបានគ្រប់ពេលវេលា និងទីកន្លែង។

### ៤.២.៤ ការគម្រាមកំហែង

ទោះបីជាមានការរីកចម្រើន និងចំណុចវិជ្ជមានមួយចំនួនធំក៏ដោយ ក៏ការគម្រាមកំហែងនៅតែអាចកើតមានដែលតម្រូវឲ្យមានការសិក្សាវិភាគ និងបង្ការទុកជាមុនផងដែរ។ កត្តាដែលអាចកើតមាននូវការគម្រាមកំហែងរួមមាន:

**ក. ការគេចវេស និងបង្កឲ្យមានបទល្មើស៖**

- ទោះបីជាមានការគិតគូរលើកទឹកចិត្ត ព្រមទាំងមានការអនុគ្រោះយ៉ាងណាក៏ដោយ ក៏អំពើការរត់គេចពន្ធពីជនខិលខូចមួយចំនួននៅតែមាន។ ជនមួយចំនួនតូចទាំងនោះដែលមានបំណងមិនល្អ ចង់ប្រកួតប្រជែងតម្លៃនៅលើទីផ្សារឲ្យកាន់តែមានតម្លៃទាប ធ្វើឲ្យទីផ្សារខូចតម្លៃ ដូច្នេះហើយពួកគេមិនចង់ឆ្លងកាត់នូវនីតិវិធីទាំងអស់នេះទេ។
- នីតិវិធីលម្អិតពេកអាចបង្កជាភាពស្មុគស្មាញ ជាពិសេសទៅដល់អ្នកដែលមានចំណេះដឹងមិនទូលំទូលាយពិបាកក្នុងការអនុវត្ត ហេតុដូច្នេះហើយក៏វាអាចបណ្ដាលឲ្យមានការរត់គេចពន្ធផងដែរ។

**ខ. កង្វះខាតផ្នែកព័ត៌មានវិទ្យា**

- ជាការពិតដែលពិភពលោកបច្ចុប្បន្នកំពុងឈានទៅរកសម័យបច្ចេកវិទ្យាកាន់តែទំនើបពីមួយថ្ងៃទៅមួយថ្ងៃ។ ប៉ុន្តែសព្វថ្ងៃនេះ កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍនៅឡើយ ដែលការប្រើប្រាស់បច្ចេកវិទ្យាទាំងអស់នេះនៅមានកម្រិតតិចតួចណាស់ ដែលជាហេតុនាំឲ្យការដាក់ឲ្យដំណើរការប្រតិបត្តិការដំណើរការទាំងឡាយតាមប្រព័ន្ធទំនើបនេះមិនទាន់ទទួលបានប្រសិទ្ធភាពពេញលេញនៅឡើយ។
- អ្វីដែលជាការគម្រាមកំហែងមួយទៀតនោះ គឺនៅពេលដែលនីតិវិធីទាំងស្រុងនឹងត្រូវពឹងផ្អែកលើប្រព័ន្ធ វាអាចបង្កជាហានិភ័យដូចជា ប្រព័ន្ធដើររអាក់រអួល ឬអាចឈានទៅដល់ការបាត់បង់ទិន្នន័យដែលបានរក្សាទុកនៅក្នុងប្រព័ន្ធទាំងនោះទៀតផង។

**គ. ការចូលជាសមាជិក WTO**

ទន្ទឹមនឹងការផ្ដល់ឱកាសវិជ្ជមាន ក្រោយពីការចូលជាសមាជិក WTO នេះ វាក៏បានការគម្រាមកំហែងដល់កម្ពុជាលើចំនុចមួយចំនួនផងដែររួមមាន:

- បណ្តាលឲ្យមានការនាំចូលកាន់តែច្រើន និងធ្វើឲ្យផលិតភាពក្នុងការផលិតនឹងធ្លាក់ចុះ។
- ការនាំចូលទំនិញដែលគ្មានគុណភាព ជាពិសេសទំនិញចាស់ៗពីបរទេសចូលមកក្នុងប្រទេស ដែលអាចប៉ះពាល់ដល់បរិស្ថាន និងសុខភាពរបស់ប្រជាជន។

មួយវិញទៀត ក្នុងការចូលជាសមាហរណកម្មអាស៊ានវាបានផ្តល់ផលចំណេញ ប៉ុន្តែក្នុងនោះវាក៏អាចផ្តល់លទ្ធផលដូចជា៖

- ការបាត់បង់ចំណូលចូលរដ្ឋតាមរយៈការលើកលែងពន្ធ និងអាករក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន។
- ការហូរចូលនូវទំនិញ និងពលកម្មចូលមកក្នុងប្រទេស ដែលអាចឲ្យកម្ពុជារងនូវសម្ពាធការគ្មានការងារធ្វើ។
- ការប្រកួតប្រជែងនៅលើទីផ្សារកាន់តែខ្លាំង។

# សេចក្ដីសន្និដ្ឋាន
# និងការផ្ដល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ "នីតិវិធីនៃការគ្រប់គ្រងទំនិញនាំចូលមកដល់កម្ពុជាតាមផ្លូវគោក" រួចមកយើងពិតជាទទួលបាននូវចំណេះដឹងជាច្រើនបន្ថែមទៀតតាមរយៈការលើកឡើងនូវទ្រឹស្តីអន្តរជាតិដែលធ្លាប់បានសិក្សា ផ្សារភ្ជាប់ទៅនឹងប្រធានបទពាក់ព័ន្ធនឹងការនាំចូលនេះ។ លើសពីនេះទៀត អត្ថបទស្រាវជ្រាវនេះក៏បានបង្ហាញអំពីប្រភេទទំនិញ បែបបទ នីតិវិធី និងច្បាប់សម្រាប់អនុវត្តលើការនាំចូលទំនិញ។ មិនត្រឹមតែប៉ុណ្ណោះអត្ថបទនេះក៏បានបង្ហាញអំពីភាពរីកចម្រើន និងការយកចិត្តទុកដាក់របស់រដ្ឋាភិបាល ដែលតែងបង្កើតឱ្យមានយន្តការលើកទឹកចិត្តដល់វិនិយោគិនទាំងឡាយណាដែលគោរពច្បាប់របស់ប្រទេស និងជាប្រភេទធុរជនដែលមានអនុលោមភាពខ្ពស់។ ក្នុងនេះដែរ ការស្រាវជ្រាវក៏បានធ្វើការសិក្សាវិភាគរិះរកចំណុចល្អដែលបានអនុវត្តកន្លងមក និងចំណុចខ្វះខាតមួយចំនួនដែលគួរមានការកែលម្អផងដែរ។

ដោយយោងតាមរយៈការបង្ហាញនូវខ្លឹមសារនៃជំពូកនីមួយៗ យើងអាចធ្វើការសន្និដ្ឋានបានថា ពីមួយដំណាក់ការទៅមួយដំណាក់ការនៃការដាក់ចេញសម្រាប់អនុវត្តលើទំនិញនាំចូលគឺត្រូវបានធ្វើឡើងដោយមានទម្រង់បែបបទ និងគោរពទៅតាមច្បាប់ត្រឹមត្រូវចាប់តាំងពីពេលដែលទំនិញមកដល់ដែនកម្ពុជាភ្លាម។ អ្នកនាំចូលទាំងអស់ត្រូវធ្វើការរាយការណ៍នូវរាល់ទំនិញនាំចូលទាំងអស់ទៅដល់នាយកដ្ឋានគយ និងរដ្ឋាករ ដោយតម្រូវឲ្យធ្វើតាមនីតិវិធីដែលមានដូចជា ប្រតិវេទន៍គយ ការត្រួតពិនិត្យគយ ការបង់ពន្ធ និងអាករទៅតាមតម្លៃកំណត់ដែលមានទៅតាមប្រភេទទំនិញនាំចូលដែលត្រូវបានកំណត់ក្នុងតារាងពន្ធគយ។ ជាពិសេស ព្រមទាំងបានយល់ដឹងពីនីតិវិធីដែលត្រូវបានប្រើសម្រាប់ការនាំចូលនូវទំនិញក្រោមរូបភាពផ្សេងៗ ដូចជាទំនិញដែលមានលក្ខណៈពាណិជ្ជកម្ម ទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ ទំនិញគ្មានការទាមទារ ទំនិញលើកលែងពន្ធ និងនីតិវិធីពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចសេសជាដើម ហើយព្រមទាំងយល់ដឹងពីទោសទណ្ឌលើការនាំចូលខុសច្បាប់ថាបទល្មើសកម្រិតត្រូវទទួលរងនូវកម្រិតទោសបែបណា។ លើសនេះទៅទៀត យើងក៏បានយល់ដឹងពីរបៀបរបបនៃការបញ្ចេញទំនិញដោយប្រើប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (ASYCUDA) ដោយមានបង្ហាញពីមុខងារ និងតួនាទីនីមួយៗនៃការឆ្លងកាត់ច្រកទាំងបួនពណ៌យ៉ាងល្អិតល្អន់។

កត្តាដែលអាចធ្វើឲ្យមានការអនុវត្តនីតិវិធីនៃការគ្រប់គ្រងនេះឲ្យប្រព្រឹត្តទៅដោយប្រសិទ្ធភាព គឺដោយសារមានការជួយគាំទ្រពីសំណាក់រាជរដ្ឋាភិបាល ដោយបង្កើតនូវកំណែទម្រង់ជាច្រើនក្នុង

ន័យសម្រួលដល់ដំណើរការពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេសឲ្យមានភាពប្រសើរឡើងដើម្បីការអភិវឌ្ឍន៍ ដូចជាដាក់ឲ្យមានកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងនូវហានិភ័យ ការកាត់បន្ថយអត្រាពន្ធនាំចូល ការបង្កើតឲ្យមាននូវកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសក្នុងអាស៊ាន និងប្រទេសជាដៃគូ ព្រមទាំងការលើកលែងពន្ធ និងអាករក្រោមរបប កសិកម្ម ថ្នាំពេទ្យជាដើម។

ទន្ទឹមនឹងការរកឃើញនូវចំណុចល្អដែលជាគុណប្រយោជន៍សម្រាប់ប្រទេសជាតិទាំងមូល ភាពខ្វះចន្លោះ និងប្រសិទ្ធភាពនៃការអនុវត្តលើនីតិវិធីទាំងនោះនៅមានកម្រិតនៅឡើយ ពោលនីតិវិធីទាំងនោះនៅមានភាពស្មុគស្មាញ និងការសម្រួលពាណិជ្ជកម្មដល់ធុរជនមិនទាន់ដល់កម្រិតអតិបរមានៅឡើយ។ ហេតុដូចនេះទើបបានជាលេចចេញនូវអំពើរត់គេចពន្ធ និងការអ៊ូវត្ថុញត្តែររបស់វិនិយោគិននាំចូលក្នុងរូបភាពតូចៗមួយចំនួន។

សរុបសេចក្តីមកថ្វីត្បិតតែចំណុចខ្វះខាតមួយចំនួននៅតែមាន ប៉ុន្តែវាមិនមែនជាឧបសគ្គធ្ងន់ធ្ងរដល់ការអនុវត្តដល់ដំណើរការនៃការគ្រប់គ្រងទំនិញនាំចូលទៅមុខបាននោះឡើយ។ រដ្ឋាភិបាលបានព្យាយាមរិះរកមធ្យោបាយ និងធ្វើកំណែទម្រង់ជាបន្តបន្ទាប់ ដើម្បីដោះស្រាយនូវរាល់បញ្ហាដែលមានភាពមិនប្រក្រតីដែលអាចកើតមានឡើង និងស្វែងរកឱកាសផ្សេងៗដើម្បីជាផលប្រយោជន៍ដល់ប្រទេសជាតិតាមរយៈការចូលជាសមាជិកអាស៊ាន សមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងការចុះកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសជាដៃគូ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិទាំងមូល។

## ២. ការផ្តល់អនុសាសន៍

ទោះបីជាការអនុវត្តនូវនីតិវិធីនៃការគ្រប់គ្រងទំនិញនាំចូលនេះមានភាពរីកចម្រើនប្រកបដោយប្រសិទ្ធភាព និងត្រូវបានទទួលស្គាល់ ព្រមទាំងមានការជួយជ្រោមជ្រែងពីរដ្ឋាភិបាលក៏ពិតមែន តែបញ្ហាមួយចំនួននៅតែជួបប្រទះជាបន្តបន្ទាប់ នៅពេលដែលមានការអនុវត្តផ្ទាល់ ជាមួយនឹងអ្នកនាំចូល។ បន្ថែមពីនេះទៀត ករណីខ្លះហាក់មិនអំណោយផលដល់ដំណើរការប្រព្រឹត្តទៅនៃការអនុវត្តនូវនីតិវិធីនេះ ពីព្រោះធនធានមនុស្សដែលអាចប្រើប្រាស់បាននូវបច្ចេកវិទ្យានេះ នៅមានកម្រិតទាំងអ្នកដែលធ្វើការនាំចូល ទាំងអ្នកគ្រប់គ្រង ពោលគឺត្រូវការពេលវេលាដើម្បីសិក្សាទៅលើវាឲ្យមានភាពស្ទាត់ជំនាញ។ បន្ថែមពីនេះទៀត ការគ្រប់គ្រងទិន្នន័យក៏ជាកត្តាប្រឈមមួយដែរព្រោះនៅពេលដែលមានការពឹងផ្អែកទាំងស្រុងទៅលើប្រព័ន្ធវាអាចបង្កឲ្យមានហានិភ័យខ្ពស់។

មួយវិញទៀត អ្នកនាំចូលបានព្យាយាមប្រើប្រាស់មធ្យោបាយគ្រប់រូបភាព ដើម្បីគេចពីការធ្វើការរបស់មន្ត្រីមានសមត្ថកិច្ច ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចជាការរាយការណ៍ពីទំនិញ

របស់ខ្លួននៅពេលនាំចូល ការបង់ពន្ធ និងអាករជាដើម ដែលជាកត្តានាំឲ្យមានអំពើល្មើស ឬខុសច្បាប់ ហើយធ្វើការចែកចាយក្នុងតម្លៃទាប ដែលធ្វើឲ្យប៉ះពាល់ដល់តម្លៃទំនិញដទៃទៀត។ គួរគូសបញ្ជាក់ដែរថា ស្ថេរភាពប្រទេសជាតិគឺជារឿងមួយសំខាន់ណាស់ប្រសិនបើប្រទេសអសន្តិសុខសង្គម អស្ថេរភាពនយោបាយបង្កឲ្យមានជម្លោះ គ្រប់ស្ថាប័នមានការរង្គោះរង្គើ ការគ្រប់គ្រងមិនបានល្អ អំពើរត់គេចពន្ធមានការកើនឡើងកាន់តែច្រើន និងអនុវត្តការងារមានការធ្លាក់ចុះ នោះកម្ពុជានឹងឈានទៅរកស្ថានភាពមិនប្រសើរនោះទេ។

ដូច្នេះហើយអនុសាសន៍មួយចំនួនត្រូវបានរៀបចំឡើង ដើម្បីចូលរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពនៃនីតិវិធីដូចបានសិក្សាខាងលើ ដូចតទៅ:

- ការពង្រឹងនូវការអប់រំដល់ប្រជាជនកម្ពុជាឲ្យកាន់តែច្រើន និងជាពិសេសត្រូវធ្វើការណែនាំព្រមទាំងផ្តល់ជាវគ្គបណ្តុះបណ្តាលជាប្រចាំដល់អ្នកដែលពាក់ព័ន្ធ ដើម្បីអាចឲ្យពួកគេមានលទ្ធភាពក្នុងការស្វែងយល់ និងអនុវត្តប្រកបដោយប្រសិទ្ធភាព។
- ការទិញនូវប្រព័ន្ធសុវត្ថិភាព (security) ក្នុងការការពារប្រព័ន្ធ ដើម្បីកាត់បន្ថយនូវហានិភ័យពីការបាត់បង់ទិន្នន័យ ឬការលួចទិន្នន័យពីជនខាងក្រៅ។
- ណែនាំបន្ថែមឲ្យប្រជាជនយល់ច្បាស់អំពីសារៈសំខាន់នៃការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលមានទំនិញនាំចូល ពីព្រោះមិនមែនត្រឹមតែជាការបង់ពន្ធ និងអាករដែលចូលរួមចំណែកបង្កើតប្រាក់ចំណូលចូលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែក៏អាចឲ្យអ្នកនាំចូលបានគិតដល់នូវបញ្ហាមួយចំនួនទៀតដូចជាផ្នែកបរិស្ថាន សុខភាពរបស់ប្រជាជនទូទាំងប្រទេស ជាពិសេសឲ្យយល់ច្បាស់នូវទំនិញប្រភេទហាមឃាត់ដែលធ្វើក្នុងគោលបំណងផលប្រយោជន៍រួម។
- ណែនាំឲ្យប្រជាជនត្រៀមខ្លួននៅពេលដែលមានការចូលសមាហរណកម្មអាស៊ាន តាមរយៈការពង្រឹងសមត្ថភាពរបស់ខ្លួនទាំងការធ្វើការនៅក្នុងស្រុក និងក្រៅស្រុក ការប្រុងប្រយ័ត្នគ្រប់រូបភាពទៅលើការហូរចូលទំនិញគ្មានគុណភាពជាដើម។
- ការព្យាយាមកែលម្អ និងទទួលយកសំណូមពររបស់ធុរជនមកធ្វើការកែប្រែ ដើម្បីឈានទៅរកប្រសិទ្ធិភាពឲ្យកាន់តែមានភាពប្រសើរឡើង។

  ព្យាយាមកែប្រែចំណុចខ្វះខាតដែលនៅសេសសល់ទាំងឡាយ។

# ឯកសារយោង

# ឯកសារយោង

## ឯកសារយោងជាភាសាខ្មែរ


១. ច្បាប់ស្តីពីគយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧

២. កិច្ចព្រមព្រៀង ATIGA ចុះខែកុម្ភៈ ឆ្នាំ២០០៩ ដែលបង្កើតឡើងដោយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

៣. អនុក្រឹត្យលេខ២០៩ អនក្រ.បក ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧

៤. អនុក្រឹត្យលេខ២១ អនក្រ.បក ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦

៥. ប្រកាសលេខ ១០៥ សហវ.ប្រក ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨

៦. ប្រកាសលេខ ៣៨៧ សហវ.គរ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨

៧. ប្រកាសលេខ ៣៨៨ សហវ.គរ ស្តីពីសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយដោយទីចាត់ការគយ និងរដ្ឋាករ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨

៨. ប្រកាសលេខ ៧៣៤ សហវ.ប្រក ស្តីពីនីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨

៩. សារាចរណែនាំស្តីពីការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ លេខ០០៧ សហវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧

១០.សៀវភៅតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ដោយអគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជា

១១.សៀវភៅច្បាប់ និងបទប្បញ្ញត្តិគយ បោះពុម្ពលើកទី៣ ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឆ្នាំ២០១១

១២.សៀវភៅបទប្បញ្ញត្តិពាក់ព័ន្ធនឹងទំនិញពន្ធអាករជាបន្ទុករដ្ឋ បញ្ជីទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ បោះពុម្ពដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឆ្នាំ២០១៦

១៣.សៀវភៅយន្តការភាពជាដៃគូគយ-ផ្នែកឯកជន បោះពុម្ពដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ខែកក្កដា ឆ្នាំ២០១៥

១៤. សៀវភៅកម្រងអត្ថបទនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ បោះផ្សាយដោយអគ្គនាយដ្ឋានគយនិងរដ្ឋាករ ខែតុលា ឆ្នាំ២០១៥
១៥. សៀវភៅគោលការណ៍សេដ្ឋកិច្ច រៀបរៀងដោយលោក ស៊ុំ សុចិន្ដា ឆ្នាំ២០១១
១៦. សៀវភៅសំណួរ-ចម្លើយអាស៊ាន រៀបរៀងដោយលោក គង់ សុខហេង ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៩,ទំព័រទី២
១៧.វចនានុក្រមខ្មែរ ភាគ១ ភាគ២, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស២៥១២ គ.ស១៩៨៦
១៨. សន្ទានុក្រមពាក្យច្បាប់ និងធុរកិច្ច បោះពុម្ពលើកទី១ ដោយលោក ម៉ឹក គឹមស្រួយ, ឆ្នាំ២០១៥
១៩.របាយការណ៍ស្ថិតិប្រចាំឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម
២០. របាយការណ៍កិច្ចប្រជុំយន្តការភាពជាដៃគូគយ ផ្នែកឯកជនលើកទី៥,សំណូមពរទី១១,សំណូមពរទី៨, នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥

## ឯកសារជាភាសាបរទេស

1. Steve Suranovic , International Trade Theory And Policy,(May 2010), Publisher: Saylor Foundation
2. Harri Daniel, Benefits of International Trade, benefitof.net/benefits-of-international-trade ,(March 16, 2011)
3. Charles W.L. Hill ,International Business, New York Magraw,2002
4. Mason A. Carpenter and Sanjyot P. Dunung, Challenges and Opportunities in International Business, Chapter 2: International Trade and Foreign Direct Investment,(2012)
5. John J. Wild, Kenneth L. Wild and Jerry C. Y. Han, International Business , (2003)

## ឯកសារពីគេហទំព័រ

- http://www.econlib.org/library/Topics (ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧)
- www.businessdictionary.com (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧)
- http://en.wikipedia.org/wiki/International-Trade (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧)
- http://en.wikipedia.org/wiki/Theory International-Trade(ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧)
- http://en.wikipedia.org/wiki/import (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧)

- http://en.wikipedia.org/wiki/ Benefit of International-Trade(ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧)
- https://en.wikipedia.org/wiki/Incoterm&source (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧)
- htt://Investasean.asean.org/asean-trade-in-goods-agreement.html (ថ្ងៃទី២៨ មិថុនា ឆ្នាំ២០១៧)
- http://www.customs.gov.kh/អត្រាពន្ធ (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧)
- http://www.customs.gov.kh/នីតិវិធីពិសេស/ធុរជនល្អបំផុត (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧)
- http://asean.org/static_post=rcep-regional-comprehensive-economic-Partnership (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧)
- http://www.freshnewsasia.com/index.php/en/localnews/57267-2017-06-13 (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧)
- https://www.wto.org/(ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៧)

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ៩០ សជណ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-**

ដាក់ឲ្យប្រើប្រាស់នូវបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ដែលរួមមាន មុខទំនិញចំនួន ១៥៣៧ បន្ទាត់អត្រាពន្ធនៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០០៧ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលគ្រប់ខេត្ត ក្រុង និងគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ៨ ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# ឧបសម្ព័ន្ធ ១

នៃអនុក្រឹត្យលេខ ២០៩... អនក្រ.បក ចុះថ្ងៃទី ៣១... ខែ ...ធ្នូ.... ឆ្នាំ ២០០៩

## បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ក្នុងការនាំចេញ ឬនាំចូល

| ល.រ | លេខកូដ | បរិយាយ | ប្រព្រឹត្តកម្មនៃការនាំចេញ នាំចូល | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | MIME | MOH | MOC | MAFF | NBC | MOE | MOI | CDC | MEF | MOCFA | MPTC | MOD | Other |
| 1 | 0101.10.00 | - សេះពូជ | | | | (2) (3) (7) | | | | | | | | | |
| 2 | 0101.90.30 | - - សេះ | | | | (2) (3) (7) | | | | | | | | | |
| 3 | 0101.90.90 | - - ផ្សេងទៀត | | | | (2) (3) (7) | | | | | | | | | |
| 4 | 0102.10.00 | - គោ ក្របីពូជ | | | | (2) (3) (7) | | | | | | | | | |
| 5 | 0102.90.10 | - - គោ | | | | (2) (3) (7) | | | | | | | | | |
| 6 | 0102.90.20 | - - ក្របី | | | | (2) (3) (7) | | | | | | | | | |
| 7 | 0102.90.90 | - - ផ្សេងទៀត | | | | (2) (3) (7) | | | | | | | | | |
| 8 | 0103.10.00 | - ជ្រូកពូជ | | | | (2) (3) (7) | | | | | | | | | |
| 9 | 0103.91.00 | - - ជ្រូកដែលមានទំងន់តិចជាង ៥០ គីឡូក្រាម | | | | (2) (3) (7) | | | | | | | | | |
| 10 | 0103.92.00 | - - ជ្រូកដែលមានទំងន់ ៥០ គីឡូក្រាម ឬលើស | | | | (2) (3) (7) | | | | | | | | | |
| 11 | 0104.10.10 | - - ចៀមពូជ | | | | (2) (3) (7) | | | | | | | | | |
| 12 | 0104.10.90 | - - ចៀមផ្សេងទៀត | | | | (2) (3) (7) | | | | | | | | | |
| 13 | 0104.20.10 | - - ពពែពូជ | | | | (2) (3) (7) | | | | | | | | | |
| 14 | 0104.20.90 | - - ផ្សេងទៀត | | | | (2) (3) (7) | | | | | | | | | |
| 15 | 0105.11.10 | - - - មាន់ពូជ | | | | (2) (3) (7) | | | | | | | | | |
| 16 | 0105.11.90 | - - - មាន់ផ្សេងទៀត | | | | (2) (3) (7) | | | | | | | | | |
| 17 | 0105.12.10 | - - - មាន់បារាំងពូជ | | | | (2) (3) (7) | | | | | | | | | |
| 18 | 0105.12.90 | - - - ផ្សេងទៀត | | | | (2) (3) (7) | | | | | | | | | |
| 19 | 0105.19.10 | - - - សត្វទាពូជ | | | | (2) (3) (7) | | | | | | | | | |

# ឧបសម្ព័ន្ធ ២

នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧

## សេចក្ដីពន្យល់ និងកំណត់សម្គាល់សម្រាប់ការអនុវត្ត
## បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

**I- និយមន័យ ៖**

ទំនិញជាប់អាយ័ត និងទំនិញជាប់កម្រិតកំណត់គឺជាទំនិញដែលស្ថិតក្រោមល័ក្ខខ័ណ្ឌលើការនាំចេញ ឬនាំចូលក្នុងគោលបំណងណាមួយដូចជា ៖

- ការការពារសន្តិសុខជាតិ
- ការការពារសណ្ដាប់ធ្នាប់សាធារណៈ និងស្ដង់ដារនៃសុការធម៌ និងសីលធម៌
- ការការពារសុខភាព និងជីវិតមនុស្ស សត្វ ឬរុក្ខជាតិ
- ការការពារបេតិកភណ្ឌជាតិ ដែលមានតម្លៃខាងសិល្បៈ ប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យា
- ការអភិរក្សធនធានធម្មជាតិ
- ការតម្រូវតាមបញ្ញត្តិនានានៃច្បាប់ណាមួយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ការបំពេញកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិ ។

បញ្ជីទំនិញនេះត្រូវកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ស្របតាមបញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្ដីពីគយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ។

ការនាំចេញ ឬនាំចូលទំនិញក្នុងបញ្ជីនេះជាកម្មវត្ថុនៃ ៖

- ការហាមឃាត់ដាច់ខាតមិនឲ្យធ្វើការនាំចេញ ឬនាំចូល
- ការអនុញ្ញាតឲ្យនាំចេញ ឬនាំចូលដោយតម្រូវឲ្យមានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនប័ត្រផ្សេងៗ ព្រមទាំងឯកសារគតិយុត្តិដែលមានទម្រង់ប្រហាក់ប្រហែលជាមុន ឬស្ថិតក្រោមប្រព្រឹត្តិកម្មដោយឡែកមួយចំនួនពីអាជ្ញាធរមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលរួមមាន ក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចពាក់ព័ន្ធស្របតាមច្បាប់ ឬបទប្បញ្ញត្តិនានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**II- កំណត់សំគាល់៖**

១- បញ្ជីនេះមិនអនុវត្តចំពោះការនាំចេញ ឬនាំចូលដែលគ្មានលក្ខណៈពាណិជ្ជកម្មតាមរូបភាពជា ទំនិញគំរូ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកធ្វើដំណើរ សម្ភារៈផ្លាស់ប្ដូរលំនៅដ្ឋាន ឬតាមរូបភាពប្រហាក់ប្រហែល ។ ការលើកលែងនេះ មិនអនុវត្តចំពោះមុខ

ទំនិញដែលស្ថិតក្រោមមុខសញ្ញាហាមឃាត់ដាច់ខាតក្នុងការនាំចេញ នាំចូល ឬប្រភេទមានហានិភ័យខ្ពស់ដល់សុវត្ថិភាពសាធារណៈ ។

២- ផលិតផលមានដើមកំណើតពីសត្វដែលស្ថិតក្នុងបញ្ជីសាយតេស ប៉ុន្តែមិនមានបញ្ជាក់ច្បាស់ក្នុងតារាងនេះដោយហេតុផលបច្ចេកទេសនោះ ត្រូវមានលិខិតអនុញ្ញាតសាយតេស ។

៣- ដោយសារហេតុផលបច្ចេកទេសនៃតារាងពន្ធគយ បញ្ជីនេះមិនបានដាក់បញ្ចូលនូវមុខទំនិញជាប់អាយ័ត និងទំនិញជាប់កម្រិតកំណត់ដូចខាងក្រោម ៖

- រថយន្តចង្កូតស្តាំ
- ទំនិញប្រើរួចមួយចំនួនដូចជា កំព្យូទ័រ ស្បែកជើង កាបូប អាគុយ ជាដើម
- សៀវភៅសាសនា សៀវភៅនយោបាយ រូបភាពអាសអាភាស រូបភាពពាណិជ្ជកម្ម និងឯកសារបោះពុម្ពដែលច្បាប់ហាមឃាត់ផ្សេងទៀត
- ទំនិញល្មើសច្បាប់កម្មសិទ្ធិបញ្ញា (IPR Law) ឬទំនិញក្លែងក្លាយ និងទំនិញល្មើសសិទ្ធិផ្តាច់មុខ

៤- បរិក្ខា ឬឧបករណ៍បច្ចេកទេសបម្រើឲ្យការហោះហើរ ត្រូវមានការឯកភាពជាមុនពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ។

៥- ឧបករណ៍ត្រជាក់ប្រភេទប្រើរួចគ្រប់ប្រភេទ ឬប្រភេទថ្មីដែលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន ត្រូវមានការអនុញ្ញាតឲ្យនាំចូលពីក្រសួងបរិស្ថាន ។

៦- ទំនិញនាំចូលត្រូវគោរពតាមវិធានស្តង់ដារឧស្សាហកម្មកម្ពុជា និងវិធានគុណភាព និងសុវត្ថិភាព

៧- ចំពោះពូជដំណាំ ឬគ្រាប់ពូជផ្សេងទៀតដែលពុំមានចែងក្នុងបញ្ជីនេះ ត្រូវទទួលនូវប្រព្រឹត្តកម្មដូចគ្នាជាមួយពូជដំណាំ ឬគ្រាប់ពូជក្នុងបញ្ជីនេះដែរ ស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងសម្ភារៈកសិកម្ម ។

៨- ចំពោះប្រភេទទំនិញនាំចេញណា ដែលប្រទេសនាំចូលតម្រូវឲ្យមានវិញ្ញាបនប័ត្របញ្ជាក់សុខភាពសត្វ វិញ្ញាបនប័ត្រភូតគាមអនាម័យ វិញ្ញាបនប័ត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផល ឬវិញ្ញាបនប័ត្រផ្សេងៗទៀត អ្នកនាំចេញត្រូវស្នើសុំវិញ្ញាបនប័ត្រទាំងនោះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ស្របតាមការតម្រូវនៃប្រទេសនាំចូលនោះ ។

៩- ចំពោះការនាំចេញធនធានរ៉ែ ត្រូវមានការអនុញ្ញាតឲ្យនាំចេញពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

១០- ចំពោះទំនិញក្នុងជំពូកទី ២៨ និងជំពូកទី ២៩ ណាដែលជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ និង/ឬដែលមានចែងក្នុងបញ្ជីនៃសារធាតុផ្សំគ្រឿងញៀន បញ្ជីនៃសារធាតុប៉ះពាល់ដល់សរសៃប្រសាទ និងបញ្ជីគ្រឿងញៀន ត្រូវមានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។ ដោយឡែកចំពោះទំនិញក្នុងជំពូកទី ២៨ និងជំពូកទី ២៩ ណាដែលពុំមានចែងក្នុងបញ្ជីទាំងបីនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

១១- ចំពោះបសុឱសថដែលពុំមានចែងច្បាស់លាស់នៅក្នុងបញ្ជីនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

១២- ប្រសិនបើមានការអនុញ្ញាតឲ្យនាំចេញ ឬនាំចូលពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការនាំចេញ ឬនាំចូលអាចធ្វើទៅបាន ដោយពុំចាំបាច់មានការអនុញ្ញាតពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតឡើយ លើកលែងតែទំនិញដែលស្ថិតក្រោមកម្រិតកំណត់នៃការដឹកជញ្ជូន ដោយហេតុផលសន្តិសុខ និងសុវត្ថិភាពសាធារណៈ ។

១៣- យោងតាមសំណូមពរនៃការគ្រប់គ្រង ត្រួតពិនិត្យជាក់ស្តែង ការធ្វើវិមជ្ឈការការងារ និងលទ្ធភាពនៃប្រព័ន្ធតភ្ជាប់ព័ត៌មាន ទំនិញក្នុងបញ្ជីនេះ ដែលទទួលបានការអនុញ្ញាតឲ្យនាំចេញ ឬនាំចូលរួចហើយពីក្រសួង ស្ថាប័នមានសមត្ថកិច្ច តាមរូបភាពជាកញ្ចប់សម្រាប់ការនាំចេញ ឬនាំចូលច្រើនដង និង/ឬតាមមាត់ច្រកលើសពីមួយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យដោយឡែកជាបណ្តោះអាសន្នពីទីចាត់ការគយ និងរដ្ឋាករ និង/ឬពីនាយកដ្ឋានកាំកុងត្រូល ។

## III- លេខសំគាល់ប្រព្រឹត្តកម្ម:

(1) : ត្រូវបំពេញបែបបទនាំចេញ-នាំចូលតាមនីតិវិធីជាធរមាន ដោយគ្រាន់តែតម្រូវឲ្យតម្កល់ឯកសាររដ្ឋបាលតែមួយ (Single Administrative Document – SAD) នៅពេលបំពេញបែបបទនាមាត់ច្រកនាំចេញ ឬនាំចូលតែម្តង និងមានឯកសារភ្ជាប់ជាមួយឯកសាររដ្ឋបាលតែមួយរួមមាន វិកយប័ត្រពាណិជ្ជកម្ម ឯកសារដឹកជញ្ជូន បញ្ជីវេចខ្ចប់ និងឯកសារចាំបាច់ផ្សេងទៀតប្រសិនបើមានការតម្រូវ និងពុំតម្រូវឲ្យមានការអនុញ្ញាតជាមុននាពេលនាំចេញ ឬនាំចូលឡើយ លើកលែងតែទំនិញនេះស្ថិតក្រោមរបបលើកលែង ឬព្យួរទាំងស្រុង ឬជាភាគនៃពន្ធ និងអាករ ឬរបបអនុគ្រោះផ្សេងទៀត ។

(2) : ត្រូវមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតឲ្យនាំចូល ឬលិខិតគតិយុត្តិប្រហាក់ប្រហែលពីក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននេះ ។

(3) : ត្រូវមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតឲ្យនាំចេញ ឬលិខិតគតិយុត្តិប្រហាក់ប្រហែលពីក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននេះ។

(4) : ត្រូវបានហាមឃាត់ដាច់ខាតសម្រាប់ការនាំចូល

(5) : ត្រូវបានហាមឃាត់ដាច់ខាតសម្រាប់ការនាំចេញ

(6) : ត្រូវបានហាមឃាត់ដាច់ខាតទាំងការនាំចេញ និងនាំចូល

(7) : ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សុខភាពសត្វតាមការតម្រូវរបស់ប្រទេសនាំចូល

(8) : ត្រូវមានវិញ្ញាបនប័ត្រកូតតាមអនាម័យតាមការតម្រូវរបស់ប្រទេសនាំចូល

(9) : ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់គុណភាពផ្នែកពេគសាស្ត្រផលផលរបស់ប្រទេសនាំចេញ

## IV– របៀបអានបញ្ជីនេះ ៖

១- អក្សរកាត់៖

| | |
|---|---|
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIMIE | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOCFA | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| MOD | ក្រសួងការពារជាតិ |
| MOE | ក្រសួងបរិស្ថាន |
| MOH | ក្រសួងសុខាភិបាល |
| MOI | ក្រសួងមហាផ្ទៃ |
| NBC | ធនាគារជាតិនៃកម្ពុជា |
| SAD | ឯកសាររដ្ឋបាលតែមួយ |

២- ត្រូវពិនិត្យមើលថាតើលេខសំគាល់ប្រព្រឹត្តកម្មនោះ ស្ថិតនៅក្នុងជួរឈរដែលមានឈ្មោះក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធណា។

ឧទាហរណ៍ ៖ បើលេខ (2) ស្ថិតនៅក្នុងជួរឈរនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) នោះមានន័យថាត្រូវមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតអោយនាំចូល ឬលិខិតគតិយុត្តិប្រហាក់ប្រហែលពីក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

៣- ចំពោះប្រព្រឹត្តកម្មលេខរៀងទី (4) (5) និង (6) គឺជាប្រព្រឹត្តកម្មហាមឃាត់ដាច់ខាត មិនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នជំនាញណាមួយឡើយ ហើយស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាលកម្ពុជា។

**********************

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៩៥៥៧ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## បញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ

### ទេសរដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ ១.-

រាល់ទំនិញនាំចេញ ឬនាំចូលទោះជាជាប់ពន្ធ និងអាករក្តី ឬត្រូវបានលើកលែងពន្ធ និងអាករ ទំនិញទាំងនោះត្រូវតែជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍គយ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ប្រតិវេទន៍គយគឺជាឯកសាររដ្ឋបាលតែមួយ (Single Administrative Document –SAD) ដែលមានកំណត់ពន្យល់ដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃប្រកាសនេះ ។

នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ទម្រង់ប្រតិវេទន៍គយផ្សេងទៀតសម្រាប់តម្រូវការនៃការនាំចេញ នាំចូលរបស់អ្នកដំណើរ កញ្ចប់ប្រៃសណីយ៍ និងគោលបំណងផ្សេងទៀតតាមការចាំបាច់ ។

ប្រតិវេទន៍គយ ដែលត្រូវបានចុះបញ្ជិកាដោយគយ គឺជាឯកសារត្រឹមត្រូវតាមច្បាប់តែមួយគត់ ដែលអាចត្រូវបានយកទៅប្រើប្រាស់ ដើម្បីជូនជាសំអាងថា ទំនិញនោះត្រូវបាននាំចូលមកក្នុង ឬត្រូវបាននាំចេញពីកម្ពុជា ។

**ប្រការ ២.-**

ប្រតិវេទន៍គយ ត្រូវដាក់នៅការិយាល័យគយមានការអនុញ្ញាត ដែលកំណត់ដោយនាយកទីចាត់ការគយនិងរដ្ឋាករ ។

ប្រតិវេទន៍គយ អាចត្រូវបានដាក់នៅការិយាល័យគយ មុនពេលការមកដល់នៃទំនិញប្រសិនបើមានការអនុញ្ញាតជាមុនពីទីចាត់ការគយ និងរដ្ឋាករ ។

ចំពោះការនាំចូល:

ក. នៅពេលដែលទំនិញមិនត្រូវបានរាយការណ៍ដល់គយនៅលើប្រតិវេទន៍បំពេញ ប្រតិវេទន៍គយត្រូវដាក់នៅការិយាល័យគយនាពេលដែលទំនិញមកដល់ វៀរលែងតែមានការអនុញ្ញាតឲ្យដាក់ប្រតិវេទន៍មុនពេលទំនិញមកដល់ ស្របតាមកថាខ័ណ្ឌ ២ នៃប្រការនេះ ។ ប្រសិនបើទំនិញមកដល់មុនពេលចាប់ផ្តើមប្រតិបត្តិការរបស់ការិយាល័យគយ ប្រតិវេទន៍គយត្រូវតែដាក់ភ្លាមនៅពេលចូលធ្វើការ ។

ខ. ក្នុងករណីដែលទំនិញត្រូវបានរាយការណ៍ដល់គយនៅលើប្រតិវេទន៍បំពេញ ប្រតិវេទន៍គយត្រូវតែដាក់នៅការិយាល័យគយក្នុងរយៈពេលបី (៣) ថ្ងៃគត់ បន្ទាប់ពីទំនិញមកដល់ វៀរលែងតែទំនិញនោះត្រូវបានដាក់បញ្ចូលក្នុងសន្និធិគយបណ្តោះអាសន្ន ឬត្រូវបានដាក់ក្រោមនីតិវិធីឆ្លងកាត់ ។

ចំពោះការនាំចេញ ប្រតិវេទន៍គយត្រូវដាក់ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌ ក កថាខ័ណ្ឌ ៣ នៃប្រការនេះ ដោយរាប់បញ្ចូលទាំងការដាក់ប្រតិវេទន៍គយមុនពេលទំនិញមកដល់ ។

**ប្រការ ៣.-**

ទំនិញនាំចេញ ឬនាំចូល ត្រូវប្រកាសដោយម្ចាស់ទំនិញ ឬដោយបុគ្គលដែលបានទទួលការអនុញ្ញាតឲ្យបំពេញបែបបទគយក្នុងនាមម្ចាស់ទំនិញ ។

បុគ្គលដែលបានទទួលការអនុញ្ញាតឲ្យបំពេញបែបបទគយ រួមមាន ៖

- បុគ្គលដែលបានទទួលកាអនុញ្ញាតជាជើងសារគយ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- បុគ្គលណាដែលគ្មានវិជ្ជាជីវៈជាជើងសារគយ អាចបំពេញប្រតិវេទន៍គយបានសម្រាប់អាជីវកម្មរបស់ខ្លួន ។ បុគ្គលនេះ អាចទទួលបានការអនុញ្ញាតឲ្យបញ្ចេញទំនិញពីគយសម្រាប់អ្នកដទៃបាន សម្រាប់ប្រតិបត្តិការពាក់ព័ន្ធនឹងទំនិញដោយឡែកមួយចំនួនជាបណ្តោះអាសន្ន ប្រសិនបើមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤.-**

ប្រតិវេទន៍គយ ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ ឬ តាមមធ្យោបាយអេឡិចត្រូនិក។ បញ្ញត្តិ និងលក្ខខណ្ឌ សម្រាប់ការដាក់ប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធតាមមធ្យោបាយអេឡិចត្រូនិកមានចែងក្នុងឧបសម្ព័ន្ធ ខ នៃប្រកាសនេះ ។

សម្រាប់គោលបំណងនៃការអនុវត្តច្បាប់ និងបទបញ្ញត្តិគយជាធរមាន និងសម្រាប់គោលបំណងស្ថិតិ ប្រតិវេទន៍គយ ត្រូវមានចុះរាល់សូចនាចាំបាច់ស្របតាមការកំណត់ពន្យល់ដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃប្រកាសនេះ និងបណ្តាសេចក្តីណែនាំដែលចេញដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

ឯកសារភ្ជាប់ជាមួយប្រតិវេទន៍គយ រួមមាន ៖ វិក្កយប័ត្រទំនិញ បញ្ជីវេចខ្ចប់ និងឯកសារដឹកជញ្ជូន ។ ក្នុងករណីចាំបាច់ និវេទន៍ប័ណ្ណ អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនប័ត្រដើមកំណើត វិញ្ញាបនប័ត្រធានារ៉ាប់រង និងឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវភ្ជាប់ជាមួយប្រតិវេទន៍គយ ។

ក្នុងករណីខ្លះ នាយកទីចាត់ការគយ និងរដ្ឋាករ អាចសម្រេចអនុញ្ញាតឲ្យប្រកាសដោយផ្ទាល់មាត់ជំនួសការប្រកាសជាលាយល័ក្ខអក្សរ ។

ប្រតិវេទន៍គយត្រូវតែមានចុះហត្ថលេខាដោយប្រតិវេទករ ។

**ប្រការ ៥.-**

កាលបើទំនិញច្រើនមុខ ត្រូវបានបំពេញក្នុងប្រតិវេទន៍គយតែមួយមុខទំនិញនីមួយៗ ត្រូវបានចាត់ទុកជាកម្មវត្ថុនៃការប្រកាសដោយឡែក ។ មុខទំនិញ នីមួយៗ ត្រូវតែចុះដោយឡែកពីគ្នា និងត្រូវចុះលេខសំគាល់ចំណាត់ថ្នាក់ទំនិញឲ្យបានត្រឹមត្រូវតាមតារាងពន្ធគយជាធរមាន ។

**ប្រការ ៦.-**

កាលបើបុគ្គលមាននីតិសម្បទាធ្វើប្រតិវេទន៍គយ មិនមានព័ត៌មានគ្រប់គ្រាន់សម្រាប់បំពេញប្រតិវេទន៍គយ បុគ្គលនោះអាចត្រូវបានអនុញ្ញាតឲ្យពិនិត្យទំនិញ និងដកទំនិញគំរូមុនពេលបំពេញប្រតិវេទន៍គយ ។ បុគ្គលនោះត្រូវដាក់ប្រតិវេទន៍បណ្តោះអាសន្នជូនគយ ដែលទោះជាក្នុងករណីណាក៏ដោយបុគ្គលនោះមិនអាចរួចផុតពីកាតព្វកិច្ចបំពេញប្រតិវេទន៍គយដែរ ។

ត្រូវហាមឃាត់ដល់រាល់សហត្ថកម្ម ដែលអាចបណ្តាលឲ្យប្រែប្រួលសភាពដើម ឬលក្ខណៈនៃទំនិញដែលជាកម្មវត្ថុនៃការបំពេញប្រតិវេទន៍បណ្តោះអាសន្ន ។

ទម្រង់ប្រតិវេទន៍បណ្តោះអាសន្ន និងលក្ខខណ្ឌនៃការត្រួតពិនិត្យទំនិញមុនពេលបំពេញប្រតិវេទន៍គយត្រូវកំណត់ដោយសេចក្តីសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៧.-**

ប្រតិវេទន៍គយដែលបានបំពេញត្រឹមត្រូវ និងគ្រប់គ្រាន់ ព្រមទាំងមានភ្ជាប់ជាមួយនូវឯកសារចាំបាច់នានានឹងត្រូវទទួលយកបាន និង ចុះបញ្ជិកាភ្លាមដោយគយ ។

ត្រូវចាត់ទុកថា ជាប្រតិវេទន៍គយដែលមិនអាចទទួលយកបាន និងមិនត្រូវ

បានចុះបញ្ជិកាដោយគយ បណ្តាប្រតិវេទន៍ដែលខុសទម្រង់ ដែលបំពេញមិនបានត្រឹមត្រូវ និងគ្រប់គ្រាន់ ឬមិនបានភ្ជាប់ជាមួយនូវឯកសារចាំបាច់នានា ។ នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវកំណត់នូវលក្ខខណ្ឌនៃការទទួលយកបាននៃប្រតិវេទន៍គយ ។

**ប្រការ ៨.-**

ក្រោយពេលចុះបញ្ជិកាប្រតិវេទន៍គយ ប្រតិវេទករ អាចធ្វើការកែតម្រូវប្រតិវេទន៍គយ តែនៅថ្ងៃចុះបញ្ជិកាប្រតិវេទន៍ និងមុនពេលចាប់ផ្តើមត្រួតពិនិត្យទំនិញជារូបវ័ន្តប៉ុណ្ណោះ ។ ការកែតម្រូវព័ត៌មានអំពី បរិមាណ និងតម្លៃ និងការតម្រូវដែលធ្វើឡើងក្រោយថ្ងៃចុះបញ្ជិកាប្រតិវេទន៍ តម្រូវឲ្យមានការអនុញ្ញាតជាមុនពីទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៩.-**

ក្រោយពេលចុះបញ្ជិកាប្រតិវេទន៍គយ និងមុនពេលត្រួតពិនិត្យទំនិញជារូបវ័ន្ត មន្ត្រីគយត្រូវត្រួតពិនិត្យប្រតិវេទន៍គយដើម្បីផ្ទៀងផ្ទាត់ពីភាពគ្រប់គ្រាន់ និងភាពត្រឹមត្រូវនៃព័ត៌មានដែលបានប្រកាសលើប្រតិវេទន៍គយ រួមមាន ដើមកំណើតចំណាត់ថ្នាក់ទំនិញ តម្លៃគិតពន្ធគយ របបគយ និងចំនួនប្រាក់ពន្ធ និងអាករដែលត្រូវបង់ ។ មន្ត្រីគយត្រូវផែកពិនិត្យផងដែរនូវតម្រូវការចាំបាច់នានា ប្រសិនបើទំនិញនោះជាប្រភេទត្រូវបានហាមឃាត់ ឬជាប់កម្រិតកំណត់ ។

**ប្រការ ១០.-**

ការកែតម្រូវ ការបន្ថែម ការលុប ការបែងចែក និងការគ្រប់គ្រង សុពលភាព និងបណ្តាតម្រូវការផ្សេងទៀតនៃប្រតិវេទន៍ និងបណ្តាឯកសារគយត្រូវធ្វើឡើងតាមទម្រង់ និងរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ១១.-**

បន្ទាប់ពីបានត្រួតពិនិត្យឯកសារប្រតិវេទន៍គយ មន្ត្រីគយអាចធ្វើការត្រួត

ពិនិត្យជារូបវ័ន្តទាំងស្រុង ឬភាគខ្លះនៃទំនិញដែលបានប្រកាស ប្រសិនបើយល់ថាជាការចាំបាច់ដោយផ្អែកលើការវាយតម្លៃហានិភ័យ ។

ក្នុងករណីដែលមន្ត្រីគយមិនបានធ្វើការត្រួតពិនិត្យជារូបវ័ន្តលើទំនិញ ពន្ធ និងអាករ និងនីតិវិធីគយផ្សេងទៀតត្រូវអនុវត្តផ្អែកលើសេចក្តីបរិយាយ និងព័ត៌មាននានានៅលើប្រតិវេទន៍គយ និងឯកសារភ្ជាប់ ។

**ប្រការ ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៣.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយក ទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១៣
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ «ក»

## I. កំណត់ពន្យល់ប្រភេទទន៍គយនាំចូល (ឯកសាររដ្ឋបាលតែមួយ)

ឯកសាររដ្ឋបាលតែមួយ (SAD) គឺជាឯកសារតែមួយប្រើសម្រាប់គ្រប់របបបញ្ចេញទំនិញពីគយ ការនាំចូល ការនាំចេញ ភណ្ឌាគារគយ ។ល។ ផ្នែកនេះបង្ហាញលំអិតអំពីរបៀបបំពេញ SAD សំរាប់ប្រតិវេទន៍គយនាំចូល ។ ប្រតិវេទន៍គយនាំចូលរួមមាន:

- ការនាំចូលស្ថាពរ (ដោយផ្ទាល់) / ការនាំចូលដើម្បីប្រើប្រាស់ក្នុងស្រុក - IM4
- ការនាំចូលបណ្ដោះអាសន្ន - IM5
- ការនាំចូលមកវិញ - IM6
- ការនាំចូលក្នុងភណ្ឌាគារគយ - IM7
- ឆ្លងកាត់ - IM8
- តំបន់រួចពន្ធ / តំបន់សេដ្ឋកិច្ចពិសេស - IM9

ប្រអប់និមួយៗនៃ SAD ត្រូវបានរៀបចំឡើង ដែលជាការបញ្ចូលចាំបាច់ (វាត្រូវតែបំពេញ) បញ្ចូលដោយជ្រើសរើស(បំពេញប្រសិនបើមានពាក់ព័ន្ធ) ឬក្នុងករណីខ្លះប្រអប់អាចមិនចាំបាច់បំពេញ(មិនត្រូវការប្រើប្រាស់)។

ផ្នែកខាងក្រោមនេះ រៀបរាប់លំអិតពីគោលបំណងនៃប្រអប់និមួយៗនៃ SAD នៅពេលអនុវត្តប្រតិវេទន៍គយនាំចូល។ ប្រអប់និមួយៗត្រូវបានបរិយាយពីលំដាប់នៃការបញ្ចូលព័ត៌មាន ថាតើវាជាប្រអប់ចាំបាច់ ឬជាប្រអប់ជម្រើស។ ប្រអប់ខ្លះ តម្រូវឱ្យបញ្ចូលលេខកូដយោង ឬឈ្មោះតំណាងអោយព័ត៌មានយោងតាមស្តង់ដារ។ កូដយោងប្រើក្នុងកំណត់ពន្យល់នេះនឹងចេញដោយទីចាត់ការគយ និងរដ្ឋាករ។

**ការពន្យល់នៃប្រអប់ SAD សំរាប់ប្រភេទទន៍នាំចូល**

| លេខប្រអប់ | ស្លាកសញ្ញាប្រអប់ | សកម្មភាព | បរិយាយ និង / ឬ ការប្រើប្រាស់ |
|---|---|---|---|
| 1 | ប្រភេទប្រតិវេទន៍ | ចាំបាច់ | ដើម្បីកំណត់ថាតើប្រតិវេទន៍ទំនិញត្រូវបានដាក់សំរាប់ការនាំចូល ការនាំចេញ ឬ ក៏ជាការឆ្លងកាត់គយ។<br>លេខតំរូប្រតិវេទន៍ត្រូវបានដាក់បញ្ចូលលើទម្រង់ SAD ក្នុងប្រអប់នេះ។<br>សំរាប់ប្រតិវេទន៍នាំចូលទាំងអស់ តំរូវនេះគឺ "IM" ជាមួយនឹងលេខ ដើម្បីកំណត់ថាតើរបបមួយណាជាការនាំចូល ឧទាហរណ៍លេខ ៤ សំរាប់ (នាំចូលប្រើប្រាស់ក្នុងស្រុក) លេខ ៧ សំរាប់ (ស្តុកក្នុងឃ្លាំង)។ល។ |
| A: | ការិយាល័យដាក់ប្រតិវេទន៍: ការិយាល័យគយដែលប្រតិវេទន៍ត្រូវបានដាក់ជូនមន្ត្រីគយពិនិត្យ | | |
| | កូដការិយាល័យ | ចាំបាច់ | កូដនិងឈ្មោះការិយាល័យគយដែលប្រតិវេទន៍ (SAD) ត្រូវបានដាក់និងដំណើរការ។<br>ការិយាល័យគយដែល SAD ត្រូវបានដាក់អាចផ្សេងពីការិយាល័យគយដែលទំនិញត្រូវបាននាំចូល/នាំចេញពីប្រទេស (ប្រអប់លេខ២៩)។<br>នៅពេលប្រើប្រព័ន្ធអាស៊ីគូដា នឹងបង្ហាញដោយស្វ័យប្រវត្តិនូវឈ្មោះ |

<table>
<tr><td></td><td></td><td></td><td>ការិយាល័យ បន្ទាប់ពីកូដត្រូវបានដាក់បញ្ចូល។<br>ការប្រើប្រាស់ SAD ដោយដៃ ប្រតិវេទករត្រូវបំពេញទាំងកូដការិយាល័យ និងឈ្មោះ ផ្អែកតាមបញ្ជីកូដយោង។</td></tr>
<tr><td></td><td>និវេទនប័ណ្ណ</td><td>ជម្រើស</td><td>នៅពេលនិវេទនប័ណ្ណត្រូវបានចុះបញ្ជីក្នុងអាស៊ីគូដា ប្រព័ន្ធផ្តល់នូវលេខចុះបញ្ជី។ នៅពេលអនុវត្តនិវេទនប័ណ្ណ លេខនេះនឹងត្រូវបានបញ្ចូលទៅក្នុង SAD ក្នុងប្រអប់នេះ។ ប្រតិវេទករត្រូវចុះ នូវលេខនិវេទនប័ណ្ណ ដែលផ្តល់ដោយអ្នកនាំចូល។</td></tr>
<tr><td></td><td>លេខ និងកាលបរិច្ឆេទបញ្ជិកាប្រតិវេទន៍គយ</td><td>ចាំបាច់</td><td>នៅពេលប្រើប្រព័ន្ធអាស៊ីគូដា នៅកន្លែងចុះបញ្ជិកា (ការទទួលយកតាមច្បាប់ដោយគយ នៅពេលដែលទំនិញបានមកដល់ និងនៅពេលដែលចាប់ផ្តើមបំពេញឯកសារ និងការដាក់បញ្ចូលទិន្នន័យ ត្រូវបានបំពេញ)។ ប្រព័ន្ធផ្តល់លេខចុះបញ្ជីឯកភាពដោយស្វ័យប្រវត្តិតែមួយផ្សំឡើងដោយ លំដាប់អក្សរ + លេខ + កាលបរិច្ឆេទសំរាប់ការិយាល័យគយបច្ចុប្បន្ន និងឆ្នាំបច្ចុប្បន្ន។<br><br>ឧទាហរណ៍<br>
<table>
<tr><th>លំដាប់អក្សរ</th><th>លេខ</th><th>កាលបរិច្ឆេទ</th><th>ការិយាល័យគយ</th><th>ឆ្នាំបច្ចុប្បន្ន</th></tr>
<tr><td>I</td><td>32</td><td>15/11/2006</td><td>ក្រុងព្រះសីហនុ</td><td>2006</td></tr>
<tr><td>I</td><td>33</td><td>20/11/2006</td><td>ក្រុងព្រះសីហនុ</td><td>2006</td></tr>
<tr><td>I</td><td>33</td><td>20/11/2006</td><td>អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ</td><td>2006</td></tr>
</table>
ការប្រើប្រាស់ SAD ដោយដៃ គយជាអ្នកផ្តល់នូវលេខចុះបញ្ជីឯកភាព (ទម្រង់ដូចគ្នាទៅនឹងទម្រង់បានផ្តល់ដោយប្រព័ន្ធ) នៅពេលដាក់ប្រតិវេទន៍គយ SAD ។ គយត្រូវគ្រប់គ្រងប្រព័ន្ធចុះបញ្ជិកា ទៅក្នុងសៀវភៅចុះបញ្ជិកា / សៀវភៅចុះលេខប្រតិវេទន៍នៅថ្នាក់ការិយាល័យគយ និងផ្អែកលើមូលដ្ឋានប្រចាំឆ្នាំ។</td></tr>
<tr><td>2</td><td>កូដអ្នកនាំចេញ / អ្នកផ្ញើទំនិញ</td><td>ជម្រើស</td><td>ប្រអប់នេះជាធម្មតា គឺជាឈ្មោះបុគ្គល ឬ ក្រុមហ៊ុន ឬ ស្ថាប័ននៅក្រៅប្រទេស (នៅក្រៅកម្ពុជា) ដែលអ្នកនាំចូលទិញទំនិញ ។<br><br>ចំពោះប្រតិវេទន៍នាំចូល ប្រអប់នេះគឺជាជំរើស ។ ប្រសិនបើមានព័ត៌មានសូមផ្តល់នូវឈ្មោះពេញ និងអាសយដ្ឋាន រួមទាំងអាសយដ្ឋានអ៊ីមែលផង (ប្រសិនបើមាន) របស់អ្នកនាំចេញ/ អ្នកផ្ញើ (អ្នកផ្គត់ផ្គង់) ទំនិញ នៅក្រៅប្រទេស។</td></tr>
<tr><td>3</td><td>ទម្រង់</td><td>ចាំបាច់</td><td>ប្រអប់នេះបង្ហាញចំនួនសរុបនៃទំព័រក្នុងប្រតិវេទន៍ ដែលរាប់បញ្ចូលទាំងទំព័រមុខ និងទំព័របន្តណាមួយ (ទំព័របន្ថែម) មានន័យថា ២, ៣ ។ល។ ទៅតាមត្រូវការ។<br><br>ដូចក្នុងឧទាហរណ៍ ប្រព័ន្ធអាស៊ីគូដានឹងបង្ហាញដោយស្វ័យប្រវត្តិ ប្រសិនបើប្រតិវេទន៍មាន៣ទំព័រ ១/៣ លើទំព័រទី១ ២/៣លើទំព័រទី ២ និង ៣/៣</td></tr>
</table>

| | | | |
|---|---|---|---|
| | | | លើទំព័រចុងក្រោយ ។<br>ការបញ្ចូល SAD ដោយដៃត្រូវអនុវត្តតាមទម្រង់ដូចគ្នា។ |
| 4 | | មិនតម្រូវ | ចំនួនបញ្ជីផ្ទុកទំនិញឬឯកសារភ្ជាប់ប្រហាក់ប្រហែលផ្សេងទៀតភ្ជាប់ជាមួយការប្រកាសទំនិញ។<br>មិនទាន់ត្រូវការ នាពេលបច្ចុប្បន្ននេះទេ។ |
| 5 | មុខទំនិញ | ចាំបាច់ | ប្រអប់នេះបង្ហាញចំនួនមុខទំនិញសរុបក្នុងប្រតិវេទន៍។ ប្រតិវេទន៍នីមួយៗអាចបំពេញមុខទំនិញបានជាអតិបរិមារហូតដល់ ៩៩មុខទំនិញ។<br>ការប្រើប្រាស់ប្រព័ន្ធអាសុីគូដា ចំនួនមុខទំនិញនឹងត្រូវបង្ហាញដោយស្វ័យប្រវត្តិ ។<br>ការប្រើប្រាស់ SAD ដោយដៃ ប្រតិវេទករត្រូវបញ្ចូលក្នុងប្រអប់នេះ |
| 6 | ភណ្ឌិកាសរុប | ចាំបាច់ | ការប្រើប្រាស់ SAD ដោយដៃ និងដោយអេឡិចត្រូនិក ប្រតិវេទករ ត្រូវបង្ហាញនូវចំនួនសរុបភណ្ឌិកា សំរាប់ប្រតិវេទន៍ទាំងមូល (មានន័យថាចំនួនសរុបកញ្ចប់នៃមុខទំនិញទាំងអស់)។<br>ចំពោះទំនិញចាក់ធាលោកអ្នកអាចបញ្ចូលលេខ១ ។ |
| 7 | លេខយោង ប្រតិវេទករ | ចាំបាច់ | នេះជាលេខលំដាប់ខាងក្នុង (មានន័យថាលេខប្រតិបត្តិការ) ដែលប្រតិវេទករម្នាក់ៗត្រូវបំពេញលើ SAD (ដោយដៃ ឬដោយអេឡិកត្រូនិក)។<br>ប្រតិវេទករ ត្រូវថែរក្សាផ្ទៃក្នុង "លេខប្រតិបត្តិការ" សៀវភៅចុះបញ្ជីរបស់ខ្លួន។ |
| 8 | អ្នកនាំចូល / អ្នកទទួលទំនិញ | ចាំបាច់ | ចំពោះប្រតិវេទន៍នាំចូល អ្នកទទួលទំនិញជាទូទៅជាអ្នកនាំចូលនៅក្នុងកម្ពុជា ។ អ្នកទទួលទំនិញ គឺជាបុគ្គល ឬ ក្រុមហ៊ុន ឬ អង្គការ ដែលទំនិញត្រូវបានគេផ្ញើអោយ។<br>ប្រតិវេទករត្រូវបំពេញ (លេខអត្តសញ្ញាណពន្ធ/អាករលើតម្លៃបន្ថែម អ.ត.ប) របស់អ្នកទទួលទំនិញ ទៅក្នុងប្រអប់កូដ។ នៅពេលប្រព័ន្ធអាសុីគូដាត្រូវបានប្រើប្រាស់ ឈ្មោះនិងអាសយដ្ឋានពេញរបស់អ្នកនាំចូល/អ្នកទទួលទំនិញ ត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅលើ SAD ភ្លាមនៅពេលលេខ អ.ត.ប ត្រូវបានបញ្ចូល ។<br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ប្រតិវេទករត្រូវបំពេញ ឈ្មោះ និងអាសយដ្ឋានអ្នកនាំចូល/អ្នកទទួលទំនិញ ផ្អែកតាមបញ្ជីយោងកូដដែលបានផ្តល់ឲ្យ។<br>លេខ អ.ត.ប. ត្រូវបានផ្តល់ឲ្យដោយនាយកដ្ឋានពន្ធដារ ។<br><u>កំណត់សំគាល់:</u><br>អ្នកនាំចូល ដែលគ្មានលេខ អ.ត.ប (អ្នកនាំចូល/អ្នកទទួលទំនិញម្តងម្កាលប៉ុណ្ណោះ) ត្រូវប្រើកូដ ៩៩៩៩៩៩៩៩៩ អ្នកនាំចូល/អ្នកទទួលទំនិញម្តងម្កាល និងត្រូវបញ្ចូលឈ្មោះ លេខអត្តសញ្ញាណ ប័ណ្ណ និងអាសយដ្ឋានក្នុងប្រអប់លេខ ៩ ។ |

| | | | |
|---|---|---|---|
| | | | ចំពោះអ្នកដែលកំពុងរង់ចាំលេខ អ.ត.ប របស់ខ្លួន ឯកសារពីនាយកដ្ឋានពន្ធដារ (រាប់បញ្ចូលលេខ អ.ត.ប បណ្តោះអាសន្ន) ត្រូវតែបានភ្ជាប់ជាមួយ SAD។ |
| 9 | អ្នកទទួលទំនិញ/អ្នកនាំចូលម្តងម្កាល | ជម្រើស | ប្រអប់នេះត្រូវបានបំពេញ សម្រាប់តែអ្នកទទួលទំនិញ ដែលមានលក្ខណៈម្តងម្កាលប៉ុណ្ណោះ ។ ក្នុងករណីនេះ អ្នកត្រូវបំពេញឈ្មោះអ្នកទទួលទំនិញ អត្តសញ្ញាណប័ណ្ណ និងអាសយដ្ឋានក្នុងប្រអប់រងនៃអ្នកទទួលទំនិញម្តងម្កាល។<br><br>អ្នកទទួលទំនិញឬអ្នកនាំចូលម្តងម្កាល គឺជាបុគ្គល ឬ ក្រុមហ៊ុន ដែលធ្វើការនាំចូលតែមួយលើកប៉ុណ្ណោះ។ ក្នុងករណីនេះក្រុមហ៊ុននឹងមិនមានលេខ អ.ត.ប ទេ។ ប្រសិនបើក្រុមហ៊ុនមានបំណងក្លាយជាអ្នកនាំចូលទៀងទាត់ នោះក្រុមហ៊ុនត្រូវមានលេខ អ.ត.ប |
| 10 | ប្រទេសមកពី/ទៅដល់ | ជម្រើស | នេះជាកូដប្រទេស ដែលទំនិញត្រូវបានផ្ទុកជាចុងក្រោយលើនាវា/អាកាសយាន (យន្តហោះ) ។ |
| 11 | | មិនតម្រូវ | នេះគឺជាប្រទេសដែល សហ-សហគ្រិនមៅការនៃអ្នកនាំចូល ត្រូវបានតាំងលំនៅ ឬមានរបរជំនួញរបស់ខ្លួន។ ចំពោះការនាំចូល ពាក្យ "ប្រទេសទិញទំនិញ" ត្រូវបានប្រើប្រាស់។<br><br>មិនទាន់ត្រូវការ សំរាប់ពេលបច្ចុប្បន្ននេះទេ។ |
| 12 | តម្លៃលំអិត | ចាំបាច់ | ប្រអប់នេះមានចន្លោះដើម្បីបញ្ចូលលំអិតនៃកម្រៃផ្សេងៗ (មិនត្រូវបានដាក់បញ្ចូលទៅក្នុងវិក្ក័យប័ត្រ) ដែលទាក់ទងទៅនឹងការគណនាតម្លៃគិតពន្ធគយនៃទំនិញ ។<br><br><u>ការពន្យល់:</u><br><br>ប្រសិនបើ មានការលក់រវាងអ្នកទិញនិងអ្នកលក់ ហើយថ្លៃលើវិក្ក័យប័ត្រ គឺក្នុងកម្រិត FOB បន្ទាប់មកការចំណាយផ្សេងៗ និងសោហ៊ុយដឹកទំនិញមកកាន់កម្ពុជា ត្រូវបានបូកបន្ថែមទៅលើតម្លៃ FOB ។ ការចំណាយ និងសោហ៊ុយផ្សេងៗ អាចជាសោហ៊ុយដឹកជញ្ជូនតាមអាកាស ឬសមុទ្រ ការធានារ៉ាប់រង សោហ៊ុយដឹកជញ្ជូនផ្សេងៗ ឬ សោហ៊ុយលើកដាក់ សោហ៊ុយពីទំនិញក្នុងស្រុក ។ល។ និង ត្រូវបូកបន្ថែមទៅក្នុងតម្លៃទំនិញនៅ"កន្លែង" ឬ "កម្រិត" ត្រឹមត្រូវ - CIF ប្រទេសនាំចូលដូចបង្ហាញខាងក្រោម:<br><br>ឧទាហរណ៍<br><br>វិក្ក័យប័ត្រសរុប (FOB) = ១០០០ USD<br>ថ្លៃដឹកជញ្ជូនខាងក្រៅ = ២០០ USD( 800 000 រៀល)<br>ធានារ៉ាប់រង = ៥០ USD ( 200 000 រៀល)<br>ថ្លៃដឹកជញ្ជូនខាងក្នុង = ៨០ ០០០រៀល<br>ដកចេញ = ១០៥ ០០០រៀល<br><br>តម្លៃលំអិត =៩៧៥ ០០០ រៀល (៨០០ ០០០+២០០ ០០០ + 80 000 - ១០៥ ០០០) |

| | | | |
|---|---|---|---|
| | | | ប្រសិនបើប្រព័ន្ធអាស៊ីគូដា និងប័ណ្ណកំណត់តម្លៃគិតពន្ធគយត្រូវបានប្រើ ប្រអប់តម្លៃលំអិតនេះ នឹងបង្ហាញដោយស្វ័យប្រវត្តិដោយប្រព័ន្ធ ។<br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ឬ ប័ណ្ណកំណត់តម្លៃគិតពន្ធគយមិនត្រូវបានប្រើប្រាស់ ប្រតិវេទករត្រូវបញ្ចូលចំនួនទឹកប្រាក់នៃ "កម្រៃផ្សេងៗ" ។<br>កំណែតម្រូវសរុបចំពោះថ្លៃវិក្កយប័ត្រ ត្រូវបានបន្ថែមតាមសមាមាត្រទៅតាមមុខទំនិញដែលបានប្រកាស ក្នុងករណីដែលប្រតិវេទន៍មានច្រើនជាងមួយមុខទំនិញ ។ |
| 13 | អ.ទ.ម.ផ. | ចាំបាច់ | ប្រអប់នេះត្រូវបានប្រើសម្រាប់ទំនិញឆ្លងយន្តការ PSI<br>ឧទា: លេខ0=មិនជាប់ PSI, លេខ1=ឆ្លងPSI, លេខ2=មិនឆ្លង PSI<br>ក្នុងករណីតម្លៃ PSI=1 ត្រូវចុះលេខCRF នៅក្នុងមុខទំនិញទី1 |
| 14 | កូដប្រតិវេទករ / អ្នកតំណាង | ចាំបាច់ | ប្រតិវេទនករ គឺជាបុគ្គល ឬ ក្រុមហ៊ុន ឬអង្គការ ធ្វើការប្រកាសទំនិញចំពោះគយ។<br>នរណាអាចប្រកាស?<br>1. ក្នុងករណីនេះ អ្នកនាំចូលអាចបំពេញបែបបទយកទំនិញរបស់ខ្លួនបាន។ អ.ត.ប របស់ក្រុមហ៊ុនត្រូវតែបញ្ចូល (កូដក្រុមហ៊ុន និងកូដប្រតិវេទករដូចគ្នា) ។ ក្នុងករណីដែលអ្នកនាំចូលគ្មានលេខអ.ត.ប (អ្នកនាំចូលម្តងម្កាល) ប៉ុន្តែចង់ប្រកាសនាំចូលត្រូវប្រើប្រាស់ លេខកូដ ៩៩៩៩៩៩៩៩៩ ជាប្រតិវេទករម្តងម្កាល។ តែទោះជាយ៉ាងណាក៏ដោយ អ្នកទទួលទំនិញម្តងម្កាល មិនអាចជាប្រតិវេទករម្តងម្កាលក្រៅពីរបស់ខ្លួនបានទេ ។ ក្នុងករណីដោយឡែកនេះ ប្រសិនបើអ្នកនាំចូលទំនិញម្តងម្កាលមិនចង់ប្រកាសទំនិញរបស់ខ្លួនទេនោះ ម្ចាស់ទំនិញនោះត្រូវប្រើប្រាស់សេវាជើងសារគយ។<br>2. ជើងសារគយគឺជាអ្នកដែលត្រូវបានផ្តល់សិទ្ធិដោយម្ចាស់ទំនិញ ឲ្យបំពេញបែបបទយកទំនិញចេញពីគយក្នុងនាមម្ចាស់ទំនិញ ត្រូវតែបញ្ចូលកូដ អ.ត.ប ជើងសារគយមានការអនុញ្ញាត ។<br>នៅពេលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើប្រាស់ ឈ្មោះពេញ និងអាសយដ្ឋាននៃប្រតិវេទករ ត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅលើ SAD ។<br>ប្រសិនបើ SAD ត្រូវប្រើដោយដៃ ប្រតិវេទករត្រូវបំពេញឈ្មោះ និងអាសយដ្ឋានរបស់ខ្លួន ។ |
| 15 | ប្រទេសនាំចេញ | ចាំបាច់ | ប្រសិនបើប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើប្រាស់ ឈ្មោះប្រទេសនាំចេញ នឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិ ប្រតិវេទករត្រូវបំពេញឈ្មោះប្រទេសនាំចេញ ផ្អែកតាមបញ្ជីយោងលេខកូដ ដែលបានផ្តល់អោយ ។<br>ប្រសិនបើ SAD ប្រើដោយដៃ ប្រតិវេទករត្រូវបំពេញឈ្មោះប្រទេសនាំចេញផ្អែកតាមបញ្ជីយោងលេខកូដដែលបានផ្តល់អោយ។ |

| | | | |
|---|---|---|---|
| 15 | កូដប្រទេសនាំចេញ | ចាំបាច់ | កូដប្រទេសនាំចេញមានពីរផ្នែក:<br>ផ្នែកទី១ លោកអ្នកត្រូវបញ្ចូលកូដប្រទេស (មិនមែនឈ្មោះប្រទេសទេ) ដែលបានធ្វើការនាំចេញទំនិញ ។<br>ផ្នែកទី២ តំបន់នៃប្រទេសនាំចេញ(ប្រអប់នេះមិនបាច់បំពេញ)។ |
| 16 | ប្រទេសដើមកំណើតទំនិញ | ចាំបាច់ | ប្រសិនបើមុខទំនិញនីមួយៗក្នុងប្រអប់លេខ ៥ មានប្រទេសដើមកំណើតទំនិញដូចគ្នា (ប្រអប់៣៤) ឈ្មោះប្រទេសនឹងបង្ហាញស្វ័យប្រវត្តិដោយប្រព័ន្ធក្នុងប្រអប់លេខ ១៦ ។<br>ប្រសិនបើមុខទំនិញនីមួយៗក្នុងប្រអប់លេខ៥ មានប្រទេសដើមកំណើតទំនិញខុសគ្នា (ប្រអប់៣៤) ប្រព័ន្ធនឹងបង្ហាញពាក្យ "ច្រើន" ក្នុងប្រអប់លេខ ១៦ ។<br>អនុវត្តវិធានដូចគ្នា ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ។ |
| 17 | កូដប្រទេសគម្យដ្ឋាន | ចាំបាច់<br><br><br>មិនតម្រូវ | កូដប្រទេសគម្យដ្ឋានមានពីរផ្នែក:<br>ផ្នែកទី១ នៅពេលនាំចូល ប្រទេសគម្យដ្ឋានជាប្រទេសនៃទីតាំងនាំចូលដែលជាកម្ពុជា។ ពាក្យ KH កូដប្រទេស ត្រូវបានបង្ហាញជាស្វ័យប្រវត្តិដោយប្រព័ន្ធ។<br>ប្រសិនបើ SAD ត្រូវបានប្រើដោយដៃ ប្រតិវេទករ ត្រូវបញ្ចូល KH ក្នុងប្រអប់នេះ ។<br>ផ្នែកទី២ តំបន់នៃប្រទេសគម្យដ្ឋាន (ប្រអប់នេះមិនត្រូវបានបញ្ចូល និង មិនត្រូវបានជ្រើសរើស XX) |
| 17 | ប្រទេសគម្យដ្ឋាន | ចាំបាច់ | នៅពេលដែលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើ ឈ្មោះ "កម្ពុជា" ត្រូវបានបង្ហាញជាស្វ័យប្រវត្តិ។<br>ប្រសិនបើ SAD ប្រើដោយដៃ ប្រតិវេទករត្រូវវាយបញ្ចូល "កម្ពុជា"។ |
| 18 | អត្តសញ្ញាណនិងសញ្ជាតិ មធ្យោបាយដឹកជញ្ជូនទៅ/មក | ចាំបាច់<br><br><br>ជម្រើស | ប្រអប់នេះចែកជាពីរផ្នែក:<br>ផ្នែកទី១ ត្រូវតែបំពេញជាមួយអត្តសញ្ញាណមធ្យោបាយដឹកជញ្ជូនដែលដឹកជញ្ជូនទំនិញឆ្ពោះទៅប្រទេសគម្យដ្ឋាន។ ចំពោះនាវាអាចជាឈ្មោះនាវា ឬលេខវេនជើងនាវានោះ ។ ចំពោះយន្តហោះវាអាចជាលេខជើងហោះហើរ ចំពោះរថយន្តដឹកទំនិញ អាចជាស្លាកលេខ/ លេខអាជ្ញាប័ណ្ណ ។ល។ ផ្នែកនៃប្រអប់ ១៨ នេះ គឺចាំបាច់ ។<br>ផ្នែកទី២ សញ្ជាតិបង្ហាញជាកូដប្រទេសដែលមធ្យោបាយដឹកជញ្ជូននោះបានចុះបញ្ជី។ ផ្នែកនេះនៃប្រអប់ ១៨ គឺជម្រើស ប៉ុន្តែប្រសិនបើអ្នកមានព័ត៌មានសូមបំពេញ។ |
| 19 | ការបង្ហាញកុងតឺន័រ | ជម្រើស | ប្រអប់នេះគឺបង្ហាញថាតើទំនិញបានប្រកាស ត្រូវបានដឹកជញ្ជូនតាមកុងតឺន័រ (ផ្ទុកក្នុងកុងតឺន័រ) ឬ មិនផ្ទុកក្នុងកុងតឺន័រ មិនសំដៅលើបរិមាណកុងតឺន័រទេ។ សូមគូសសញ្ញា √ ក្នុងប្រអប់នេះបើសិនទំនិញផ្ទុកក្នុងកុងតឺន័រ។ |

| | | | |
|---|---|---|---|
| 20 | ល័ក្ខខ័ណ្ឌប្រគល់ទទួល | <br><br>ចាំបាច់<br><br>ចាំបាច់<br><br>មិនតម្រូវ | ល័ក្ខខ័ណ្ឌបានព្រមព្រៀងទទួលយក រវាងអ្នកលក់និងអ្នកទិញ ចំពោះការប្រគល់ទំនិញដល់អ្នកទិញ។ ល័ក្ខខ័ណ្ឌប្រគល់ទទួល ក្នុងពាណិជ្ជកម្មអន្តរជាតិត្រូវបានចែងក្នុងវាក្យស័ព្ទពាណិជ្ជកម្មអន្តរជាតិ INCOTERMS។<br>ប្រអប់នេះមាន ៣ ផ្នែក:<br>**ផ្នែកទី១** ក្នុងប្រអប់នេះលោកអ្នកត្រូវបញ្ចូលកូដល័ក្ខខ័ណ្ឌប្រគល់ទទួល រៀបរាប់ល័ក្ខខ័ណ្ឌប្រគល់ទទួលដែលបានបញ្ជាក់ក្នុងកិច្ចសន្យាលក់ទំនិញរវាងអ្នកទិញនិងអ្នកលក់ នៃទំនិញដែលបានប្រកាស ដូចជា CIF, FOB, CFR ។ល។<br>**ផ្នែកទី២** ក្នុងប្រអប់នេះអ្នកត្រូវបញ្ចូលល័ក្ខខ័ណ្ឌប្រគល់ទទួល<br>**ទីកន្លែង:** ដូចជាក្រុងព្រះសីហនុ<br>**ផ្នែកទី៣** ប្រអប់នេះ គឺជាល័ក្ខខ័ណ្ឌប្រគល់ទទួលបង្ហាញជាកូដ មិនតម្រូវអោយបំពេញ និងត្រូវបានកំណត់ដោយ xx ។ |
| 21 | អត្តសញ្ញាណមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ | <br>ជម្រើស<br><br><br><br>ជម្រើស | ប្រអប់នេះមានពីរផ្នែក:<br>**ផ្នែកទី១** ត្រូវបានបំពេញនូវអត្តសញ្ញាណមធ្យោបាយដឹកជញ្ជូនបានប្រើប្រាស់ក្នុងការឆ្លងកាត់ព្រំដែននៃប្រទេសតម្បង្ហានចុងក្រោយ។ សំរាប់នាវា វាអាចជាឈ្មោះនាវា ឬលេខវេនជើងធ្វើដំណើរ សំរាប់យន្តហោះវាអាចជាលេខជើងហោះហើរ សំរាប់រថយន្តដឹកវាអាចជាលេខចុះបញ្ជី/អាជ្ញាប័ណ្ណ។ល។ ប្រអប់នេះគឺជាការជ្រើសរើស ប៉ុន្តែប្រសិនបើអ្នកមានព័ត៌មានសូមបំពេញ។<br>**ផ្នែកទី២** សញ្ជាតិបង្ហាញជាកូដប្រទេស មធ្យោបាយដឹកជញ្ជូនឆ្លងកាត់ព្រំដែនដែលត្រូវបានចុះបញ្ជី។ ប្រអប់នេះគឺជ្រើសរើសប៉ុន្តែប្រសិនបើអ្នកមានព័ត៌មានសូមបំពេញ។ |
| 22 | រូបិយបណ្ណ័ & តំលៃវិក្កយបត្រសរុប | <br>ចាំបាច់<br>ចាំបាច់ | ប្រអប់នេះមាន២ផ្នែក:<br>**ផ្នែកទី១** អ្នកត្រូវបញ្ចូលកូដរូបិយវត្ថុដែលបានចុះក្នុងវិក្កយបត្រ<br>**ផ្នែកទី២** លោកអ្នកត្រូវបញ្ចូលចំនួនទឹកប្រាក់ជារូបិយប័ណ្ណសរុប (មិនទាន់ប្តូរ) ដូចបានប្រកាសក្នុងវិក្កយបត្រ។ |
| 23 | អត្រាប្តូរប្រាក់ | ចាំបាច់ | ប្រអប់នេះ គឺជាអត្រាប្តូរប្រាក់ផ្លូវការ សំរាប់រូបិយប័ណ្ណ ដែលទំនិញក្នុងប្រអប់នេះ ត្រូវបានបង់ជាប្រាក់រៀល។<br>ការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា អត្រាប្តូរប្រាក់នឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅពេលដែលចំនួនប្រាក់ក្នុងវិក្កយបត្រសរុបត្រូវបានបញ្ចូល។<br>ការប្រើប្រាស់ SAD ដោយដៃ ប្រតិវេទករត្រូវបញ្ចូលអត្រាប្តូរប្រាក់ ដែលមាននៅគ្រប់ការិយាល័យគយ។ |

| | | | |
|---|---|---|---|
| | | | អត្រាប្តូរប្រាក់ផ្លូវការត្រូវបានដាក់បញ្ចូលថ្មីជារៀងរាល់ថ្ងៃសុក្រនិងត្រូវផ្តល់សុពលភាពនៅថ្ងៃច័ន្ទ។ |
| 24 | ប្រភេទចម្លងការ | ជម្រើស | ប្រភេទចម្លងការ គឺជាការបង្ហាញដល់គយនូវប្រភេទនៃកិច្ចសន្យា ដែលទំនិញត្រូវបានផ្គត់ផ្គង់ ដូចជាការលក់ ការផ្លាស់ប្តូរ អំណោយ កម្ចី ជួលទំនិញត្រឡប់វិញ។ល។<br><br>ប្រអប់នេះមាន២ផ្នែក:<br><br>**ផ្នែកទី១** ការបរិយាយទូទៅនៃកិច្ចចម្លងការ<br><br>ឧទាហរណ៍: ២ កម្ចីដោយមានការប្រាក់<br><br>**ផ្នែកទី២** លំអិតនៃកិច្ចចម្លងការ<br><br>ឧទាហរណ៍: ១ កម្ចី ឬ ជួល<br>២ ភតិសន្យា (កិច្ចសន្យាជួល) |
| 25 | បែបផែនដឹកជញ្ជូននៅព្រំដែន | ចាំបាច់ | បែបផែនដឹកជញ្ជូន បានប្រើសំរាប់ដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន។ អ្នកត្រូវបញ្ចូលក្នុងបែបផែនដឹកជញ្ជូននៃការនាំចូលទំនិញ។<br><br>ឧទាហរណ៍:<br>១. ទំនិញមកដល់តាមនាវានៅក្រុងព្រះសីហនុ ➔ ប្រអប់២៥(បែបផែនដឹកជញ្ជូននៅព្រំដែន) = ១ (ដឹកជញ្ជូនតាមសមុទ្រ) បន្ទាប់មកដាក់លើរថយន្តដឹកជញ្ជូនទៅភ្នំពេញ ➔ ប្រអប់២៦(បែបបផែនដឹកជញ្ជូនតាមផ្លូវគោក) = ៣ (ដឹកជញ្ជូនតាមផ្លូវថ្នល់)<br><br>២. ទំនិញមកដល់ ដឹកជញ្ជូនតាមផ្លូវទឹកពីប្រទេសវៀតណាម ➔ ប្រអប់២៥ (បែបផែនដឹកជញ្ជូននៅព្រំដែន) = ៨ (ដឹកជញ្ជូនតាមផ្លូវទឹកចូលមកក្នុងដែនគយ) បន្ទាប់មកតាមបែបផែនដឹកជញ្ជូនដដែលនេះឆ្ពោះទៅកំពង់ផែភ្នំពេញ ➔ ប្រអប់២៦ (បែបបផែនដឹកជញ្ជូនតាមផ្លូវទឹកចូលមកដែនគោក) = ៨ (ដឹកជញ្ជូនតាមផ្លូវទឹកចូលមកដែនគោក)។ |
| 26 | បែបផែនដឹកជញ្ជូនដែនគោក | ជម្រើស | បែបផែនដឹកជញ្ជូនបានប្រើប្រាស់នៅពេលដឹកជញ្ជូនទំនិញនាំចូល បន្តទៅក្នុងដែនគោក (ហួសពីព្រំដែន)។ |
| 27 | ទីកន្លែងផ្ទុក/ផ្ទេរ | ជម្រើស | ឈ្មោះកំពង់ផែសមុទ្រ ព្រលានយន្តហោះ ស្ថានីយ៍បញ្ជូនទំនិញ ស្ថានីយ៍រថភ្លើង ឬ ទីកន្លែងផ្សេងទៀត ដែលទំនិញត្រូវបានផ្ទេរចេញពីមធ្យោបាយដឹកជញ្ជូន ហើយត្រូវបានប្រើប្រាស់សំរាប់ដឹកជញ្ជូនទំនិញ។<br><br>ប្រអប់នេះរួមមាន២ ផ្នែក:<br><br>**ផ្នែកទី១** ត្រូវបានបំពេញជាមួយកូដក្រុង (ឧទាហរណ៍ BBM សំរាប់ឈ្មោះខេត្តបាត់ដំបង)។<br><br>**ផ្នែកទី២** ត្រូវបានបំពេញជាមួយកូដប្រទេស (ឧទាហរណ៍ KH សំរាប់ |

| | | | |
|---|---|---|---|
| | | | ប្រទេសកម្ពុជា)។ |
| 28 | ព័ត៌មានហិរញ្ញវត្ថុនិងធនាគារ (កូដធនាគារ ល័ក្ខខ័ណ្ឌទូទាត់ ឈ្មោះធនាគារ សាខា លេខឯកសារ | <br><br>ជម្រើស<br><br>ជម្រើស<br><br>ជម្រើស<br><br><br>ជម្រើស<br><br>មិនតម្រូវ | ប្រអប់នេះ ពាក់ព័ន្ធជាមួយព័ត៌មានធនាគារ និងហិរញ្ញវត្ថុ ដូចជាឈ្មោះធនាគារ តាមរយៈការទូទាត់ទំនិញត្រូវបានធ្វើឡើង និង លក្ខខណ្ឌទូទាត់។<br>ប្រអប់នេះមាន៥ផ្នែក:<br>**ផ្នែកទី១** (កូដធនាគារ) ក្នុងការអវត្តមាននៃកូដធនាគារពិសេស លេខ អ.ត.ប ធនាគារនីមួយៗ ត្រូវបានប្រើជាកូដធនាគារ។<br>**ផ្នែកទី២** (ល័ក្ខខ័ណ្ឌទូទាត់) ការព្រមព្រៀងណាមួយរវាងអ្នកនាំចូលនិងអ្នកនាំចេញលើការទូទាត់ទំនិញ (មិនមានពាក់ព័ន្ធទៅនឹងការទូទាត់ពន្ធ និងអាករទេ)។<br>**ផ្នែកទី៣** (ឈ្មោះធនាគារ) នៅពេលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើ ឈ្មោះធនាគារនឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តនៅពេលកូដ ធនាគារត្រូវបានបញ្ចូល។<br>នៅពេលអាស៊ីគូដាត្រូវបានប្រើដោយដៃ ប្រតិវេទនករត្រូវបំពេញឈ្មោះធនាគារ។<br>**ផ្នែកទី៤** (សាខាធនាគារ) បច្ចុប្បន្ននៅកម្ពុជា សាខាធនាគារមិនត្រូវបានដាក់កូដទេ។ ប៉ុន្តែឈ្មោះរបស់វាត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ ។<br>**ផ្នែកទី៥** (លេខឯកសារ) លេខយោងឯកសារធនាគារ វាមិនត្រូវបានតម្រូវ ។ |
| 29 | ការិយាល័យ ចេញ/ចូល | ចាំបាច់ | ប្រអប់នេះ សំរាប់បំពេញកូដការិយាល័យគយ ទីកន្លែងដែលទំនិញបាននាំចូលមកក្នុងប្រទេសគម្យដ្ឋាន។ កូដការិយាល័យគយនេះអាចខុសពីការិយាល័យដាក់ប្រតិវេទន៍ដូចក្នុងប្រអប់ A (ការិយាល័យដាក់ប្រតិវេទន៍)។<br>នៅពេលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើ ការត្រួតពិនិត្យខាងក្រោមនេះនឹងត្រូវអនុវត្ត:<br>- ការិយាល័យនៃច្រកចូល/ចេញ គឺត្រូវស្របទៅនឹង "បែបផែនដឹកជញ្ជូននៅព្រំដែន" ក្នុងប្រអប់២៥ និង<br>- គឺត្រូវបានប្រកាសជាការិយាល័យគយព្រំដែនដែរ។<br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ប្រតិវេទករត្រូវផ្ទៀងផ្ទាត់បែបផែនដឹកជញ្ជូន មានសុពលភាពសំរាប់ការិយាល័យចូល/ចេញ ដែលបានគូសបញ្ជាក់លើ SAD និងប្រភេទការិយាល័យគយ (ព្រំដែន ឬ មិនមែនព្រំដែន)។ |
| 30 | ទីតាំងនៃទំនិញ | ជម្រើស | ការបង្ហាញពីទីកន្លែងដែលទំនិញត្រូវបានផ្ទុកនិងទីកន្លែងដែលបានផ្តល់សំរាប់ការឆែកពិនិត្យ។ ទីនោះអាចជាទីបរិវេណសហគ្រាសរបស់អ្នកនាំចូល ឃ្លាំងបណ្តោះអាសន្ន ទូរថភ្លើង ទីលានកំពង់ផែ។ល។<br>ប្រអប់នេះ មិនត្រូវបានប្រើប្រាស់សំរាប់ប្រកាសពីភណ្ឌាគារគយដែល |

| | | | |
|---|---|---|---|
| | | | ទំនិញត្រូវបានរក្សាទុកក្រោយការនាំចូល។ |
| 31 | ព័ត៌មានភណ្ឌិកានិងបរិយាយមុខទំនិញ (ផ្លាកសញ្ញាលើភណ្ឌិកា ចំនួន និងប្រភេទ អត្តសញ្ញាណកុងតេន័រ បរិយាយដូចក្នុងតារាងពន្ធគយ បរិយាយមុខទំនិញពាណិជ្ជកម្ម) | ជម្រើស | ប្រអប់នេះមានប្រាំផ្នែក:<br>**ផ្នែកទី១** (ផ្លាកសញ្ញាលើភណ្ឌិកា) ការបញ្ចូលព័ត៌មានក្នុងប្រអប់នេះត្រូវដាក់បញ្ចូលស្លាកសញ្ញានិងលេខ (២ប្រអប់) ធ្វើអត្តសញ្ញាណ ភណ្ឌិកាដោយឡែក លើកលែងតែទំនិញមិនមានការវេចខ្ចប់។<br>ចំពោះរថយន្ត:<br>(a) ត្រូវចុះចូលនូវលេខតួ<br>(b) ត្រូវចុះចូលនូវលេខម៉ាស៊ីន |
| | | ជម្រើស | **ផ្នែកទី២** (ចំនួននិងប្រភេទ) ចំនួនភណ្ឌិកាសំរាប់មុខទំនិញ នៅពេលដែលសរុបចំនួនភណ្ឌិកាតាមមុខទំនិញ ត្រូវតែស្មើនឹងចំនួនសរុបភណ្ឌិកាសំរាប់ SAD នេះ។ នៅពេលដែលទំនិញមានប្រភេទភណ្ឌិកាពីរផ្សេងគ្នា មុខទំនិញពីរនឹងត្រូវបានបង្កើតលើ SAD (ប្រសិនបើទំនិញស្ថិតក្នុងលេខកូដដូចគ្នា ប៉ុន្តែមានកូដប្រភេទភណ្ឌិកាខុសគ្នា)។ ត្រូវយកចិត្តទុកដាក់ជាពិសេស សំរាប់ឃ្លាំង ដែលកូដពិសេសនឹងត្រូវបានបន្ថែមពីភាពខុសគ្នានេះ។<br>• ការប្រើប្រភេទកូដនៃភណ្ឌិកា «មិនមានការវេចខ្ចប់»<br>• លេខអនុញ្ញាតនៃភណ្ឌិកាគឺជម្រើស<br>• ការត្រួតពិនិត្យដោយវិធាន បើសិនជាចំនួនភណ្ឌិកាមិនបានបំពេញនូវកូដភណ្ឌិកាទេ ប្រព័ន្ធមិនអនុញ្ញាតឱ្យប្រតិវេទន៍ដំណើរការទៅមុខទេ។<br>ឧទាហរណ៍: ស្រា និងប្រូមា ១ កាតុង<br>SAD: ចំនួនភណ្ឌិកាសរុប ១<br>មុខទំនិញទី១ - ស្រា - ចំនួនភណ្ឌិកា = ១, ប្រភេទភណ្ឌិកា = CT<br>មុខទំនិញទី២ - ប្រូមា - ចំនួនភណ្ឌិកា = ១, ប្រភេទភណ្ឌិកា = NE |
| | | ចាំបាច់ | កូដសំរាប់ប្រភេទភណ្ឌិកា ត្រូវតែបញ្ចូលដូចជា ថង់ កាតុង។ល។ |
| | | ជម្រើស | **ផ្នែកទី៣** (អត្តសញ្ញាណកុងតេន័រ)<br>ប្រសិនបើមានមួយ ឬ បួនកុងតេន័រ សំរាប់មុខទំនិញជាក់លាក់នេះ: ប្រតិវេទនករត្រូវបញ្ចូលលេខអត្តសញ្ញាណកុងតេន័រ (ឧទាហរណ៍ 1234567 (45HQ) នៃកុងតឺន័រនិមួយៗ។<br>ប្រសិនបើមានកុងតឺន័រច្រើនជាងបួន សំរាប់មុខទំនិញជាក់លាក់នេះ: ប្រតិវេទករត្រូវបញ្ចូលចំនួនសរុបនៃកុងតឺន័រលើប្រអប់ទីមួយដែលមានស្រាប់ និងបញ្ចូល "បញ្ជីភ្ជាប់" ក្នុងប្រអប់ទី២។ ប្រតិវេទករ ត្រូវផ្តល់នូវទំព័រកុងតឺន័រ រាប់បញ្ចូលបញ្ជីនៃអត្តសញ្ញាណប្រភេទតែមួយនូវគ្រប់កុងតឺន័រ។ ទំព័រនេះត្រូវបានផ្តល់ដោយ ASYCUDA ប្រសិនបើប្រព័ន្ធត្រូវបានប្រើប្រាស់។ |

| | | | |
|---|---|---|---|
| | | ចាំបាច់<br><br>ចាំបាច់ | សំរាប់ SAD បញ្ចូលដោយដៃ ប្រតិវេទករត្រូវប្រើ/បំពេញទំព័រកុងតឺន័ររាប់បញ្ចូលបញ្ជីនៃអត្តសញ្ញាណប្រភេទតែមួយ "Unique" នូវគ្រប់កុងតេន័រ។ ឡាប់ចម្លងនៃទម្រង់ ASYCUDA ត្រូវបានផ្តល់ដូចខាងក្រោម:<br><br>**ផ្នែកទី៤** (បរិយាយមុខទំនិញដូចក្នុងតារាងពន្ធគយ) បរិយាយមុខទំនិញដូចក្នុងតារាងពន្ធគយនឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅលើបន្ទាត់ពីរដំបូងនៃប្រអប់ នៅពេលដែលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើប្រាស់ (កំរិតអតិបរិមាត្រឹម៨៨តួអក្សរ)។<br><br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ប្រតិវេទនករត្រូវបញ្ចូលបរិយាយទំនិញនាំចូលដូចក្នុងតារាងពន្ធគយ។<br><br>**ផ្នែកទី៥** (បរិយាយមុខទំនិញពាណិជ្ជកម្ម) បន្ទាត់ទីបីនៃប្រអប់នេះ នឹងត្រូវបានបំពេញជាមួយនឹងបរិយាយមុខទំនិញពាណិជ្ជកម្មដូចក្នុងវិក្កយបត្រ។ វាក៏អាចបញ្ចូលផងដែរពីម៉ាកទំនិញ។ |
| 32 | មុខទំនិញទី | ចាំបាច់ | ប្រអប់នេះគឺជាលេខមុខទំនិញតាមលំដាប់សំរាប់ប្រតិទន៍នេះ ឧទាហរណ៍ មុខទំនិញទី១ មុខទំនិញទី២ មុខទំនិញទី៣។ល។ |
| 33 | កូដទំនិញ | ចាំបាច់ | ប្រអប់នេះត្រូវបានបំពេញជាមួយនឹងកូដទំនិញ ដែលបានប្រកាសសំរាប់ (មុខទំនិញនិមួយៗ) នៃវិក្កយបត្រ ស្របតាមតារាងពន្ធគយកម្ពុជាជាធរមាន។<br><br>បួនខ្ទង់ចុងក្រោយ (ហៅថាការតំណាងអោយលេខ៥) អាចត្រូវបានប្រើប្រាស់សំរាប់ការគ្រប់គ្រងសន្និធិឃ្លាំង។<br><br>សូមយោងសៀវភៅតារាងពន្ធគយកម្ពុជាជាធរមាន |
| 34 | កូដប្រទេសដើមកំណើតទំនិញ | ចាំបាច់ | ប្រអប់នេះ ត្រូវបានបំពេញជាមួយកូដប្រទេសដែលទំនិញជាក់លាក់ ត្រូវបានប្រកាសពីទីកន្លែងដើមកំណើតដែលបានផលិត។ |
| 35 | ទម្ងន់ទាំងសំបក | ចាំបាច់ | ប្រអប់នេះត្រូវបំពេញនូវទម្ងន់ទំនិញដោយរាប់បញ្ចូលសំបកវេចខ្ចប់ ប៉ុន្តែមិនរាប់បញ្ចូលនូវបរិក្ខាដឹកជញ្ជូន ដូចជាកុងតេន័រ ឡាំង ប៉ាឡែត។ល។ ដែលបញ្ជាក់ជាគ.ក្រ។<br><br>អ្នកត្រូវបញ្ចូលទម្ងន់សរុបនៃទំនិញ (មិនមែនឯកតា) នៃមុខទំនិញ |
| 36 | ពន្ធអនុគ្រោះ | ជម្រើស | ប្រអប់នេះគឺសំរាប់អត្រាពន្ធអនុគ្រោះដោយផ្អែកលើកិច្ចព្រមព្រៀងបានធ្វើឡើងរវាងកម្ពុជានិងបណ្តាប្រទេសនានា ដូចជា CEPT ។ |
| 37 | របបគយ | <br><br>ចាំបាច់ | ប្រអប់នេះមានពីរផ្នែក:<br><br>**ផ្នែកទី១** គឺត្រូវបានបំពេញជាមួយកូដរបបបានប្រើប្រាស់ដើម្បីកំណត់របបគយដែលទំនិញត្រូវបាននាំចូល នាំចេញ ឧទាហរណ៍ របប ៤០០០ តំណាងអោយការនាំចូលស្ថាពរដើម្បីប្រើប្រាស់ក្នុងស្រុក របប ៤០៧១ ដាក់អោយប្រើប្រាស់ក្នុងស្រុកបន្ទាប់ពីបានដាក់ចូលក្នុងឃ្លាំងគយ។ល។ |

| | | | |
|---|---|---|---|
| | | ចាំបាច់ | ផ្នែកទី២ គឺជាកូដរបបបន្ថែម បានប្រើប្រាស់ដើម្បីកំណត់របបរួមឬការលើកលែងពន្ធណាមួយ។<br>នីតិវិធីទាំងពីរខាងលើត្រូវតែឯកភាពគ្នា |
| 38 | ទម្ងន់សុទ្ធ | ចាំបាច់ | ប្រអប់នេះត្រូវបំពេញនូវទម្ងន់សុទ្ធគិតជាគ.ក្រ. នៃទំនិញដែលបានប្រកាស។ ប្រព័ន្ធនឹងបង្ហាញដោយស្វ័យប្រវត្តនូវតួលេខទម្ងន់សរុបដូចទម្ងន់សុទ្ធ។ ប៉ុន្តែអ្នកអាចសរសេរត្រួតគ្នា នៅក្នុងប្រអប់នេះជាមួយនឹងទម្ងន់សុទ្ធ។ |
| 39 | | មិនតម្រូវ | ប្រអប់នេះសំរាប់ការយោងចំពោះទំនិញដែលអនុវត្តកូតាណាមួយ ប្រអប់នេះមិនតម្រូវសំរាប់ពេលបច្ចុប្បន្ននេះទេ។ |
| 40 | ឯកសារដឹកជញ្ជូនឬប្រតិវេទន៍យោងពីមុន | ជម្រើស | ប្រអប់នេះសំរាប់បំពេញដូចខាងក្រោម៖<br>លេខអញ្ញាត្តប័ណ្ណ លេខអញ្ញាត្តប័ណ្ណតាមផ្លូវអាកាស ឬ Parcels Notification Duty Entry សំរាប់កិច្ចប្រតិបត្តិការគយដោយផ្ទាល់ ឬការយោងប្រតិវេទន៍ពីមុនសំរាប់កិច្ចប្រតិបត្តិការគយប្រយោល ។<br>ឧទាហរណ៍<br>ទំនិញត្រូវបាននាំចូលតាមផ្លូវអាកាស ហើយដាក់ចូលដោយផ្ទាល់ទៅក្នុងឃ្លាំង។ កិច្ចប្រតិបត្តិការនេះ ត្រូវបានចាត់ទុកថាជាកិច្ចប្រត្តិបត្តិការនាំចូលដោយផ្ទាល់ និងកូដរបបគយគឺ ៧១០០។ លេខអញ្ញាត្តប័ណ្ណតាមផ្លូវអាកាសនឹងត្រូវបានបញ្ចូលទៅក្នុងប្រអប់ ៤០ ដើម្បីកាត់ចេញ។<br>បន្ទាប់មក ទំនិញដដែលនេះត្រូវបានយកចេញពីឃ្លាំង និងដាក់លក់ក្នុងទីផ្សារ។ ប្រតិបត្តិការនេះមិនមែនជាប្រត្តិបត្តិការនាំចូលដោយផ្ទាល់នោះទេ ប៉ុន្តែជាការនាំចូលប្រើប្រាស់ក្នុងស្រុកបន្ទាប់ពីបានដាក់ចូលក្នុងឃ្លាំង ដូចនេះរបបគយគឺ ៤០៧១ ។ ការយោងប្រតិវេទន៍ដើម ៧១០០ នឹងត្រូវបានដាក់បញ្ចូលក្នុងប្រអប់ ៤០ សំរាប់តែជាព័ត៌មានតែប៉ុណ្ណោះ។ |
| 41 | ឯកតារង | ចាំបាច់ | ប្រអប់នេះត្រូវបានបំពេញនៅពេលចំណាត់ថ្នាក់តារាងពន្ធគយតាមមុខទំនិញដែលកំពុងប្រើប្រាស់តម្រូវអោយមានឯកតារងក្រៅពីទម្ងន់សុទ្ធដូចជា លីត្រ ចំនួន ឡ ។ល។ មានតែបរិមាណមួយគត់ត្រូវបានបំពេញក្នុងប្រអប់នេះ ឯកតាមិនត្រូវបានដាក់បញ្ចូលទេ។<br>ឧទាហរណ៍<br>i) លេខកូដ 87120010 (កង់ប្រណាំង) ឯកតារង = Unit ដូចនេះប្រអប់ នេះត្រូវបំពេញចំនួនកង់ដែលនាំចូល (ឧ. ៤៣ Unit)។ |
| 42 | តម្លៃឯកតា(តាមមុខទំនិញ) | ចាំបាច់ | ប្រអប់នេះត្រូវបានបំពេញជាមួយតម្លៃតាមមុខទំនិញគិតជារូបិយប័ណ្ណ។<br>វាត្រូវបានបង្ហាញដោយស្វ័យប្រវត្តិ នៅពេលអនុវត្តប្រព័ន្ធអាស៊ីគូដានិងកំណត់សំគាល់តម្លៃត្រូវបានប្រើប្រាស់។ មិនដូច្នេះទេ តម្លៃតាមមុខទំនិញត្រូវបានបញ្ចូលដោយដៃ។ |
| 43 | វិធីកំណត់តម្លៃ | ជម្រើស | ប្រអប់នេះត្រូវបំពេញកូដនៃវិធីកំណត់តម្លៃ (១ដល់៦ និង៩) ត្រូវបានប្រើ |

| | | | |
|---|---|---|---|
| | | | ប្រាស់ដើម្បីកំណត់តម្លៃគិតពន្ធគយ។ |
| 44 | ព័ត៌មានបន្ថែម | | ប្រអប់នេះត្រូវបានប្រើប្រាស់សំរាប់ព័ត៌មានបន្ថែមណាមួយ ដូចជា វិញ្ញាបនបត្របញ្ជាក់ការផលិត លិខិតអនុញ្ញាត។ល។ វាមានប្រអប់រងជាច្រើន៖ |
| | | ជម្រើស | - លេខអាជ្ញាប័ណ្ណ<br>- តម្លៃកាត់បន្ថយ (DV) និងបរិមាណកាត់បន្ថយ (DQ)<br>កំណត់សំគាល់: ASYCUDA មិនគ្រប់គ្រងតម្លៃ និងបរិមាណ សំរាប់អាជ្ញាប័ណ្ណទេ។ តម្លៃ និងបរិមាណត្រូវកាត់បន្ថយនឹងមិនត្រូវបានប្រើប្រាស់ក្នុងប្រទេសកម្ពុជាសំរាប់ពេលបច្ចុប្បន្ននេះទេ វាគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ។ |
| | | ចាំបាច់ | - តម្លៃលំអិត (ប័ណ្ណកំណត់តម្លៃ) នឹងត្រូវបង្ហាញដោយស្វ័យប្រវត្តិនៅពេលប្រើប្រព័ន្ធ ASYCUDA។ |
| | | ជម្រើស | - ឯកសារយោង (កូដនៃឯកសារបន្ថែម វិញ្ញាបនប័ត្រ ឬលិខិតអនុញ្ញាតបន្ថែមណាមួយ ដែលតម្រូវសំរាប់ការបញ្ចេញទំនិញណាមួយ ដូចជាតម្រូវការចត្តាឡីស័កវិញ្ញាបនប័ត្រសុខភាព។ល។<br>នៅពេលប្រព័ន្ធអាស៊ីគូដា ត្រូវបានប្រើប្រាស់ កូដនឹងត្រូវបានបន្ថែមដោយស្វ័យប្រវត្តិទៅតាមកូដដែលបានបញ្ចូលទៅក្នុងប្រព័ន្ធ (ឧទា.វិញ្ញាបនបត្រដើមកំណើតទំនិញ-ប្រយោជន៍ពីអត្រាពន្ធអនុគ្រោះ។<br>ប្រសិនបើកូដឯកសារភ្ជាប់ ត្រូវបានបំពេញដោយប្រតិវេទករ ទៅក្នុងទំព័រនៃឯកសារភ្ជាប់ វាមិនបានបង្ហាញជាមួយ SAD ទេ។<br>ប្រអប់ទំនេរសំរាប់បញ្ចូលព័ត៌មានបន្ថែម ដូចជា: វិក្កយបត្របញ្ជីវេចខ្ចប់ លេខយោង។ល។ |
| 45 | ការកែតម្រូវ | ចាំបាច់ | ការកែតម្រូវ គឺជាអនុបាត/កត្តាអនុវត្តតម្លៃគិតពន្ធគយ។ តាមការកំណត់ជាមុន (Default) ការកែតម្រូវគឺ១។ ប្រតិវេទនករមិនតម្រូវឲ្យផ្លាស់ប្តូរតម្លៃនេះទេ។ |
| 46 | តំលៃគិតពន្ធគយ | ចាំបាច់ | ប្រអប់នេះបរិយាយពីតម្លៃគិតពន្ធគយ។ ប្រអប់នេះនឹងត្រូវបានបំពេញតម្លៃជាលុយរៀលនៃទំនិញដែលបានបរិយាយក្នុងប្រអប់៣១ ផ្អែកតាមវិធានតម្លៃគិតពន្ធគយក្រោមច្បាប់ស្តីពីគយ។<br>តម្លៃនេះ គឺជាថ្លៃទំនិញដែលបានកែតម្រូវអោយត្រូវតាមកត្តាតម្លៃនៅពេលមកដល់គិតជា CIF។ |
| 47 | ការគណនាពន្ធ | ចាំបាច់ | ប្រអប់នេះរួមមានកត្តាពាក់ព័ន្ធទៅនឹងការគណនាពន្ធ ដូចមានក្នុងចំណុចខាងក្រោម៖<br>i) ប្រភេទ<br>ប្រភេទពន្ធ ឬអាករ ដែលអាចអនុវត្តក្រោមច្បាប់កម្ពុជាដូចជាពន្ធនាំចូល |

| | | | |
|---|---|---|---|
| | | | ពន្ធនាំចេញ អាករ អាករលើតម្លៃបន្ថែម។ល។<br>**ii) មូលដ្ឋានពន្ធ**<br>មូលដ្ឋានពន្ធ គឺជាតម្លៃគិតពន្ធគយនៅពេលដែលចំនួនប្រាក់ពន្ធ/អាករកំណត់ដោយគយផ្អែកតាមមូលដ្ឋាននៃការគណនា។<br>**iii) អត្រា**<br>អត្រាពន្ធ/អាករត្រូវផ្អែកលើមូលដ្ឋានកូដតារាងពន្ធគយសំរាប់មុខទំនិញជាក់លាក់ណាមួយ។<br>**iv) ចំនួនប្រាក់ពន្ធ**<br>សរុបចំនួនប្រាក់ពន្ធ/អាករ ត្រូវបានគណនាលើមុខទំនិញផ្អែកតាមអត្រាពន្ធ/អាករ។<br>**v) បែបផែនទូទាត់**<br>ប្រអប់នេះបង្ហាញថាពន្ធត្រូវបង់(១) ត្រូវបានធានា(៣) ឬ ត្រូវបានគណនាសំរាប់តែជាព័ត៌មាន(០)។ |
| 48 | ការទូទាត់ជាក្រោយ | ជម្រើស | ប្រសិនបើការទូទាត់ជាក្រោយត្រូវបានប្រើប្រាស់ ប្រអប់នេះត្រូវបានបំពេញជាមួយលេខគណនីឥណទានឬលេខគណនីទូទាត់ជាមុន។ |
| 49 | អត្តសញ្ញាណឃ្លាំងទំនិញ | | ប្រអប់នេះសំដៅលើនីតិវិធីព្យួរពន្ធ។ ប្រសិនបើនីតិវិធីគយមិនមែនជានីតិវិធីព្យួរពន្ធ ប្រអប់នេះមិនត្រូវបានប្រើ។<br>ប្រអប់នេះមានពីរផ្នែក:<br>ផ្នែកទី១- គឺបញ្ចូលកូដឃ្លាំង ឧ. អត្តសញ្ញាណឃ្លាំងដែលទំនិញនឹងត្រូវបានដាក់បញ្ចូល។<br>ចាំបាច់សម្រាប់តែរបបព្យួរពន្ធ។ មិនចាំបាច់សម្រាប់ករណីផ្សេងពីនេះ។<br>ផ្នែកទី២- គឺបញ្ចូលរយៈពេល (ចំនួនថ្ងៃ) ដែលទំនិញត្រូវបានអនុញ្ញាតអោយស្តុកទុកក្នុងឃ្លាំងណាមួយ។<br>ចាំបាច់សម្រាប់តែរបបព្យួរពន្ធ ឬមិនចាំបាច់សម្រាប់ករណីផ្សេងពីនេះ។ |
| B | គណនេយ្យលំអិត | ចាំបាច់ | ប្រអប់នេះត្រូវបានប្រើប្រាស់សំរាប់ព័ត៌មានដែលទាក់ទងនឹងគណនេយ្យដូចជាបែបបផែនទូទាត់ លេខវាយតម្លៃ លេខបង្កាន់ដៃ និងការធានា ដូចខាងក្រោម:<br>**i) បែបផែនទូទាត់**<br>បែបផែនទូទាត់ (ប្រអប់ B) ត្រូវប្រើភ្ជាប់នឹងប្រអប់ 48។ ប្រសិនបើ ប្រអប់ 48 មិនបានបំពេញ មានន័យថាប្រាក់ពន្ធ និងអាករត្រូវបានទូទាត់ភ្លាមៗ (ឬ បង់សាច់ប្រាក់)។ ប្រសិនបើប្រអប់ 48 ត្រូវបានបំពេញដោយលេខមូលប្បទានប័ត្រ ឬលេខគណនី មានន័យថាពន្ធ និងអាករត្រូវបានទូទាត់ជាក្រោយ។ |

| | | | |
|---|---|---|---|
| | | | ii) លេខវាយតម្លៃ<br>ប្រព័ន្ធ ASYCUDA នឹងផ្តល់លេខវាយតម្លៃដោយស្វ័យប្រវត្តិនៅលើប្រតិវេទន៍ក្រោយពីបញ្ចប់ការវាយតម្លៃ។<br>ចំពោះការបំពេញប្រតិវេទន៍ដោយដៃមិនមានលេខវាយតម្លៃនេះទេ។<br>iii) លេខបង្កាន់ដៃ<br>ប្រព័ន្ធ ASYCUDA នឹងផ្តល់លេខវាយតម្លៃដោយស្វ័យប្រវត្តិនៅលើប្រតិវេទន៍ក្រោយពីការទូទាត់ពន្ធ និងអាកររួច។<br>ចំពោះការបំពេញប្រតិវេទន៍ដោយដៃ គណនេយ្យករត្រូវសរសេរលេខបង្កាន់ដៃពន្ធនៅលើប្រតិវេទន៍ ។<br>iv) ការធានា<br>ប្រព័ន្ធ ASYCUDA នឹងបង្ហាញចំនួនប្រាក់ពន្ធ និងអាករសរុបដែលធានានៅលើប្រតិវេទន៍។<br>ការប្រើ SAD ដោយដៃ ប្រតិវេទនករត្រូវបំពេញនូវចំនួនប្រាក់ពន្ធ និងអាករដែលធានានៅលើប្រតិវេទន៍។<br>v) កម្រៃសរុប<br>បើសិនជាមានកម្រៃដែលត្រូវទូទាត់ច្រើនប្រភេទ(កម្រៃPSI + កម្រៃពីការលក់ប្រតិវេទន៍)ប្រអប់ B ត្រូវបំពេញនូវកម្រៃសរុបដែលត្រូវទូទាត់។<br>ចំពោះការប្រើប្រព័ន្ធ កម្រៃនីមួយៗត្រូវបានបង្ហាញនៅលើប័ណ្ណវាយតម្លៃ។<br>ការប្រើ SAD ដោយដៃ ប្រតិវេទនករត្រូវបំពេញនូវកម្រៃនីមួយៗនៅខាងក្រោមប្រអប់ D។<br>vi) ប្រាក់ពន្ធសរុបលើប្រតិវេទន៍<br>សរុបចំនួនប្រាក់ពន្ធ អាករ និងកម្រៃផ្សេងៗ ត្រូវបង់សំរាប់ប្រតិវេទន៍នេះ (សរុបពន្ធ / អាករ + សរុបកម្រៃ) |
| 54 | ហត្ថលេខា និងឈ្មោះប្រតិវេទនករ/អ្នកតំណាង | ចាំបាច់ | ឈ្មោះ កាលបរិច្ឆេទ និងហត្ថលេខាប្រតិវេទនករ/អ្នកតំណាង។ |
| 50 51 52 53 C D | | | បំរុងទុកសំរាប់ប្រើនាពេលអនាគត |